ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ កម្មវិធីស្រាវជ្រាវ : ជនជាតិភាគតិចនិងកេរតំណែលពីរបបខ្មែរក្រហម

◆ តើខ្មែរក្រោមជាជនជាតិភាគតិចឬ?

ចែកជូនដោយឥតគិតថ្លៃដល់វិហារអ៊ីស្លាមនិងឃុំមួយចំនួនទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេសសម្រាប់សហគមន៍ជនជាតិភាគតិចនៅកម្ពុជា ឆ្នាំ២០០៧

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខពិសេសសម្រាប់សហគមន៍ជនជាតិភាគតិចនៅកម្ពុជា

ប្រចាំខែកញ្ញា ឆ្នាំ២០០៧

## មាតិកា

◆ សំបុត្រៈកម្មវិធីសិក្សាស្រាវជ្រាវ ....................................១

**ផ្នែកឯកសារ**

◆ អាជីពជាគ្រូបង្រៀននិងឆ្មប............................................ ៤

◆ ការសន្ទនាដែលផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ............................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ជនជាតិចាមបានីនៅប្រទេសវៀតណាម...............................១៦

◆ ជនជាតិមិល.............................................................. ២២

◆ ក្រុមយុវជនចាមមុស្លីមនិងយុវនិស្សិតច្បាប់........................២៥

◆ ស្លាប់ដោយសារអង្ករ.....................................................៣២

**ផ្នែកច្បាប់**

◆ ការជម្លៀសប្រជាជននិងការនិរទេសក្នុងស្រុក........................៣៤

◆ តើខ្មែរក្រោមជាជនជាតិភាគតិចឬ? ..................................៣៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ចំនួនជនជាតិចាមដែលបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម............៤២

◆ ការតស៊ូនិងការផ្សះផ្សា..................................................៤៤

**ទំព័រថែរក្សារប្បធម៌ចាម**

◆ ភាសានិងអក្សរចាម.......................................................៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ គ្រួសារខ្ញុំ..............................................................៥៨



ហ្យៃ ទាប់



ព្រះសង្ឃខ្មែរក្រោម

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** *លីហ្សាប៉ែត ម៉ៃយ៉ើរ, អាញ៉ៅ ឌឹហ្វូ, កែវ ដាស៊ីល, លី សុផល, អេលីហ្សាប៉ែត វ៉ាន់ស្កាក់, ចន ឆរឆីអារី, អ៊ីសា ឧស្មាន, សាឡេះ អាប់ឌុលរ៉ស់ម៉ាន, គើ ម៉ាត់* ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** *សូ ហ្វារីណា* ***អ្នកបកប្រែៈ*** *ប៉ាន់ ស៊ីម៉ាឡា, ឌី ខាំបូលី* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ីម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *រ័ត្ន តារាពិដោរ*

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# កម្មវិធីសិក្សាស្រាវជ្រាវ : ជនជាតិភាគតិចនិងការដំណែលពីរបបខ្មែរក្រហម

បច្ចុប្បន្នមានសៀវភៅនិងអត្ថបទជាច្រើនសរសេរអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងវាសនានៃក្រុមមនុស្សមួយចំនួនតូចដែលប្រកាន់គោលជំហរនយោបាយ ជំនឿសាសនាផ្សេងៗគ្នានៅក្នុងសង្គមកម្ពុជា (តួយ៉ាងដូចជា អាចារ្យ បញ្ញវន្ត ទាហាន និងមន្ត្រីរាជការពីសម័យលន់នល់) ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក្រុមជនជាតិភាគតិចទទួលបានការយកចិត្តទុកដាក់តិចតួចបំផុត លើកលែងតែជនជាតិវៀតណាមប៉ុណ្ណោះដែលទទួលបានការចាប់អារម្មណ៍គួរឲ្យកត់សម្គាល់ ។ ផ្នែកសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងស្រាយបំភ្លឺអំពីតួនាទីរបស់ជនជាតិភាគតិចនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ការប្រព្រឹត្ត និងឥទ្ធិពលរបស់ជនជាតិភាគតិចចំពោះរដ្ឋាភិបាលអាណត្តិបន្តបន្ទាប់ ។ ក្នុងកម្មវិធីនេះ យើងនឹងកំណត់ថាតើតួនាទីរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានឥទ្ធិពលប៉ះពាល់ដល់ស្ថានភាពសង្គមកម្ពុជាបច្ចុប្បន្នដែរឬទេ?

គម្រោងនេះមានគោលបំណងជំរុញឲ្យមានការស្វែងយល់និងការគោរពគ្នាទៅវិញទៅមកចំពោះជនជាតិភាគតិចដទៃទៀតនៅកម្ពុជា ដើម្បីឲ្យមានសង្គមប្រជាធិបតេយ្យដ៏ពេញលេញមួយ ។ តាមរយៈការបង្ហាញអំពីទស្សនៈមិនសមស្របចំពោះជនជាតិភាគតិចដែលទទួលរងការឈឺចាប់ក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (មិនខុសគ្នាពីជនជាតិខ្មែរ) និងពីមូលហេតុនាំឲ្យក្រុមជនជាតិភាគតិចមួយចំនួនត្រូវបានផ្តាច់ខ្លួនចេញដោយមូលហេតុវិសមភាពសេដ្ឋកិច្ច ហើយអាចឈានទៅដល់ការប៉ុនប៉ងផ្នែកនយោបាយ ។ យើងសង្ឃឹមថា នឹងអាចលើកទឹកចិត្តទាំងសិស្សានុសិស្សនិងប្រជាជនទាំងឡាយ ផ្តល់ការគោរពចំពោះសមាសភាពជនជាតិផ្សេងទៀតដើម្បីទទួលបានសង្គមមួយដែលប្រជាជនគ្រប់ជាតិសាសន៍ទទួលបាននូវការគោរពស្មើៗគ្នាចំពោះមុខច្បាប់ ។

នៅក្នុងអំឡុងរបបសង្គមរាស្ត្រនិយម (ពីឆ្នាំ១៩៥៣ដល់១៩៧០) សម្តេច ព្រះនរោត្តម សីហនុ ស្នើសុំឲ្យហៅសហគមន៍អ៊ីស្លាមនៅកម្ពុជាថា “ខ្មែរអ៊ីស្លាម” ។ អ្នកខ្លះយល់ឃើញថា នេះជាការប៉ុនប៉ងចង់បញ្ចូលសហគមន៍អ៊ីស្លាមទៅក្នុងវប្បធម៌ជាតិរួមមួយ ។ រីឯក្នុងរបបលន់នល់ (១៩៧០-១៩៧៥) បានសម្តែងការអនុគ្រោះចំពោះជនជាតិចាម (សហគមន៍ចាមជាសហគមន៍មានឈ្មោះតាំងពីបូរាណកាលមក) ប៉ុន្តែរបបនេះបែរជាសម្លាប់ និងបណ្តេញជនជាតិភាគតិចវៀតណាមដោយឥតធម៌មេត្តាទៅវិញ ។ មិនត្រឹមតែប៉ុណ្ណោះ ជនជាតិវៀតណាមត្រូវបានចាត់ទុកជាសត្រូវរបស់រដ្ឋ ។

ជនជាតិវៀតណាមទទួលរងនូវការឈឺចាប់ពីការសងសឹកដ៏ឃោរឃៅក្នុងរបបខ្មែរក្រហមដោយសារមូលហេតុនយោបាយជាកត្តាចម្បង ។ សមាជិកនៃក្រុមជនជាតិនេះត្រូវបានដាក់ដោយឡែកដោយមូលហេតុថាអ្នកទាំងនោះមានលក្ខណៈសម្គាល់ខុសពីជនជាតិខ្មែរដែលជាប្រជាជនទូទៅ ។ ឧទាហរណ៍ជាក់ស្តែង អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញភ័ស្តុតាងបង្ហាញថា ជនជាតិចាមត្រូវបានសម្លាប់ក្នុងអត្រាមួយខ្ពស់ជាងជនជាតិខ្មែរ ។ ដោយឡែកជនជាតិចិនត្រូវបានដោយកទៅសម្លាប់ដោយសារមានសម្បុរសជ្រះនិងទ្រព្យសម្បត្តិស្តុកស្តម្ភ ។

ក្រុមជនជាតិភាគតិចឯទៀត (ជនជាតិភាគតិចមានដើមកំណើតនៅកម្ពុជា) មានប្រវត្តិធ្លាប់គាំទ្ររបបខ្មែរក្រហម ដូច្នេះជាទូទៅប្រជាជនទាំងនេះមិនសូវឆ្លងកាត់ការលំបាកធ្ងន់ធ្ងរទេ ។

រយៈពេលប៉ុន្មានឆ្នាំក្រោយរបបខ្មែរក្រហម សេរីភាពខាងសាសនានិងជនជាតិភាគតិចមានពន្លឺសាជាថ្មី ។ តួយ៉ាងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ពីឆ្នាំ១៩៧៩-១៩៨៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ) ជនជាតិភាគតិចចិនរស់នៅក្នុងស្ថានភាពដែលងាយនឹងទទួលរងឥទ្ធិពលពីកត្តា

នយោបាយភូមិសាស្ត្រ ។ ម្យ៉ាងវិញទៀត ដោយសារវៀតណាមមានអំណាចលើប្រទេសជាតិផង ក្នុងខណៈនោះជនជាតិភាគតិចវៀតណាមស្ថិតក្នុងស្ថានភាពវិជ្ជមានច្រើនជាងពេលមុនៗ ។

បច្ចុប្បន្ន ជនជាតិភាគតិចនៅប្រទេសកម្ពុជារស់នៅក្នុងសង្គមមានស្ថិរភាពជាងមុន ទោះបីជាភាពតានតឹងទូទៅនៅតែមានក៏ដោយ ជាពិសេសចំពោះជនជាតិវៀតណាមនិងថៃដែលជនជាតិទាំងពីរនេះធ្លាប់មានប្រវត្តិជា "សត្រូវ" នឹងកម្ពុជាអស់រយៈពេលជិត១ពាន់ឆ្នាំមកហើយ ។ ជាទូទៅ ជនអន្តោប្រវេសន៍វៀតណាមគឺជាប្រជាជនក្រីក្រ និងខំប្រឹងប្រែងស្វែងរកចំណូលជាមួយប្រជាជនកម្ពុជាតាមរយៈការនេសាទនិងការងារសំណង់ ។ សព្វថ្ងៃភាពល្អក់កករផ្លូវចិត្តរបស់ជនជាតិភាគតិចដែលបន្សល់ទុកពីរបបខ្មែរក្រហមនិងសម័យរំដោះចំពោះជនជាតិភាគតិចនៅតែជិតដាម ។ ទោះបីជាជនជាតិខ្មែរនិងថៃ មានភាសា វប្បធម៌ និងសាសនាប្រហាក់ប្រហែលគ្នា ក៏ប្រជាជនខ្មែរមួយចំនួនមានអារម្មណ៍មិនចូលចិត្តប្រទេសជឿនលឿននៅជិតខាង ។ កុបកម្មប្រឆាំងថៃឆ្នាំ២០០៣បានជះកំហឹងដោយសារតែពាក្យសម្តីរបស់តារាភាពយន្តថៃម្នាក់ដែលនិយាយថាប្រទេសថៃជា "ម្ចាស់ប្រាសាទអង្គរវត្ត" ។ កុបកម្មនេះបណ្តាលឲ្យស្ថានទូតថៃ និងអគារពាណិជ្ជកម្មថៃទទួលរងនូវការខូចខាតដោយសរុបជាទឹកប្រាក់មានតម្លៃប្រហែល៥០លានដុល្លារអាមេរិក ។ សកម្មភាពនេះបង្ហាញពីការបែកបាក់ទំនាក់ទំនងជនជាតិនៅកម្ពុជា ។

សាសនាគ្របដណ្តប់នៅប្រទេសកម្ពុជា (សាសនាព្រះពុទ្ធ សាសនាអ៊ីស្លាម និងសាសនាគ្រិស្ត) ប្រៀនប្រដៅឲ្យមនុស្សចេះអត់ឱនអធ្យាស្រ័យគ្នា ប៉ុន្តែក្នុងសង្គមកម្ពុជានៅតែបង្ហាញពីការមិនទុកចិត្តចំពោះប្រទេសជិតខាង ។ អ្នកទីក្រុងរស់នៅយ៉ាងចុះសម្រុងជាមួយជនជាតិភាគតិចឯទៀត ចំណែកការរស់នៅតាមភូមិស្រុកវិញ នៅតែមានការបែងចែក ជនជាតិចាម ខ្មែរ និងវៀតណាមរស់នៅដាច់ដោយឡែកពីគ្នា ។ ជាងនេះទៅទៀត ភាពតានតឹងដ៏ស្មុគស្មាញកំពុងលេចឡើងនៅកម្ពុជាដោយសារមានការហូរចូលនៃសាសនាថ្មីៗ និងនិកាយសាសនាផ្សេងៗទៀតជាច្រើន (ដូចជា និកាយប្រូតេស្តង់ នៅតាមខេត្តដែលជាតំបន់សម្បូរដោយជនជាតិភាគតិច អ្នកស្រុកភ្នំ និងនិកាយតឹងរ៉ឹងនៃសាសនាអ៊ីស្លាម) ។ របាយការណ៍ឆ្នាំ២០០២របស់ការិយាល័យសហរដ្ឋអាមេរិកបានគូសបញ្ជាក់ថា ៦ភាគរយនៃចំនួនប្រជាជនសរុបមានន័យថា ជនជាតិចាមប្រមាណ៧០ម៉ឺននាក់កំពុងប្រតិបត្តិនិកាយវ៉ាហាប៊ីដ៏ចំណាស់ ។ ដូច្នេះការយល់ដឹងអំពីបញ្ហាភាពតានតឹងរវាងជនជាតិភាគតិចមានសារសំខាន់ក្នុងការឆ្លុះបញ្ចាំងគោលនយោបាយពីដំបូងរបស់រដ្ឋចំពោះក្រុមជនជាតិ ក៏ដូចជាឆ្លុះបញ្ចាំងពីទំនាក់ទំនងអតីតកាលនិងបច្ចុប្បន្នរវាងក្រុមជនជាតិនៅកម្ពុជា ។

ការឃោសនានយោបាយត្រូវបានធ្វើឡើងតាមរយៈការបញ្ចុះបញ្ចូលនិងការប្រកាន់ពូជសាសន៍ក្នុងសង្គម ។ ការបោះឆ្នោតឆ្នាំ២០០៣ អាលែន មេយើ បានកត់សម្គាល់ថា ÷

យុទ្ធនាការប្រឆាំងគ្នាទាំងពីរផ្តោតជាចម្បងទៅលើការញុះញង់ឲ្យស្អប់និងការព្រួយបារម្ភចំពោះជនជាតិភាគតិចវៀតណាម ។ ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតនៅដើមឆ្នាំ ២០០៣ គណបក្សនយោបាយបានបង្កភាពរាំងស្ទះដោយលើកពីការជំទាស់ជាច្រើនដងប្រឆាំងនឹង "ជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់" ។ ប្រជាជនមួយចំនួនធំត្រូវបានបដិសេធមិនឲ្យចុះឈ្មោះបោះឆ្នោតដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោត ដោយគ្មានសម្អាងលើអ្វីក្រៅពីថា អ្នកចុះឈ្មោះមានឈ្មោះស្រដៀងវៀតណាម ឬរូបរាងដូចវៀតណាម ។

តាមការប៉ាន់ស្មានការឃោសនាលក្ខណៈស្នេហាជាតិនិយមជ្រុលនេះ បានបង្កឲ្យមានឧបទ្ទវហេតុផ្សេងៗ ដែលប៉ុនប៉ងដោយក្រុមមនុស្សអនាចារ ហើយក្នុងនោះមានករណីពីរ-បីទទួលបានជោគជ័យក្នុងការរារាំងមិនឲ្យជនជាតិវៀតណាមចូលរួមបោះឆ្នោត ។

សហគមន៍អឺរ៉ុបមានការយល់ឃើញប្រហាក់ប្រហែលគ្នាដែរ ។ ខណៈពេលផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនៅខែមិថុនាកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ មានរបាយការណ៍ស្តីពីការគំរាមកំហែងផ្នែកនយោបាយ និងគោលគំនិតប្រឆាំងយ៉ាងខ្លាំងនឹងជនជាតិវៀតណាមដែលស្តែងចេញដោយបេក្ខជនបោះឆ្នោត ។

ប្រព័ន្ធនយោបាយនៅកម្ពុជាប្រឈមនឹងកង្វះខាតការអនុគ្រោះ និងការមិនទុកចិត្តគ្នារវាងប្រជាជនភាគច្រើននិងជនជាតិភាគតិច ដែលតែងតែបង្កឧបសគ្គដល់ប្រសិទ្ធភាពការងារនៅក្នុងជួររដ្ឋាភិបាល (ជម្លោះផ្ទៃក្នុងនយោបាយបានរារាំងការបង្កើត

រដ្ឋាភិបាល និងអូសបន្លាយពេលវេលាតាំងពីខែកក្កដា ឆ្នាំ២០០៣ រហូតដល់ខែមេសា ឆ្នាំ២០០៤) និងភាពលម្អៀងក្នុងការអនុវត្តយុត្តិធម៌ ។ បញ្ហាជនជាតិភាគច្រើននិងភាគតិចនៅកម្ពុជា រួមទាំងបញ្ហាអត្តសញ្ញាណទំនាក់ទំនងរវាងជនជាតិ និងការប្រព្រឹត្តតាមផ្លូវច្បាប់និងនយោបាយនឹងត្រូវយកមកពិចារណាក្នុងការសិក្សានេះដោយយោងតាមទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយក្រុមជនជាតិភាគតិចនីមួយៗ ។ ការសិក្សានេះនឹងផ្តល់ព័ត៌មានឲ្យប្រជាជនដែលជាកត្តាចាំបាច់ក្នុងការស្ថាបនាលទ្ធិប្រជាធិបតេយ្យដើម្បីឲ្យប្រជាជនធ្វើការសម្រេចចិត្តប្រកបដោយការត្រិះរិះ និងចូលរួមកិច្ចការសាធារណៈ ដែលមានឥទ្ធិពលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។ ដរាបណាប្រជាជនយល់ដឹងពីបញ្ហានេះទើបអ្នកទាំងអស់គ្នាអាចជួយជ្រោមជ្រែងក្នុងការបង្កើតនិងទ្រទ្រង់សង្គមប្រជាធិបតេយ្យដ៏រឹងមាំមួយដែលមានសមាជិកធ្លាប់បានឆ្លងកាត់ឧបាយកលនយោបាយនេះ ។

គម្រោងស្រាវជ្រាវនេះនឹងបំពេញកន្លះចន្លោះការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីជនជាតិភាគតិចនៅកម្ពុជាដើម្បីលុបបំបាត់ការសង្ស័យចំពោះជនជាតិភាគតិចដែលមានអត្តសញ្ញាណខុសពីជនជាតិភាគច្រើន ។

ប្រជាជនកម្ពុជាហាក់បីដូចជាមិនមានទស្សនៈប្រាកដមួយនៅឡើយទេ អំពីថាតើជនជាតិភាគតិចតំណាងឲ្យសង្គមទាំងមូលយ៉ាងដូចម្តេច ។ អ្នកប្រាជ្ញល្បីល្បាញដែលធ្វើការស្រាវជ្រាវករណីប្រទេសកម្ពុជាមួយចំនួនដូចជា ប៊ែន យៀរនិន, ដេវីដ ឆេនល័រ និង ម៉ៃឃើល វីកឃីរី បានសិក្សាលើក្រុមជនជាតិភាគតិចក្នុងរបបខ្មែរក្រហម ។ ខណៈពេលការប្រកួតប្រជែងពានរង្វាន់ព្រះសីហនុរាជ ការស្រាវជ្រាវចូលរួមដោយសមាជិកជំនាញផ្សេងៗគ្នា បានធ្វើការសិក្សាទៅលើក្រុមជនជាតិចាម ចិន វៀតណាម ឡាវ ថៃ ភូមា និងជនជាតិភាគតិចតំបន់ខ្ពង់រាប ។ ការស្រាវជ្រាវនេះចាប់ផ្តើមនៅខែមិថុនា ឆ្នាំ១៩៩៥ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៩៦ ប៉ុន្តែលទ្ធផលនៃស្រាវជ្រាវមិនទាន់បានបោះពុម្ពផ្សាយនៅឡើយទេដោយសារកង្វះខាតថវិកា ។

កិច្ចការស្រាវជ្រាវពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើឡើងដើម្បីបំពេញចន្លោះនោះ ។ កិច្ចការស្រាវជ្រាវទីមួយនិងទីពីរជាលទ្ធផលពិសោធន៍របស់លោក អ៊ីសា ឧស្មាន អំពីសហគមន៍ចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងស្តីពីការបះបោររបស់ជនជាតិចាមក្នុងរបបនោះ ។ កិច្ចការទីបីដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗនេះ ស្រាវជ្រាវដោយលោក ស៊ឹម សូរិយា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និង សារ៉ា ខម នៃអង្គការសិទ្ធិមនុស្ស ។ កិច្ចការស្រាវជ្រាវនេះផ្តោតទៅលើប្រវត្តិសាស្ត្រនៃជនជាតិភាគតិចតំបន់ភ្នំនិងតួនាទីរបស់អ្នកទាំងនោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សេចក្តីប្រកាស

## ការសិក្សាស្រាវជ្រាវនិងចងក្រងសៀវភៅស្តីពីជនជាតិភាគតិចនៅប្រទេសកម្ពុជា

*ភាពតានតឹងរវាងជនជាតិផ្សេងៗធ្លាប់កើតមានរួចទៅហើយនៅក្នុងប្រទេសកម្ពុជា ។ ឧទាហរណ៍ កុបកម្មឆ្នាំ២០០៣ ប្រឆាំងស្ថានទូតថៃនិងអគារពាណិជ្ជកម្មផ្សេងៗ ហើយថ្មីៗនេះភាពតានតឹងកើតឡើងនៅក្នុងសហគមន៍មូស្លីមដែលមាននិកាយរបស់អ្នកកាន់សាសនាអ៊ីស្លាមប្រកាន់វ៉ាហាប៊ីប៉ុនប៉ងធ្វើឲ្យមានការផ្លាស់ប្តូរការរស់នៅរបស់ប្រជាជនចាមបែបបុរាណបានបង្ហាញឡើងយ៉ាងច្បាស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្នើឲ្យមានគម្រោងមួយរយៈពេល២ឆ្នាំដើម្បីពិនិត្យទៅលើប្រវត្តិសាស្ត្រសហគមន៍ជនជាតិផ្សេងៗនៅកម្ពុជា ការប្រព្រឹត្តរបស់ខ្មែរក្រហមមកលើជនជាតិផ្សេងៗ (ជនជាតិចាមមូស្លីមនិងជនជាតិវៀតណាមបានទទួលរងការគំរាមកំហែងយ៉ាងខ្លាំងនៅក្នុងរបបនោះ) និងស្ថានភាពរស់នៅរបស់ជនជាតិផ្សេងៗនាពេលបច្ចុប្បន្ន ។ គម្រោងនេះនឹងរុករកអត្តសញ្ញាណជនជាតិទំនាក់ទំនង និងការអនុវត្តផ្នែកនយោបាយ និងច្បាប់របស់ជនជាតិភាគតិចនៅប្រទេសកម្ពុជា រួមមាន ជនជាតិចាម ថៃ វៀតណាម ឡាវ ចិន ភូមា និងកុលសម្ព័ន្ធតំបន់ភ្នំ ។*

# អាជីពជាគ្រូបង្រៀននិងឆ្មប

នៅក្បែរស៊ូរ៉ាវ (ទីតាំងសម្រាប់ថ្វាយបង្គំ និងរៀបចំពិធីសាសនា) ភូមិរកាលើ មានផ្ទះសាមញ្ញមួយខ្នងសង់អំពីឈើខ្ពស់ផុតពីដីដំបូលប្រក់ស័ង្កសីជញ្ជាំងក្តារលាយស្លឹកបែរមុខទៅទិសខាងកើត ។ ស្ត្រីវ័យចំណាស់ម្នាក់កំពុងតែបង្រៀនផ្នែកសាសនាអ៊ិស្លាមដល់សិស្សចំនួន៣០នាក់ បានទទួលរាក់ទាក់ក្រុមការងារឲ្យឡើងអង្គុយលើផ្ទះ ។ បន្ទាប់ពីបង្រៀនសិស្សចប់ គាត់ក៏អនុញ្ញាតឲ្យក្រុមការងារសម្ភាសអំពីដំណើរជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។

ហ្យៃ នាប់ មានស្រុកកំណើតនៅភូមិតានង់ ឃុំព្រែកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ បន្ទាប់ពីបានរៀនភាសាខ្មែរបេះបន្តិចបន្តួច នាប់ ចាប់ផ្តើមរៀនផ្នែកសាសនាអ៊ិស្លាមជាមួយឪពុកម្តាយ ។ ឪពុកម្តាយរបស់ នាប់ ជាគ្រូបង្រៀនសាសនា ហើយជីដូនជីតារបស់គាត់ក៏ជាគ្រូបង្រៀនសាសនាដែរ ។ បងប្អូនបីនាក់របស់ នាប់ សុទ្ធតែធ្វើជាគ្រូបង្រៀនសាសនា ហើយរស់នៅបែកផ្ទះរៀងៗខ្លួនបន្ទាប់ពីរៀបការរួច ។ ហ្យៃ នាប់ ចូលចិត្តបង្រៀនសិស្សនិងមានគំនិតចង់ក្លាយជាឆ្មប ។ ក្រៅពីរៀនសូត្រខ្លួនឯង នាប់ បានជួយបង្រៀនសិស្សរបស់ឪពុកម្តាយគាត់ថែមទៀត ។


ហ្យៃ នាប់

## ជីវិតគូស្រករ

ការរៀបការនិងការទទួលខុសត្រូវរបស់ឪពុកម្តាយចំពោះកូនគឺជាវិន័យសំខាន់ណាស់នៅក្នុងសាសនាអ៊ិស្លាម ហើយប្រសិនបើកូនមិនទាន់គ្រប់អាយុ ១៥ឆ្នាំ ឬពេញវ័យ និងមិនទាន់មានគូស្រករ កូនត្រូវរស់នៅក្រោមការថែទាំនិងការប្រៀនប្រដៅរបស់ឪពុកម្តាយ ។ ប៉ុន្តែប្រសិនបើកូនស្រីរបស់ខ្លួនរៀបការរួច បន្ទុកទាំងអស់នឹងធ្លាក់ទៅលើប្តីដែលជាមេគ្រួសារវិញ ។ ការចែងបែបនេះគឺដើម្បីឲ្យក្រុមគ្រួសារនីមួយៗមើលថែទាំនិងគ្រប់គ្រងកូនៗឲ្យបានល្អ ហើយទម្លាប់នេះបានអនុវត្តតគ្នាពីមួយជំនាន់ទៅមួយជំនាន់ ។

ក្នុងវ័យ១៦ឆ្នាំ ឪពុកម្តាយរបស់ នាប់ បានផ្សំផ្គុំគាត់ជាមួយបងប្រុសជីដូនមួយឈ្មោះ ម៉ាត់ លី ដែលមានអាយុ២៨ឆ្នាំ ។ ដោយសារ នាប់ ជាកូនស្រី ដូច្នេះឪពុកម្តាយរបស់គាត់ចង់ឲ្យគាត់និងប្តីរស់នៅជាមួយ ។ នាប់ នៅតែបង្ហាត់បង្រៀនសិស្សជាមួយឪពុកម្តាយ ហើយប្តីរបស់គាត់ក៏ជាគ្រូបង្រៀនសិស្សដែរ ។

## ជីវភាពរស់នៅនិងអាជីពជាគ្រូបង្រៀន

នៅក្នុងភូមិនិងជនបទនានា អ្នកភូមិតែងតែយកអីវ៉ាន់និងរបស់របរប្រើប្រាស់ផ្សេងទៀតដូរគ្នាទៅវិញទៅមកសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ នាប់ បានបញ្ជាក់ថា កាលណោះ គ្រូបង្រៀនសាសនាមិនមានប្រាក់ខែទេ ។ ឪពុកម្តាយដែលមានកូនមករៀនបានឧបត្ថម្ភស្រូវ១ថាំងដល់គ្រូបង្រៀនសម្រាប់រយៈពេល១ឆ្នាំសិក្សា ហើយអ្នកភូមិខ្លះបានជូនអាហារនិងរបស់របរប្រើប្រាស់ផ្សេងៗដល់ឪពុកម្តាយរបស់គាត់ ជាពិសេសនៅខែរ៉ាម៉ាឌនដែលអ្នកកាន់សាសនាអ៊ិស្លាមតមការបរិភោគរយៈពេល១ខែរៀងរាល់មួយឆ្នាំម្តង ។

ភូមិតានង់មានមនុស្សរស់នៅប្រហែល៥០០គ្រួសារ ប្រហាក់ប្រហែលនឹងប្រជាជននៅភូមិរកាដែល នាប់ កំពុងរស់នៅដែរ ។ នាប់ បានរស់នៅជាមួយក្រុមគ្រួសារយ៉ាងមានសុភមង្គលជាមួយមុខរបរគ្រូបង្រៀន ហើយក្រៅពីអាជីពនេះ នាប់ ចេះវិជ្ជាពេទ្យថែមទៀត ។ ក្នុងឋានៈជាម្តាយក្មេង៥នាក់ នាប់ បញ្ជាក់ថា គាត់មិនបានរៀនមុខវិជ្ជាពេទ្យឆ្មបពីមុនមកទេ ប៉ុន្តែគាត់មានឧបនិស្ស័យពីកំណើតមក ។

## ការផ្លាស់ប្តូរ

នៅឆ្នាំ១៩៧០បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ភូមិតានដ៍មិនសូវមានការផ្លាស់ប្តូរប៉ុន្មានទេ ប្រជាជននៅតែប្រកបរបររកស៊ីដូចធម្មតា ហើយក្រុមគ្រួសាររបស់ ហៃរូ នាប់ នៅតែបង្ហាត់បង្រៀនសិស្សដដែល ។ ប៉ុន្តែនៅឆ្នាំ១៩៧៥ ភូមិតានដ៍ចាប់ផ្តើមមានការផ្លាស់ប្តូរ ខ្មែរក្រហមចាប់ផ្តើមបំបែកជនជាតិចាមដោយប្រាប់ឲ្យប្រជាជនចេញពីភូមិកំណើតឬកន្លែងដែលខ្លួនកំពុងស្នាក់នៅ ដើម្បីនាំយកប្រជាជនទៅដូរប្រេងជាមួយប្រទេសក្រៅ ។ ប្រជាជនជាច្រើនត្រូវបានជម្លៀសចេញពីភូមិភាគឧត្តរនិងបូព៌ាទៅភូមិភាគពាយ័ព្យ ។ នៅក្នុងភូមិរបស់ នាប់ មនុស្សចម្លែកជាច្រើនបានចូលមកប្រកាសតាមមីក្រូឲ្យអ្នកភូមិរៀបចំអីវ៉ាន់ចេញទៅប្រទេសក្រៅ ។ ដំបូង ប្រជាជនមិនទាន់រៀបចំអីវ៉ាន់និងរបស់របរនៅឡើយទេ ប៉ុន្តែដោយសារការឃោសនានេះហាក់ដូចជាមានលក្ខណៈបន្ទុំបន្ទិចម្តងៗ ទើបក្នុងរយៈពេល១០ថ្ងៃក្រោយ អ្នកភូមិព្រមទាំងក្រុមគ្រួសាររបស់ នាប់ នាំគ្នាចាកចេញពីភូមិដោយសង្ឃឹមថា នឹងបានទៅរស់នៅបរទេស ។ នាប់ ត្រេកអរណាស់គ្រាន់តែឮថាទៅបរទេស គាត់មិនយករបស់របរច្រើនទៅតាមខ្លួនទេ ។ គាត់វេច ខ្ចប់សម្លៀកបំពាក់ ចានឆ្នាំង និងស្បៀងបន្តិចបន្តួច ព្រមទាំងយកគម្ពីរគួរអានមួយក្បាលទៅជាមួយគ្រាន់ទុកសម្រាប់សូត្រ ។ នាប់ បានយកឧបករណ៍ពេទ្យសម្រាប់បង្កើតកូនមួយប្រអប់តូចទៅជាមួយដែរ ព្រោះគាត់យល់ថា របស់របរទាំងនោះអាចជួយសង្គ្រោះជីវិតមនុស្សបាន ។ ក្រុមគ្រួសាររបស់ នាប់ និងអ្នកភូមិទាំងអស់ត្រូវបានដឹកតាមកាណូតទៅដល់ទីក្រុងភ្នំពេញ បន្ទាប់មកពួកគាត់ធ្វើដំណើរតាមរថភ្លើងមកឈប់នៅខេត្តបាត់ដំបង រួចបន្តដំណើរដោយរទេះគោទៅតាមភូមិផ្សេងៗ ។

## ភូមិអន្លង់អាតាំង

នាប់ និងប្រជាជនទាំងអស់ខកចិត្តជាខ្លាំងនៅពេលដឹងថា ខ្មែរក្រហមបាននាំពួកគាត់មករស់នៅតំបន់ដាច់ស្រយាលគ្មានការទាក់ទងរវាងគ្នានឹងគ្នា ហើយបងប្អូនសាច់ញាតិត្រូវបានបំបែកចេញពីគ្នាទៀត ។ ក្រុមគ្រួសាររបស់ នាប់ ត្រូវចាត់តាំងឲ្យរស់នៅក្នុងភូមិអន្លង់អាតាំង ។ ភូមិអន្លង់អាតាំងជាភូមិមួយដែលខណ្ឌដោយព្រៃ ហើយគ្មានដំណាំដើមឈើសម្រាប់ហូបឡើយ ។ នាប់ រស់នៅជាមួយឪពុកម្តាយ បងស្រី ប្តី និងកូនរបស់គាត់ទាំង៥នាក់ ព្រមទាំងជនជាតិចាមចំនួន៤គ្រួសារទៀតដែលមកពីភូមិតានដ៍ជាមួយគ្នា រួមនឹងជនជាតិចិននិងជនជាតិខ្មែរដែលជម្លៀសមកពីភ្នំពេញ ។ នាប់ និងក្រុមគ្រួសារនាំគ្នាសង់ខ្ទមធ្វើពីឫស្សីដែលមានប្រវែង៤ម៉ែត្រគុណ៤ម៉ែត្រដើម្បីស្នាក់នៅ ។


កូនសិស្សរបស់ ហៃរូ ណាប់

គោលនយោបាយខ្មែរក្រហមគឺធ្វើការបោសសម្អាតទាហាននិងមន្ត្រីរដ្ឋការរបបមុន បន្ទាប់មក បញ្ញាជន គ្រូបង្រៀន សិស្ស និស្សិត វេជ្ជបណ្ឌិត អ្នកចេះដឹងខាងសាសនា ។ ដំបូងខ្មែរក្រហមចាប់ផ្តើមស្រាវជ្រាវធ្វើប្រវត្តិរូបប្រជាជន ។ អ្នកដែលមានប្រវត្តិរូបមិនស្អាតស្អំនឹងត្រូវចាប់ខ្លួន ។ អ្នកចេះដឹងខាងសាសនានិងមន្ត្រីជាច្រើនរូបត្រូវខ្មែរក្រហមចាប់ខ្លួនដោយប្រាប់ថា យកទៅកាប់ឫស្សីឬទៅរស់នៅភូមិថ្មី ។ នាប់ ចងចាំតែពាក្យមួយម៉ាត់គឺ «នេសាទ» ហើយអ្នកភូមិរបស់គាត់បានឯកភាពគ្នា

ដាក់ថាធ្វើនេសាទ ។ ឪពុកម្តាយរបស់ នាប់ ទោះបីជាធ្លាប់ធ្វើគ្រូបង្រៀនសាសនាក៏ដាក់ថាធ្វើនេសាទដែរ ដើម្បីចៀសវាងពីការចោទប្រកាន់ថាជាពួកមូលធន ។

ខ្មែរក្រហមមានគោលដៅផ្លាស់ប្តូរប្រទេសកម្ពុជាឲ្យទៅជាសង្គមបរិសុទ្ធមួយ ដែលការងារកសិកម្មគឺជាការងារចម្បងបំផុតក្នុងការអភិវឌ្ឍន៍ប្រទេស ។ ប្រជាជនទាំងចាស់ទាំងក្មេង ទាំងស្រីទាំងប្រុស តម្រូវឲ្យធ្វើការងារទាំងអស់គ្នា ។ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់ជំពូក៩ មាត្រា១២ចែងថា "...ពលករផ្សេងៗទៀតមានសិទ្ធិមានការងារធ្វើទាំងអស់ ភាពគ្មានការងារធ្វើមិនមានដាច់ខាតក្នុងកម្ពុជាប្រជាធិបតេយ្យ" ។ ហ្យៃ នាប់ ត្រូវចាត់បញ្ចូលក្នុងកងស្ទូងស្រូវនិងច្រូតកាត់ ។ ពេលព្រឹកគាត់ចូលធ្វើការនៅម៉ោង៧ ហើយចេញនៅម៉ោង១១ និងពេលរសៀលចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច ។ ជួនកាលគាត់ត្រូវចាត់តាំងឲ្យទៅធ្វើការនៅពេលយប់ទៀត ។ ប្តីរបស់គាត់ធ្វើការនៅក្នុងកងនេសាទនិងដើររកបន្លែសម្រាប់រោងបាយ ហើយកូនៗរបស់គាត់ធ្វើការនៅក្នុងកងកុមារ ។ ចំណែកឪពុកម្តាយរបស់គាត់ត្រូវអង្គការចាត់ឲ្យថែទាំក្មេងៗនៅក្នុងភូមិ ។

នៅក្នុងភូមិអន្លង់អាទាំង មានរោងបាយពីរសម្រាប់ប្រជាជនដែលនៅសងខាងព្រែក ។ ព្រែកជាប្រភពទឹកសម្រាប់អ្នករស់នៅភូមិអន្លង់អាទាំង ។ នាប់ ដងទឹកពីព្រែកនោះមកប្រើប្រាស់ប្រចាំថ្ងៃសម្រាប់ងូតនិងហូប ។ គាត់តែងតែដាក់ដាំមុនពេលហូប ដើម្បីចៀសវាងជំងឺតម្កាត់ផ្សេងៗ ។

ផែនការ៤ឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យដែលតម្រូវឲ្យប្រជាជនធ្វើស្រែសមូហភាពមិនអាចផ្គត់ផ្គង់តម្រូវការរបស់ប្រជាជនបានឡើយ ។ ទិន្នផលស្រូវដែលទទួលបានក្នុងមួយឆ្នាំៗ មួយផ្នែកត្រូវនាំទៅផ្គត់ផ្គង់ទ័ពនៅសមរភូមិមុខ និងមួយផ្នែកត្រូវនាំចេញទៅក្រៅប្រទេស ដើម្បីដោះដូរជាមួយសព្វាវុធនិងសម្ភារប្រើប្រាស់ ហើយនៅសល់មួយផ្នែកទៀតសម្រាប់បំពេញតម្រូវការរបស់ប្រជាជន ។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រជាជនទទួលបានអាហារកាន់តែតិចទៅៗ ហើយថែមទាំងត្រូវរ៉ាប់រងការងារកាន់តែធ្ងន់ធ្ងរលើសពីកម្លាំងកាយថែមទៀត ដែលនេះបណ្តាលឲ្យប្រជាជនជាច្រើនត្រូវស្លាប់ដោយសារអត់អាហារនិងជំងឺបាត់កម្លាំង ។

## មរណភាពរបស់ឪពុកនិងកូនៗរបស់ ហ្យៃ នាប់

របបអាហារនៅក្នុងភូមិអន្លង់អាទាំងមានតែបបររាវកក្កុក ។ នៅឆ្នាំ១៩៧៦ ដោយទទួលរបបអាហារមិនគ្រប់គ្រាន់ ឪពុករបស់ នាប់ ក៏ត្រូវស្លាប់ ។ នាប់ បានទៅអង្វរប្រធានកងពីរដងទម្រាំទទួលបានការអនុញ្ញាតពីប្រធានកងដើម្បីរៀបចំបញ្ចុះសាកសពឪពុកតាមប្រពៃណីទំនៀមទម្លាប់សាសនាអ៊ីស្លាម ។

ក្រោយមក កូនបីនាក់របស់ នាប់ បានស្លាប់បន្តបន្ទាប់គ្នាដោយអត់អាហារបរិភោគ ។ នាប់ នៅសល់តែកូនពីរនាក់ប៉ុណ្ណោះ គឺ ហ្សីម៉ាស់ (ស្រី) និង រ៉ូហ្សាលី (ប្រុស) អាយុ៥ឆ្នាំ ។ ក្រៅពីស្លាប់ដោយអត់អាហារ ប្រជាជនក៏ទទួលរងការគំរាមកំហែងយកទៅសម្លាប់តាមរយៈការស្រាវជ្រាវរកមន្ត្រីរដ្ឋការរបបមុននិងអ្នកពាក់ព័ន្ធនឹងសមាសភាពមិនល្អដែរ ។ នាប់ កើតការភិតភ័យនៅពេលដឹងថាបាត់មនុស្សជាបន្តបន្ទាប់នៅក្នុងភូមិអន្លង់អាទាំង ។

## ធ្វើឆ្មបក្នុងរបបខ្មែរក្រហម

ក្រៅពីធ្វើស្រែជូនអង្គការ នាប់ ត្រូវបានជ្រើសរើសជាឆ្មបប្រចាំភូមិអន្លង់អាទាំង ។ នាប់ បានជួយបង្កើតកូនឲ្យស្ត្រីជាច្រើននាក់ ដោយប្រើឧបករណ៍ដែលគាត់ដាក់ទៅតាមខ្លួន ហើយខ្មែរក្រហមមិនបានសួរដេញដោលគាត់អំពីឧបករណ៍ទាំងនោះទេ ។ ការបង្កើតកូនគឺជាការងារមួយដែល នាប់ ចូលចិត្ត ប៉ុន្តែគាត់គ្រាន់តែតូចចិត្តនឹងខ្មែរក្រហមដែលផ្តល់អាហារឲ្យគាត់មិនគ្រប់គ្រាន់និងកង្វះខាតថ្នាំសង្កូវសម្រាប់ស្ត្រីប៉ុណ្ណោះ ។ ម្យ៉ាងទៀតខ្មែរក្រហមបានប្រើឲ្យស្ត្រីមានផ្ទៃពោះចុះទៅធ្វើការទាំងមិនទាន់រឹងដៃរឹងជើង ។ ស្ត្រីខ្លះទាស់ស្លាប់ដោយសារការបង្ខំឲ្យធ្វើការងារធ្ងន់ ។ បងថ្លៃរបស់ នាប់ ទាស់ស្លាប់ដោយសារតែទូលស្រូវទាំងល្ងីៗ ក្រោយពីសម្រាលកូនរួចបានប្រហែល១០ថ្ងៃ ។

## ប្រសូត្រកូនបុត្រដោយខ្លួនឯង

ក្រោយមក នាប់ មានផ្ទៃពោះ ។ គាត់ឃ្លានចង់ហូបផ្លែក្រូចប៉ុន្តែគាត់មិនអាចរកបានព្រោះនៅទីនោះមិនមានដើមឈើហូបផ្លែ ដូច្នេះគាត់ចេះតែលេបទឹកមាត់ទ្រាំអត់ឃ្លាននិងធ្វើការងាររហូតដល់ពេលគ្រប់ខែ ។ នាប់ បង្កើតកូនដោយខ្លួនឯងដូចដែលគាត់ធ្លាប់បង្កើតកូនឲ្យស្ត្រីផ្សេងទៀតដែរ ។ កូនប្រុសរបស់គាត់

ប្រសូតចេញមកដោយសុវត្ថិភាព ។ នាប់ រំឭកថា ការបង្កើតកូនឲ្យអ្នកដទៃនិងបង្កើតកូនឲ្យខ្លួនឯងគឺដូចគ្នា ។ នាប់ សម្រាកអាំងភ្លើងលើគ្រែឫស្សីក្នុងខ្ទមដើម្បីកម្តៅសរសៃ និងហូបថ្នាំបុរាណដែលប្តីរបស់គាត់ដើរកាប់ឫសឈើយកមកឲ្យដើម្បីឲ្យមានទឹកដោះគ្រប់គ្រាន់សម្រាប់បំបៅកូន ។ នាប់ បានដាក់ឈ្មោះឲ្យកូនរបស់គាត់ថា ស្វៃម៉ាន (ដែលជាឈ្មោះរបស់ឪពុកដែលបានស្លាប់ទៅ) ក្នុងគោលបំណងតំណាងឲ្យឈ្មោះឪពុក ។

## ទោសលួចត្រកួន

ការលួចរបស់សមូហភាពគឺជាទោសដែលត្រូវអប់រំនិងកសាង ហើយអ្នកដែលត្រូវរកឃើញថាជាចោរ សុទ្ធតែត្រូវចាប់ខ្លួនមកអប់រំឬទទួលរងការវាយដំមិនថា ចាស់ក្មេង ប្រុសស្រីឡើយ ។ ថ្ងៃមួយនៅលើគ្រែកំពុងអាំងភ្លើង នាប់ បានប្រើកូនប្រុសរបស់គាត់ឈ្មោះ រ៉ូហ្សាលី ដែលមានអាយុ៩ឆ្នាំឲ្យទៅបេះត្រកួននៅតាមវាលស្រែដើម្បីយកមកស្ងោរលាយជាមួយបបរដែលគេចែកឲ្យ ។ នាប់ យល់ថា បបរដ៏តិចតួចនោះមិនអាចធ្វើឲ្យគាត់បាត់ឃ្លានឡើយ ។ គាត់បេះតែទន្ទឹងរង់ចាំដូវកូនយ៉ាងយូរ ។ ក្រោយមកអ្នកជិតខាងប្រាប់ថា កូនរបស់គាត់ត្រូវឈ្លបចាប់វាយដំរហូតជិតស្លាប់ដោយចោទថាលួចបូតកួរស្រូវ ។ គ្រាន់តែឮដូច្នេះ ប្តីរបស់គាត់បានស្ទុះងើបទាំងឈឺដោយសារជើងរបស់គាត់ហើម ហើយដើរអូសជើងទៅតាមរកកូន រួចក៏ប្រទះឃើញកូនដេកថ្ងូរនៅក្បែរប្រឡាយដែលមានស្រែអមសងខាង ។ គាត់ក៏ក្រាហ៍កូនត្រឡប់មកខ្ទមឫស្សីវិញ នាប់ អាណិតកូននិងប្តីខ្លោចចិត្តនៅពេលឃើញអ្នកទាំងពីរត្រឡប់មកវិញក្នុងស្ថានភាពយ៉ាប់យ៉ឺនបែបនេះ ។ ជាពិសេស នៅពេលឃើញកូនរបស់គាត់កាន់ត្រកួនបីបួនទងមកជាមួយ ។ នាប់ បានសួរបញ្ជាក់កូនថា «តើមានទៅលួចបូតស្រូវអង្គការដែរឬទេ?» រ៉ូហ្សាលី និយាយថាមិនបានធ្វើដូច្នេះទេ ។ [បច្ចុប្បន្ន រ៉ូហ្សាលី មានប្រពន្ធហើយផ្លាស់ទៅរស់នៅភូមិកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម] ។

## ការប្រណិប័តន៍សាសនាត្រូវហាមឃាត់

គោលការណ៍របស់ខ្មែរក្រហមគឺលុបបំបាត់សាសនាទាំងអស់ ។ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យជំពូក១៥ មាត្រា ២០ ចែងថា «ប្រជាជនគ្រប់រូបមានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនជឿជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន ។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិតេយ្យនិងប្រជាជនកម្ពុជាដាច់ខាត» ។ ខ្មែរក្រហមចាត់ទុកថា សាសនាដែលមានពីរបបមុនគឺសុទ្ធតែជាសាសនាប្រតិកិរិយាដែលអាចបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែទោះបីខ្មែរក្រហមលុបបំបាត់មិនឲ្យមានសាសនាក៏ដោយ ក៏អ្នកកាន់សាសនា(ទាំងព្រះពុទ្ធនិងអ៊ីស្លាម)មួយចំនួន មិនអាចបំភ្លេចការថ្វាយបង្គំព្រះ (សំពះយ៉ាំង) និងការបួស (ការតមអាហារ) បានឡើយ ។ សម្រាប់ជនជាតិចាមមូស្លីមមួយចំនួនដែលជាអ្នកប្រណិប័តន៍ខ្ជាប់ខ្ជួនត្រូវខ្មែរក្រហមធ្វើទារុណកម្មឬសម្លាប់ដោយសារការប្រឆាំងនឹងគោលការណ៍ខាងលើ ។ នាប់ ក៏បានលួចថ្វាយបង្គំក្នុងចិត្តនិងបួសខ្លះដែរ ។

## ស្ថានភាពមួយឆ្នាំមុនរំដោះ

ក្រោយពីប្រមូលផលស្រូវបានច្រើន គណៈសហករណ៍បានដាំបាយឲ្យប្រជាជននៅក្នុងភូមិហូបម្តងម្កាល ហើយជួនកាលមានកាប់ជ្រូកទៀតផង ។ នាប់ តែងតែបន់ស្រន់និងបដិសេធមិនព្រមហូបសាច់ជ្រូកឡើយ យូរៗម្តងទើបចុងភៅស្ត្រីឲ្យពួកគាត់ហូប ។

នៅឆ្នាំ១៩៧៨ ការរស់នៅរបស់ប្រជាជននៅភូមិអន្លង់អាទាំងកាន់តែដុនដាប មនុស្សជាច្រើនធ្លាក់ខ្លួនស្គមនៅសល់តែស្បែកដណ្តប់ឆ្អឹង ដោយសាររបបអាហារដែលទទួលបានកាន់តែតិចទៅៗ ។ ជួនពេលខ្លះ ចុងភៅធ្វើបបរហើយជ្រលក់ក្បាលជ្រូកចូលទៅក្នុងឆ្នាំងដើម្បីឲ្យបបរមានរសជាតិ ។ ក្រោយមក ប្រជាជនចាមត្រូវប្រធានសហករណ៍តម្រូវឲ្យហូបបបរនោះ ។ ប៉ុន្តែ នាប់ សុខចិត្តអត់ ទោះបីហេវហត់យ៉ាងណាក៏ដោយ ។ ជនជាតិចាម៣គ្រួសារទៀត ដែលមិនអាចទ្រាំទ្រនឹងការរស់នៅបែបនេះបានក៏នាំគ្នាលួចភៀសខ្លួនទៅរស់នៅកន្លែងផ្សេង ចំណែក នាប់ ទោះបីលំបាកយ៉ាងណាក៏ដោយ ក៏ទ្រាំរស់នៅក្នុងភូមិអន្លង់អាទាំងជាមួយម្តាយចាស់ជរាតទៅទៀត ។

## ១០ថ្ងៃមុនរំដោះ

នាប់ រំឭកដល់ពេលមួយដែលខ្មែរក្រហមហៅមនុស្សទៅប្រជុំ ហើយគាត់កាន់តែភ័យខ្លាំងមែនទែននៅពេលដែលខ្មែរក្រហមជីករណ្តៅបម្រុងសម្លាប់មនុស្សទាំងអស់នោះ ។ ប៉ុន្តែផែនការនេះ

ត្រូវរលាយទៅវិញនៅពេលដែលកងទ័ពវៀតណាមវាយសម្រុកចូលប្រទេសកម្ពុជា។ ម្តាយរបស់ នាប់ ស្លាប់ប្រហែលមួយសប្តាហ៍មុនកងទ័ពវៀតណាមចូលមកដល់។ ពេលនោះគាត់បានទៅអង្វរមេកងម្តងទៀតដើម្បីយកសពម្តាយទៅបញ្ចុះ។ នៅពេលកងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជា នាប់ បាននាំគ្នាធ្វើដំណើរមកស្រុកកំណើតវិញ ប៉ុន្តែ នាប់ គ្មានកម្លាំងកំហែងសោះ ព្រោះជើងទាំងពីររបស់គាត់ទន់លុតលុន់ តែគាត់បានប្រើឈើច្រត់ជាជំនួយ។ ចំណែកប្តីរបស់គាត់ចងក្រមាដាក់កូនដែលទើបនឹងកើត ស្ពាយពីក្រោយខ្នង។ នាប់ បានរៀបរាប់ពេលដែលគាត់ធ្វើដំណើរចេញមកថា *«កាំភ្លើងលាន់ឮពីគ្រប់ទិស អ្នកភូមិនាំគ្នារត់រប៉ាត់រប៉ាយអស់។ កូនខ្ញុំឈ្មោះ ស្ទៃម៉ាន អាចរស់បានដោយសារតែប្តីរបស់ខ្ញុំទេ បើមិនមានគាត់ វាមិនអាចរស់បានឡើយ ហើយខ្ញុំហ្នឹងប្រហែលជាងាប់មុនគេ ព្រោះមិនដឹងជារត់ទៅខាងណា»*។

ខ្មែរក្រហមត្រូវបានផ្តួលរំលំពីអំណាចដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនទាំងអស់បានបែកផ្លូវគ្នាដើរស្វះស្វែងរកក្រុមគ្រួសារដើម្បីជួបជុំគ្នា ធ្វើដំណើរត្រឡប់មកលំនៅដ្ឋានវិញ។ ចំណែកខ្មែរក្រហមមួយភាគធំបានរត់គេចខ្លួនសំដៅទៅភាគខាងលិចប្រទេសកម្ពុជាហើយថែមទាំងកៀរប្រជាជនទៅជាមួយផង។ កងទ័ពខ្មែរក្រហមមួយចំនួនទៀតត្រូវកងទ័ពវៀតណាមចាប់បាន ហើយប្រជាជនដែលមានកំហឹងឈឺចាប់ក៏នាំគ្នាវាយសម្លាប់ភ្លាមៗ។

ខ្មែរក្រហមមួយចំនួននៅតែបន្តរស់នៅក្នុងភូមិដែលស្ថិតនៅឆ្ងាយៗពីទីរួមខេត្តនិងទីប្រជុំជន ហើយធ្វើការវាយប្រយុទ្ធជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បណ្តាលឲ្យប្រជាជនមួយចំនួនមិនអាចវិលត្រឡប់ទៅភូមិកំណើតរបស់ខ្លួនបាន។ ប្រហែលមួយឆ្នាំក្រោយមក នាប់ និងក្រុមគ្រួសារ បានធ្វើដំណើរត្រឡប់ទៅភូមិកំណើតវិញ ប៉ុន្តែមិនទាន់ទៅដល់ភូមិផង អ្នកស្រុកដែលរស់នៅក្បែរនោះប្រាប់ថា ភូមិតានង់មិនទាន់មានសុវត្ថិភាពនៅឡើយព្រោះមានខ្មែរក្រហមនៅបន្តក្នុងភូមិ។ នាប់ ក៏ត្រឡប់ក្រោយវិញ ហើយឈប់នៅត្រឹមភូមិរកា។ ភូមិរកាមានព្រៃព័ទ្ធជុំវិញហើយនៅសល់ផ្ទះមួយៗក្នុងភូមិ។ ដោយសារភូមិនេះត្រូវបានបោះបង់ចោលរយៈពេលយូរ អ្នកភូមិនាំគ្នាកាប់ឆ្ការព្រៃដើម្បីសង់រោងនិងផ្ទះស្នាក់នៅ។ នាប់ បានសង់រោងតូចមួយនៅលើដីដែលមានម្ចាស់ ហើយបង្ហាត់បង្រៀនសិស្សនៅក្បែរវិហារអ៊ីស្លាមមួយ។ ដោយសារគ្រូបង្រៀនសាសនាអ៊ីស្លាមច្រើន ក្រុមគ្រួសារ ហៃ្យ នាប់ ក៏ផ្លាស់ប្តូរទីលំនៅមកសង់ផ្ទះប្រក់ស័ង្កសីនិងជញ្ជាំងក្តារលាយស្លឹកនៅក្បែរស៊ូរ៉ាវដើម្បីងាយស្រួលក្នុងការបង្រៀន។ នាប់ បញ្ជាក់ថា ផ្ទះនោះយោលរញ្ជួយនៅពេលមានខ្យល់ម្តងៗ។ នៅពេលរដូវទឹកឡើង ប្តីរបស់គាត់រៀបចំក្តារធ្វើស្ពានឆ្លងពីផ្ទះមួយទៅផ្ទះមួយទៀតរហូតដល់មាត់ផ្លូវថ្នល់។

## ជីវភាពបច្ចុប្បន្ននិងការយល់ឃើញចំពោះរបបខ្មែរក្រហម

សព្វថ្ងៃនេះ នាប់ និងប្តីជាគ្រូបង្រៀនសាសនានៅលើផ្ទះរបស់ខ្លួន ដែលនៅពេលដំបូងមានសិស្សប្រហែល១០០នាក់ ក្រោយមកនៅសល់ប្រហែល៣០នាក់។ ការដែលចំនួននេះចុះថយវិញព្រោះសិស្សធំៗដែលរៀនបានខ្ពស់ចេញទៅបន្តការសិក្សាថ្នាក់ខ្ពស់ជាមួយគ្រូផ្សេងទៀត ខ្លះត្រូវរៀបការ ហើយខ្លះចេញទៅរៀននៅភ្នំពេញនិងនៅបរទេស។ ទោះបីជាយ៉ាងណា នាប់ មិនដែលបានទទួលប្រាក់ខែឡើយ អ្នកភូមិដែលយកកូនមកផ្ញើបានជូនជាប្រាក់បុជារបស់របរប្រើប្រាស់ផ្សេងៗ។ នៅឆ្នាំ១៩៨៧ នាប់ ត្រូវបានអញ្ជើញឲ្យចូលរួមវគ្គបំពាក់បំប៉នខាងវិជ្ជាឆ្មបរយៈពេលមួយសប្តាហ៍បន្ថែមទៀត ហើយទទួលបានសញ្ញាប័ត្រដែលប្រគល់ដោយគណៈកម្មការសុខភាពស្រុកកំពង់សៀមគឺលោក អេង ងួន និងឯកភាពពីគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុកកំពង់សៀមគឺលោក ឌុល អៀង។ នាប់ កាន់តែមានទំនុកចិត្តក្នុងការបង្កើតកូនឲ្យស្ត្រីដែលមានផ្ទៃពោះ ហើយអ្នកភូមិតែងតែអញ្ជើញគាត់ទៅបង្កើតកូនជានិច្ច។ ម្យ៉ាងទៀត នាប់ ចេះចាក់ថ្នាំទាស់សរសៃខ្ចី ចំណែកប្តីរបស់គាត់លក់ថ្នាំបុរាណខ្មែរសម្រាប់ព្យាបាលជំងឺទាស់។ ប៉ុន្តែដោយសារមន្ទីរពេទ្យរដ្ឋនិងគ្លីនិកព្យាបាលជំងឺកើនឡើងច្រើននៅក្នុងភូមិ ស្ត្រីមានផ្ទៃពោះភាគច្រើនដែលមានជីវភាពធូរធារតែងតែទៅពិនិត្យពោះនិងសម្រាលកូននៅមន្ទីរពេទ្យឬគ្លីនិកឯកជនជាង។

សព្វថ្ងៃ នាប់ មានអាយុ៦៦ឆ្នាំ មានកូន៥នាក់ ដែលកូនទាំង៥របស់គាត់រៀបការអស់ហើយ។ នាប់ រស់នៅជាមួយប្តីនិង

កូនប្រុសឈ្មោះ ស្មែម៉ាន ដែលប្រកបរបររត់ម៉ូតូឌុប ។ ហ្វៃ នាប់ មិនមានបងប្អូននៅភូមិតាននេះទេ (ព្រោះបងប្អូនរបស់គាត់ស្លាប់គ្មានសល់ម្នាក់ក្រោយរបបខ្មែរក្រហមដួលរលំ) ។ ក្រុមគ្រួសាររបស់គាត់ប្រៀបដូចជាសមាជិកមួយនៅក្នុងភូមិ ។ អ្នកភូមិតែងស្រឡាញ់រាប់អានក្រុមគ្រួសារគាត់ដូចជាសាច់ញាតិរបស់ខ្លួនដែរ ។ នាប់ ពេញចិត្តនឹងជីវិតរស់នៅសព្វថ្ងៃ ទោះបីជីវភាពមិនសូវធូរធារក៏ដោយ ព្រោះគាត់បានសម្រេចគោលបំណងដែលបានប៉ងក្នុងរបបខ្មែរក្រហមថានឹងធ្វើជាគ្រូបង្រៀនសាសនាអ៊ីស្លាមនៅពេលប្រទេសបានសុខសន្តិភាព ។ នាប់ គាំទ្រឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រោះគាត់មិនចង់ឲ្យរបបខ្មែរក្រហមត្រឡប់មកធ្វើបាបក្មេងជំនាន់ក្រោយវិញឡើយ ។

អង្គជំនុំជម្រះវិសាមញ្ញដែលមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិកំពុងធ្វើការដើម្បីស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ជូនជនរងគ្រោះដោយរបបខ្មែរក្រហម ។ ប្រជាជនកម្ពុជាតែងតែទន្ទឹងរង់ចាំមើលការពិតតាមផ្លូវច្បាប់ដែលនឹងត្រូវលាតត្រដាងឡើងក្នុងពេលឆាប់ៗខាងមុខនេះជានិច្ច ។

### ការទប់ស្កាត់របបខ្មែរក្រហម

ប្រទេសជាច្រើនដែលទទួលរងអំពើប្រល័យពូជសាសន៍ ឬជម្លោះ បានខិតខំស្វែងរកវិធីផ្សេងៗដើម្បីទប់ស្កាត់ការកើតឡើងវិញនូវការកាប់សម្លាប់គ្មានត្រាប្រណីតាមរយៈការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់និងសង្គម ដូចជាតាមរយៈការបង្កើតតុលាការដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលបានកើតឡើងឬបង្កើតជាគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាររវាងជនរងគ្រោះនិងជនដៃដល់ ឧទាហរណ៍ ករណីប្រទេសនានានៅអាហ្វ្រិកខាងត្បូង ។ បន្ថែមលើសពីនេះ ការចងក្រងជាឯកសារប្រវត្តិសាស្ត្រនិងការអប់រំដល់មនុស្សជំនាន់ក្រោយគឺជាវិធីសាស្ត្រសំខាន់បំផុតដែលប្រទេសទទួលរងអំពើប្រល័យពូជសាសន៍បានអនុវត្ត ។ ហ្វៃ នាប់ យល់ថា ដើម្បីទប់ស្កាត់ របបខ្មែរក្រហមលុះត្រាតែក្មេងៗយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមហើយព្យាយាមស្វែងយល់អំពីកំហុសដែលមេដឹកនាំក្នុងរបបនោះបានប្រព្រឹត្ត ។ គាត់បន្ថែមថា មនុស្សទាំងអស់ត្រូវនាំគ្នាប្រព្រឹត្តអំពើល្អនិងបេះអត់ឱនឲ្យគ្នា ។

សៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបោះពុម្ពផ្សាយក្នុងខែឧសភា ឆ្នាំ២០០៧ ត្រូវបានក្រសួងអប់រំអនុញ្ញាតឲ្យធ្វើជាសៀវភៅបន្ថែកសម្រាប់គ្រូក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សមធ្យមសិក្សាទាំងអស់ ។ ក្រោមគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំដែលបង្កើតឡើងនៅឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការជាមួយសហគមន៍ចាមមូស្លីមនិងកុលសម្ព័ន្ធជនជាតិផ្សេងៗនៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់ពីបទពិសោធន៍របស់សហគមន៍ និងការជម្នះក្នុងការរស់រានពីរបបខ្មែរក្រហម ។ សម្រាប់សហគមន៍ចាមមូស្លីម មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើការជាមួយហាកិមតួននៅតាមវិហារអ៊ីស្លាម ស្ត្រីនិងយុវជនជំនាន់ក្រោយដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រសម្រាប់សហគមន៍ និងអប់រំយុវជនពីរបបខ្មែរក្រហម ។

**សូ ហ្វារីណា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០–៧ៈ៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧–៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០–៧ៈ៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា និង គាត លក្ខិណា**

# ការសន្ទនាដែលផ្លាស់ប្តូរជីវិតរបស់ខ្ញុំ : ការផ្សារភ្ជាប់យុវជនទៅនឹងរឿងរ៉ាវផ្ទាល់ខ្លួនពីអំពើប្រល័យពូជសាសន៍

## អារម្ភកថា

ពាក្យ“ប្រល័យពូជសាសន៍”មិនទាន់ត្រូវបានបង្កើតឡើងទេ មុនរយៈកាលហូឡូខសត៍ (ការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅទ្វីបអឺរ៉ុបក្នុងអំឡុងសង្គ្រាមលោកលើកទី២) ។ តាមពិតទៅ ពាក្យនេះត្រូវបានបង្កើតឡើងបន្ទាប់ពីហូឡូខសត៍ ជាវិធីក្នុងការកំណត់និយមន័យនិងដើម្បីស្វែងយល់ឲ្យបានច្បាស់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលទាក់ទងទៅនឹងសកម្មភាពនិងបំណងក្នុងការលុបបំបាត់ចោលទាំងស្រុងឬដោយផ្នែកនូវក្រុមមនុស្សដោយផ្អែកទៅលើជាតិសាសន៍ សាសនា ឬ ពូជសាសន៍។ ពាក្យប្រល័យពូជសាសន៍មានន័យជាភាសាអង់គ្លេសថា “*Genocide*” ។ “*geno*” ជាភាសាក្រិកមានន័យថា គ្រួសារកុលសម្ព័ន្ធ ឬ ពូជសាសន៍មួយ ។ “*cide*” ជាភាសាឡាតាំងមានន័យថាសម្លាប់រង្គាល ។ ពាក្យនេះបង្កើតឡើងដោយលោក រ៉ាហ្វែល លីមគិន (*Raphael Lemkin*) ជាអ្នកច្បាប់ជនជាតិជ្វីហ្វដើមកំណើតប៉ូឡូញនៅឆ្នាំ១៩៤៣ ។ គឺបន្ទាប់ពីរយៈកាលហូឡូខសត៍ ទើបពាក្យប្រល័យពូជសាសន៍ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយនិយមន័យតាមផ្លូវច្បាប់ត្រូវបានបង្កើតឡើងដើម្បីកាត់ទោសបទឧក្រិដ្ឋនេះ ។



ខ្លោងទ្វារចូលទៅកាន់ជំរុំអូសស៊ីចហ្ស៍

ពាក្យ“ហូឡូខសត៍”សំដៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិជ្វីហ្វដែលកើតឡើងក្នុងអំឡុងពេលនៃការកាន់អំណាចរបស់គណបក្សណាហ្ស៊ីអាល្លឺម៉ង់ ក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ(១៩៣៩-១៩៤៥) ។ គណបក្សណាហ្ស៊ីគឺជាគណៈបក្សពលករសង្គមជាតិនិយម ដែលជាអង្គការនយោបាយមួយឡើងកាន់អំណាចនៅអាល្លឺម៉ង់ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៣០ ។ ក្រោមការគ្រប់គ្រងរបស់ អាដុល្ហ៍ អ៊ីត្លែរ (*Adolf Hitler*) គណបក្សណាហ្ស៊ីអាល្លឺម៉ង់បានបើកការវាយប្រហារយ៉ាងខ្លាំងក្លាទៅលើប្រទេសជាច្រើននៅទ្វីបអឺរ៉ុប និងតំបន់ផ្សេងៗទៀតនៅលើពិភពលោក ក្នុងគោលបំណងដើម្បីដណ្តើមយកដីរស់នៅនិងភាពរុងរឿងសម្រាប់ជាតិសាសន៍អាល្លឺម៉ង់ ។ ការប៉ុនប៉ងនេះបានធ្វើឲ្យផ្ទុះឡើងនូវសង្គ្រាមលោកលើកទីពីរ ដែលនៅចុងបញ្ចប់គណបក្សណាហ្ស៊ីអាល្លឺម៉ង់ត្រូវបានផ្តួលរំលំដោយកងកម្លាំងសម្ព័ន្ធមិត្ត (សហរដ្ឋអាមេរិក សហភាពសូវៀត និងចក្រភពអង់គ្លេស) ។ ក្នុងអំឡុងពេលសង្គ្រាម ប្រជាជនទាំងឡាយណាដែលគោរពបូជាលទ្ធិសាសនាជ្វីហ្វត្រូវបានគណបក្សណាហ្ស៊ីចាត់ទុកថាជាប្រជាជនថោកទាបដែលកើតចេញពីពូជសាសន៍ទាបជាងនិងផ្សេងមួយទៀត ។ ដូច្នេះប្រជាជនទាំងនេះត្រូវបានដាក់ឲ្យស្ថិតក្នុងស្ថានភាពអត់ឃ្លានរស់នៅក្នុងសភាពថោកទាបនិងភាពមិនមែនជាមនុស្ស ។ ជាងនេះទៅទៀត ប្រជាជនទាំងនេះរស់នៅក្នុងសភាពជាទាសករ ពលកម្មទទួលទារុណកម្ម និងត្រូវបានសម្លាប់ក្នុងគោលបំណងលុបបំបាត់ចោលពូជសាសន៍ជ្វីហ្វ ។ អំពើទាំងអស់នេះត្រូវបានស្គាល់ថាជា“ហូឡូខសត៍” ដែលត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធ ដោយមានគម្រោងទុកជាមុននិងមានការរៀបចំឡើងយ៉ាងហ្មត់ចត់ ហើយមានការចូលរួមពីប្រជាជន

អាល្លឺម៉ង់សាមញ្ញរាប់ពាន់នាក់ និងប្រជាជនដែលមកពីប្រទេសផ្សេងៗទៀត ។ ជាងនេះទៅទៀត គណបក្សណាហ្ស៊ីអាល្លឺម៉ង់ក៏បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើអ្នកដែលស្រឡាញ់ភេទដូចគ្នា ក្រុមកុលសម្ព័ន្ធ រ៉ូម៉ានិងស៊ីនទីនិងក្រុមអង្គការសាសនាចូហាវ៉ាវីតណេស ។ មានការប៉ាន់ស្មានថា ជនជាតិជ្វីហ្វ៦លាននាក់ និងប្រជាជនសរុប១១លាននាក់ត្រូវបានសម្លាប់នៅក្រោមរបបគណបក្សណាហ្ស៊ី ។

ដោយសម្លឹងមើលទៅក្រោយរយៈពេល៧៣ឆ្នាំនៃជីវិតដ៏វែងរបស់ខ្ញុំ ខ្ញុំអាចកត់សម្គាល់ឃើញនូវបទពិសោធន៍មួយចំនួនតូចដែលដើរតួនាទីយ៉ាងសំខាន់ក្នុងទម្រង់នៃជីវិតរស់នៅរបស់ខ្ញុំ និងការលើកទឹកចិត្តដល់ខ្ញុំមកដល់សព្វថ្ងៃនេះ ។ បទពិសោធន៍មួយក្នុងចំណោមនេះកើតឡើងកាលពីខ្ញុំអាយុបាន១៦ឆ្នាំ ។ នៅពេលនោះ ខ្ញុំបានអង្គុយលេងជាមួយជីតារបស់ខ្ញុំឈ្មោះ អែដវឺត ស្ទីន័រ (Edward Steiner) ហើយបានសុំឲ្យគាត់រៀបរាប់ពីជីវិតរបស់គាត់ក្នុងសម័យហូឡូខសត៍ ។ ព្រឹត្តិការណ៍នេះដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តរីកធំធាត់របស់ខ្ញុំនិងបានជួយបង្កើតទម្រង់អត្តសញ្ញាណសកម្មភាព និងការលើកទឹកចិត្តនាពេលអនាគតសម្រាប់រូបខ្ញុំ ។ ដោយសារអ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យកាន់តែមានវ័យចាស់ យុវជនកម្ពុជាមានទំនាក់ទំនងតិចតួចជាមួយនឹងប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួន ។ ខ្ញុំមើលឃើញតម្រូវការរបស់យុវជនកម្ពុជាក្នុងការស្វែងយល់ពីបទពិសោធន៍របស់ឪពុកម្តាយឬសាច់ញាតិខ្លួននៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ក្នុងគោលបំណងជំរុញឲ្យមានការពិភាក្សាលើប្រធានបទនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលថ្មីនេះ បានចាប់ផ្តើមកម្មវិធីមួយដែលជាផ្នែកមួយនៃគម្រោងប្រវត្តិសាស្ត្ររស់របស់ចាមមូស្លីមដើម្បីបង្រួបបង្រួមប្រជាជនកម្ពុជាពីរជំនាន់ និងលើកទឹកចិត្តដល់យុវជនចាមមូស្លីមនៅទូទាំងប្រទេសឲ្យនិយាយទៅកាន់សមាជិកគ្រួសាររបស់ខ្លួនអំពីបទពិសោធន៍ផ្ទាល់ខ្លួនក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ។

ខ្ញុំតែងតែចងចាំជានិច្ចថា ហូឡូខសត៍ ទោះជាមានឈ្មោះអាក្រក់ក្តីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ ។ ពេលអាយុបានបីឆ្នាំ ខ្ញុំបានបដិសេធមិនព្រមឲ្យគេបោះត្រានៅលើដៃរបស់ខ្ញុំដើម្បីចូលទៅលេងកម្សាន្តនៅក្នុងសួនច្បារទេ ដោយខ្ញុំខ្លាចថា វាមានអត្ថន័យប្រហាក់ប្រហែលនឹងស្នាមសាក់នៅលើដៃជីតារបស់ខ្ញុំធ្វើឡើងនៅអូស្វីចហ្ស៍ (Auschwitz) ដែលជាជំរំប្រមូលផ្តុំធំជាងគេរបស់របបណាហ្ស៊ី ហើយត្រូវបានប្រើសម្រាប់ជាមជ្ឈ-មណ្ឌលបង្ខំឲ្យធ្វើពលកម្មនិងជាអោងចក្រសម្លាប់មនុស្ស ។ មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅក្នុងបំពង់បន្ទប់ផ្សែងពុល ។ នៅក្នុងវ័យវិវត្តធំឡើង ខ្ញុំត្រូវបានធ្វើឲ្យចងចាំនិងផ្តល់ព័ត៌មានអំពីហូឡូខសត៍ ដោយសារតែសៀវភៅនិងកុនអំពីរបបនេះត្រូវបាននាំចូលជាបន្តបន្ទាប់មកក្នុងផ្ទះនិងថ្នាក់រៀន ក៏ដូចជាប្រភពសារ-ព័ត៌មានផ្សេងៗ ដែលក្មេងៗនិងមនុស្សវ័យជំទង់គ្រប់អាយុទាំងអស់អាចមើលបាន ។ ទោះជាខ្ញុំត្រូវបានផ្តល់ព័ត៌មានជាបន្តបន្ទាប់អំពីហូឡូខសត៍ក៏ដោយ ក៏ខ្ញុំនៅតែមិនបានដឹងអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកតាខ្ញុំ ។ ខ្ញុំគ្រាន់តែដឹងថា គាត់ធ្លាប់រស់នៅជំរំប្រមូលផ្តុំអូសស្វីចហ្ស៍ ហើយមានជំនាញវិស្វករទើបគាត់អាចរក្សាជីវិតរបស់គាត់ ។ គាត់នៅតែត្រូវបានរំខានដោយសុបិនអាក្រក់នៃអំពើទាំងឡាយដែលត្រូវបានធ្វើមកលើគាត់ និងអ្វីៗដែលគាត់បានបាត់បង់ ។ ការភ័យខ្លាចថា ការឈឺចាប់ដែលគាត់ទទួលរងនឹងអំពល់ទុក្ខដល់ខ្ញុំ បានធ្វើឲ្យទំនាក់ទំនងរវាងយើងទាំងពីរឃ្លាតឆ្ងាយពីគ្នាពេញរយៈពេលនៃកុមារភាពរបស់ខ្ញុំ ។ ហូឡូខសត៍ប្រៀបបាននឹងដុំពពកខ្មៅមួយដែលព្យួរនៅចន្លោះយើងទាំងពីរ ។ ខ្ញុំសម្លឹងមើលគាត់ដោយក្តីគោរព ប៉ុន្តែក៏ប្រកបដោយការភ័យខ្លាចផងដែរ ។ តើខ្ញុំពិតជាអាចស្វែងយល់ពីអ្វី ដែលគាត់អាចអត់ទ្រាំតស៊ូនៅក្នុងជំរំប្រមូលផ្តុំបានឬ? ខ្ញុំមិនច្បាស់ទេថា ខ្ញុំអាចស្រមៃពីព្រឹត្តិការណ៍ទាំងនោះ ។ ហេតុដូច្នេះ ហើយបានជាខ្ញុំតែងតែនៅឆ្ងាយពីគាត់ ។

នៅឆ្នាំទីពីរនៃថ្នាក់មហាវិទ្យាល័យរបស់ខ្ញុំ ខ្ញុំត្រូវបានតម្រូវឲ្យរៀបចំគម្រោងមួយអំពីថ្នាក់ប្រវត្តិសាស្ត្រពិភពលោក ។ នៅក្នុងគម្រោងនេះ ខ្ញុំត្រូវសរសេរឬបង្កើតអ្វីមួយអំពីហូឡូខសត៍ដោយធ្វើការគូសបង្ហាញអំពីទស្សនវិស័យពីរដោយជ្រើសរើសចេញពីជនរងគ្រោះ អ្នកដែលនៅរស់រានមានជីវិត ជនដៃដល់ អ្នកជួយសង្គ្រោះ អ្នករំដោះ និងអ្នកឈរមើល ។ ខ្ញុំដឹងថាដើម្បីបានពិន្ទុល្អ វាត្រូវការស្រាវជ្រាវឲ្យហ្មត់ចត់នោះ ខ្ញុំមើលឃើញ

ថា គម្រោងនេះគឺជាឱកាសមួយដ៏ល្អបំផុតសម្រាប់សិក្សាស្វែងយល់ពីប្រវត្តិរឿងរ៉ាវលោកតារបស់ខ្ញុំ ។ តាមមើលទៅប្រហែលជាខ្ញុំត្រូវការលេសមួយដើម្បីឲ្យមានអារម្មណ៍កក់ក្ដៅក្នុងការទៅ



លីហ្សាប៉េត និង ជីតារបស់នាង

និយាយជាមួយគាត់ ។ ពេលរសៀលថ្ងៃអាទិត្យមួយ ខ្ញុំបានអង្គុយជាមួយលោកតារបស់ខ្ញុំ ដោយមានសៀវភៅសរសេរនិងប៊ិចនៅក្នុងដៃ ។ ខ្ញុំបានសុំឲ្យគាត់រៀបរាប់ពីបទពិសោធន៍របស់គាត់តាំងពីថ្ងៃដំបូង គឺ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩ ដែលជាថ្ងៃអាល្លឺម៉ង់ឈ្លានពានប្រទេសប៉ូឡូញ ។ គម្រោងនេះ (ដែលខ្ញុំពិតជាធ្វើបានយ៉ាងល្អ) ហាក់ដូចជាមិនទាក់ទងនឹងមេរៀនហើយមិនមានសារសំខាន់ ។ ខ្ញុំចង់ដឹងរឿងរ៉ាវលម្អិតពីបទពិសោធន៍របស់គាត់ ។ ខ្ញុំអង្គុយស្ដាប់គាត់និយាយអស់រយៈពេលជាង៦ម៉ោង ។

លោកតាខ្ញុំបានរៀបរាប់ពីជីវិតរបស់គាត់នៅទីក្រុងក្រាកូ (ដែលជាទីក្រុងធំមួយនៅប្រទេសប៉ូឡូញ) មុនពេលទាហានរបស់របបណាហ្ស៊ីអាល្លឺម៉ង់ចូលឈ្លានពាន ។ ទោះជាមានការកើនឡើងចលនាប្រឆាំងនឹងជនជាតិជ្វីហ្វពីជនជាតិប៉ូឡូញមិនមែនជ្វីហ្វយ៉ាងណាក៏ដោយ ក៏លោកតាខ្ញុំនៅមានទឹកចិត្តសប្បាយរីករាយក្នុងនាមជាវិស្វករក្មេងម្នាក់ដែលនឹងមានអនាគតភ្លឺស្វាង ។ សំឡេងរបស់គាត់បានផ្លាស់ប្ដូរពេលគាត់និយាយដល់រឿងរ៉ាវឈ្លានពានរបស់អាល្លឺម៉ង់ទៅលើប្រទេសប៉ូឡូញ ច្បាប់និងបញ្ញត្តិប្រឆាំងនឹងជនជាតិជ្វីហ្វ បានដាក់កំហិតដល់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់គាត់ដោយសារតែគាត់ជាជនជាតិជ្វីហ្វ ។ គាត់ក៏បាននិយាយអំពីជីវិតរស់នៅក្នុងតំបន់ប្រមូលផ្ដុំ ដែលនៅទីនោះជនជាតិជ្វីហ្វត្រូវបានកាត់ផ្ដាច់ពីជីវិតនៅក្នុងទីក្រុង និងត្រូវបានយាយីដោយជំងឺនិងការអត់ឃ្លាន ។ គាត់សម្លឹងមើលមនុស្សដែលនៅជុំវិញខ្លួនគាត់ដែលត្រូវដកយកទៅបាត់ឬត្រូវដឹកតាមរទេះភ្លើងចេញទៅដែលបន្ទាប់មកត្រូវបាត់ខ្លួន ។ រទេះភ្លើងបានដឹកប្រជាជនទៅកាន់ជំរំសម្លាប់មនុស្សដែលនៅទីនោះ អ្នកទាំងនេះនឹងត្រូវបានសម្លាប់ចោលទាំងអស់ ដោយបំពង់បញ្ចេញផ្សែងពុល ។ ជីតាខ្ញុំត្រូវបានបញ្ជូនទៅជំរំប្រមូលផ្ដុំផ្លាហ្សូដែលស្ថិតនៅក្រៅទីក្រុងក្រាកូ ។ នៅទីនោះ គាត់ត្រូវធ្វើជាទាសករពលកម្មដែលគ្មានថ្ងៃបញ្ចប់ ។ អ្នកទោសនៅទីនោះចាត់ទុកថាមានសំណាងល្អ ប្រសិនបើពួកគេអាចរស់បានលើសពីបួនសប្ដាហ៍ ។ មេបញ្ជាការនៅជំរំនោះឈ្មោះ អាមិន ហ្គូអេថ (Amon Goeth) ត្រូវបានដឹងឮថាបានយកការសម្លាប់ជនជាតិជ្វីហ្វធ្វើជាល្បែង ។ ក្រោយមកគាត់ត្រូវបាននាំទៅកាន់ជំរំពលកម្មមួយទៀត ហើយបន្ទាប់មកគាត់ត្រូវបានបញ្ជូនទៅជំរំប្រមូលផ្ដុំ អូសស្វីចហ្ស៍ដែលនៅទីនោះគាត់ត្រូវបានសាក់លេខរៀងនៅលើដៃ ។ ចាប់ពីពេលនោះមក គាត់លែងជាមនុស្សម្នាក់ទៀតហើយ ។ គាត់គ្រាន់តែជាតួលេខមួយប៉ុណ្ណោះ ។ ជីតាខ្ញុំបានរៀបរាប់អំពីមូលហេតុដែលគាត់អាចរស់រានមានជីវិតបាន ។ បុរសមិនមែនជាជនជាតិជ្វីហ្វម្នាក់បានប្រថុយប្រថានយកម្ហូបបន្ថែមមកឲ្យគាត់ ។ ជាងនេះទៅទៀត ជំនាញរបស់គាត់ជាវិស្វករម្នាក់បានធ្វើឲ្យគាត់កាន់តែមានតម្លៃថែមទៀតសម្រាប់បុព្វហេតុសង្គ្រាមរបស់អាល្លឺម៉ង់ ហើយបានជួយឲ្យគាត់រួចផុតពីការជ្រើសរើសនិងការដឹកយកទៅសម្លាប់ ។ សរុបសេចក្ដីទៅ វាគឺព្រេងសំណាងដែលកំណត់ពីការស្លាប់រស់ ។ ប៉ុន្ដែជីតារបស់ខ្ញុំមិនចាត់ទុកថានេះគឺជាព្រេងសំណាងទេ ។ គាត់និងប្អូនស្រីរបស់គាត់គឺជាមនុស្សពីរនាក់គត់ក្នុងចំណោមសមាជិកគ្រួសារទាំងអស់ដែលនៅរស់រានមានជីវិតពីផែនការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅអឺរ៉ុបរបស់របបណាហ្ស៊ី ។ ទំនាក់ទំនងរបស់ខ្ញុំជាមួយលោកតាខ្ញុំបានផ្លាស់ប្ដូរបន្ទាប់ពីពេលរសៀលនោះមក ។ សភាពខ្មាសរបស់ខ្ញុំត្រូវរលាយ ហើយបាន

ក្លាយទៅជាសេចក្តីស្រឡាញ់។ ខ្ញុំមិនអាចទប់ចិត្តមិនសម្លឹងមើលគាត់ក្នុងសេចក្តីស្ញប់ស្ញែងយ៉ាងខ្លាំង ដែលគាត់អាចរួចរស់ជីវិតបាន។ ឥឡូវនេះខ្ញុំមានអារម្មណ៍ជិតស្និទ្ធជាមួយគាត់ដែលជាចំណងមួយបង្កើតឡើងនៅថ្ងៃដែលខ្ញុំសម្ភាសន៍គាត់។ ទោះបីជាខ្ញុំមិនអាចក្លាយជា «ក្មេងស្រីតូច» របស់ជីតាខ្ញុំដូចបងប្អូនស្រីខ្ញុំក៏ដោយ ក៏ខ្ញុំចាត់ទុកទំនាក់ទំនងរបស់យើងទាំងពីរមានលក្ខណៈពិសេសណាស់។

សម្លឹងមើលទៅបុរសចាស់ម្នាក់អាយុ៨៦ឆ្នាំដែលរួចរស់ជីវិតពីការរត់ឃ្លាន ការដកហូតសិទ្ធិ ការវាយធ្វើបាប និងជំងឺក៏ដូចជារោគមហារីកនាពេលបច្ចុប្បន្ន ខ្ញុំមើលឃើញគាត់ជាមនុស្សម្នាក់ដែលមាំទាំ និងប្រកបដោយការលើកទឹកចិត្ត។

និយាយទៅកាន់ជីតារបស់ខ្ញុំ មិនត្រឹមតែតភ្ជាប់ទំនាក់ទំនងរវាងខ្ញុំនិងគាត់ប៉ុណ្ណោះទេ ថែមទាំងតភ្ជាប់ទៅនឹងប្រវត្តិគ្រួសាររបស់ខ្ញុំនិងជនជាតិជ្វីហ្វដទៃទៀត។ ខ្ញុំដឹងខ្លួនថា ទោះជាយ៉ាងណាក្តី ខ្ញុំគឺជាផលិតផលរបស់ហូឡូខស្ត។ ខ្ញុំនឹងមិនអាចចាប់កំណើតបានទេ ប្រសិនបើហូឡូខស្តមិនបានកើតឡើង ហើយខ្ញុំបានចាត់ទុកហេតុការណ៍នេះជាផ្នែកមួយនៃខ្លួនរបស់ខ្ញុំ គឺជាអ្វីដែលជាឈាមជ័ររបស់ខ្ញុំ។ ទំនាក់ទំនងរបស់ខ្ញុំទៅនឹងសាសនាជ្វីហ្វត្រូវបានកំណត់ឡើងវិញ ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំមានទំនាក់ទំនងជាមួយសាសនារបស់ខ្ញុំនៅក្នុងផ្លូវថ្មីមួយទៀតនិងបានក្លាយជាសាក្សីមួយនៃអំពើហូឡូខស្តនិងប្រវត្តិរឿងរ៉ាវរបស់គាត់។ ដូច្នេះ វាគឺជាតួនាទីរបស់ខ្ញុំក្នុងការធានាឲ្យបានថា ការចងចាំអំពីហូឡូខស្តនឹងមានជីវិតនៅបន្តយូរអង្វែងទៀត បន្ទាប់ពីជីតារបស់ខ្ញុំនិងអ្នករស់រានមានជីវិតពីហូឡូខស្តស្លាប់បាត់ទៅ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវតែធ្វើអ្វីៗគ្រប់បែបយ៉ាងដែលអាចធ្វើបាន ដើម្បីធានាឲ្យបានថាពាក្យ «នឹងមិនមានម្តងទៀត» និងមានអត្ថន័យពិតប្រាកដ។ ពាក្យនេះត្រូវបាននិយាយម្តងហើយម្តងទៀតចាប់តាំងពីអំពើប្រល័យពូជសាសន៍កើតមកលើជនជាតិជ្វីហ្វនៅពេលដែលអំពើប្រល័យពូជសាសន៍បានកើតឡើងម្តងហើយម្តងទៀត។ ដោយបានដឹងអំពីលោក អូស្កា ឈីនដឹល័រ *(Oscar Schindler)* ជាជនជាតិអាល្លឺម៉ង់មិនមែនជ្វីហ្វម្នាក់ដែលបានជួយសង្គ្រោះជនជាតិជ្វីហ្វរាប់រយនាក់នៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ខ្ញុំត្រូវបានលើកទឹកចិត្តដោយពាក្យពេចន៍នៅក្នុងគម្ពីរគួរអាននិងគម្ពីរតាល់មុដ *(Talmud)* ជាគម្ពីររបស់សាសនាជ្វីហ្វ ដែលបានចែងថា «អ្នកដែលជួយសង្គ្រោះជីវិតមនុស្សម្នាក់ប្រៀបបានសង្គ្រោះពិភពលោកទាំងមូល»។ ខ្ញុំបានសិក្សាមេរៀនជាច្រើនពីអំពើប្រល័យពូជសាសន៍និងអំពើហិង្សានៅសាកលវិទ្យាល័យ ហើយគឺជាមេដឹកនាំម្នាក់របស់ក្រុមមួយដែលធ្វើការដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែលកំពុងតែរីកឡើងជាបន្តនៅតំបន់ដាហ្វួរប្រទេសស៊ូដង់។ ពេលវិសមកាលនារដូវក្តៅឆ្នាំមុន ខ្ញុំបានចំណាយពេលធ្វើការជាមួយជនភៀសខ្លួន និងអ្នកនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍នៅប្រទេសអ៊ូហ្គង់ដា ហើយមានបំណងចង់ដាក់ពាក្យស្នើសុំថវិកាដើម្បីសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា សម្រាប់ឆ្នាំ២០០៨នេះ បន្ទាប់ពីទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកសិទ្ធិមនុស្សពីសាលាសេដ្ឋកិច្ចនៅទីក្រុងឡុងដ៍ គឺដោយសារតែជីតារបស់ខ្ញុំ ធ្វើឲ្យខ្ញុំធ្វើដំណើរពីសហរដ្ឋអាមេរិកមកប្រទេសកម្ពុជាដើម្បីធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។

ការនិយាយទៅកាន់ជីតារបស់ខ្ញុំ ពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ខ្លួនឯងនិងអត្ត-សញ្ញាណផ្ទាល់ខ្លួន។ វាបានផ្លាស់ប្តូររបៀបដែលខ្ញុំកំណត់និយមន័យខ្លួនឯងក្នុងនាមជាបុគ្គលម្នាក់ក្នុងនាមជាជនជាតិជ្វីហ្វម្នាក់និងជាសមាជិកម្នាក់នៃសង្គមពិភពលោក ដែលបានជំរុញឲ្យខ្ញុំទៅកាន់គោលដៅនិងការលើកទឹកចិត្តថ្មីមួយទៀត។ ដើម្បីទទួលស្គាល់ពីសារសំខាន់នៃការនិយាយទៅកាន់ជីតាខ្ញុំ ខ្ញុំមើលឃើញពីសារសំខាន់សម្រាប់យុវជនកម្ពុជាក្នុងការសម្តែងចេញប្រហាក់ប្រហែលគ្នា និងនិយាយទៅកាន់មនុស្សជំនាន់មុនអំពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម។ ពេលមកដល់ប្រទេសកម្ពុជាជាញឹកញយខ្ញុំត្រូវបានប្រាប់ថា យុវជនមានការយល់ដឹងតិចតួចណាស់អំពីរបបខ្មែរក្រហមនិងសង្គ្រាមស៊ីវិលនៅកម្ពុជា។ សម្រាប់ហេតុផលនយោបាយនិងហេតុផលវប្បធម៌ជាច្រើន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមិនត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅសិក្សាទេ ហើយយុវជនកម្ពុជាមិនមានលទ្ធភាពអាចស្វែងរកមើលកុនឬសៀវភៅរឿងពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ដូចដែលខ្ញុំអាចធ្វើបានពីអំពើប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វនោះទេ ។ ជាងនេះទៅទៀត ប្រជាជនចាស់ៗនៅកម្ពុជាមិនសូវជាបានចែករំលែកអំពីបទពិសោធន៍ផ្ទាល់ខ្លួន ដូចអ្នកនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វទេ ។ ដូច្នេះ ក្មេងកម្ពុជាជំនាន់ក្រោយត្រូវតែចូលរួមនៅក្នុងផ្នែកនេះនៃប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការស្វែងរករឿងរ៉ាវពីបងប្អូនឪពុកម្តាយខ្លួន ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាមផ្សារភ្ជាប់យុវជនកម្ពុជាទៅនឹងផ្នែកដ៏សំខាន់នៃប្រវត្តិសាស្ត្រកម្ពុជា ដោយផ្អែកលើមធ្យោបាយជាច្រើនរួមមានកម្មវិធីយុវជនស្ម័គ្រចិត្ត ការប្រជុំពិភាក្សាព័ត៌មាន និងដំណើរទស្សនកិច្ចរបស់យុវជនមកភ្នំពេញដើម្បីទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាកន្លែងកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ យុវជនដែលខ្ញុំបានជួបនិយាយលេងក្នុងដំណើរទស្សនកិច្ចថ្មីៗកន្លងមកនេះដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រាប់ខ្ញុំអំពីការភ័យខ្លាចនៅពេលបានឃើញមន្ទីរស-២១ ដោយផ្ទាល់ភ្នែកនិងការពិតនៃរបបខ្មែរក្រហម ។ ក្នុងពេលថ្មីៗនេះ បុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសៀវភៅពិគ្រោះសម្រាប់សិក្សាអំពីប្រវត្តិសាស្ត្រនៅតាមសាលារៀន ។ សៀវភៅនេះត្រូវបានអនុញ្ញាតឲ្យបោះពុម្ពផ្សាយ ដោយរាជរដ្ឋាភិបាលកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងបោះពុម្ពសៀវភៅនេះមួយលានក្បាលដើម្បីចែកចាយទៅតាមសាលានិងកម្មវិធីសិក្សាអប់រំនៅទូទាំងប្រទេស ។

ទោះបីជាមានជោគជ័យច្រើនយ៉ាងនេះក៏ដោយ កិច្ចការទាំងអស់នេះមិនទាន់គ្រប់គ្រាន់ទេ ។ ទោះបីជាខ្ញុំមានលទ្ធភាពទទួលបានព័ត៌មានយ៉ាងច្រើនពីអំពើប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វយ៉ាងណាក៏ដោយ ក៏បទពិសោធន៍ដែលខ្ញុំនិយាយជាមួយជីតារបស់ខ្ញុំនោះបានផ្តល់ព័ត៌មាននិងកំណត់និយមន័យថ្មីសម្រាប់ជីវិតរបស់ខ្ញុំ ។ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងជួយជំរុញឲ្យយុវជនចាមមូស្លីមស្វែងរកព័ត៌មានផ្ទាល់ខ្លួនពីសមាជិកគ្រួសាររបស់ខ្លួន ។

នៅក្រោមគម្រោងសម្រាប់យុវជនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យុវជនចាមមូស្លីមនៅតាមបណ្តាខេត្តផ្សេងៗជាច្រើនទៀត ត្រូវបានផ្តល់ឲ្យនូវកូនសៀវភៅនិងប៊ិច និងត្រូវបានប្រាប់ឲ្យនិយាយទៅកាន់ឪពុកម្តាយឬបងប្អូនអំពីបទពិសោធន៍របស់អ្នកទាំងនេះក្នុងរបបខ្មែរក្រហម ។ យុវជនទាំងនេះត្រូវបានស្នើឲ្យសរសេររឿងរ៉ាវរបស់សមាជិកគ្រួសារដោយខ្លួនគេផ្ទាល់ ដោយសរសេររៀបរាប់រាល់ចំណុចនៃបទពិសោធន៍ទាំងឡាយដែលគាត់ចង់និយាយ ហើយរួមបញ្ចូលប្រតិកម្មផ្ទាល់ខ្លួនថា តើយុវជនទាំងអស់នេះមានអារម្មណ៍យ៉ាងណាបន្ទាប់ពីបានដឹងពីបទពិសោធន៍នៃអ្នកដែលជាទីស្រឡាញ់របស់ខ្លួន ។ អ្នកចូលរួមត្រូវបានជំរុញឲ្យបញ្ចេញនូវចំណេះដឹងដែលខ្លួនមាននិងគំនិតបង្កើតថ្មីដែលពួកគេអាចធ្វើទៅបាននៅក្នុងសំណេររបស់ខ្លួន ។ បន្ទាប់មកមជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការត្រួតពិនិត្យទៅលើសំណេរទាំងនោះនិងជ្រើសរើសសំណេរចំនួន១០ដើម្បីទទួលស្គាល់ស្នាដៃ ។ អ្នកដែលជាប់ស្នាដៃនឹងទទួលបានដំណើរមកទីក្រុងភ្នំពេញដើម្បីចូលរួមក្នុងពិធីទទួលរង្វាន់លើកទឹកចិត្ត ហើយសំណេរនេះនឹងត្រូវបានចុះផ្សាយនៅក្នុងទស្សនាវដ្តីសម្រាប់សហគមន៍ចាមប្រចាំត្រីមាស ។ អ្នកទទួលជ័យលាភីនឹងទទួលបានទស្សនាវដ្តីដោយឥតគិតថ្លៃនិងប័ណ្ណសរសើរចំពោះស្នាដៃរបស់ខ្លួនផងដែរ ។

សូមបញ្ជូនសំណេរមកមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យបានមុនថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ។ ជ័យលាភីនឹងត្រូវបានប្រកាសនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ ហើយពិធីប្រកាសរង្វាន់នឹងប្រព្រឹត្តទៅឡើងនៅទីក្រុងភ្នំពេញក្នុងខែធ្នូ ឆ្នាំ២០០៧ ។

ទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើពិធីទទួលស្គាល់ពិសេស សម្រាប់ស្នាដៃដែលល្អជាងគេតែ១០ក្តី ក៏អ្នកចូលរួមសរសេរផ្សេងទៀតនឹងទទួលបាននូវរង្វាន់ដែលមិនចេះសាបសូន្យ ។ នោះគឺការផ្សារភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសារនិងទទួលបាននូវចំណេះដឹងដ៏ប្រសើរអំពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាតែឯងមិនអាចផ្សារភ្ជាប់មនុស្សពីរជំនាន់ខុសគ្នាបានទេ ។ វាគឺជាកាតព្វកិច្ចរបស់យុវជនកម្ពុជាក្នុងការធ្វើជាសាក្សីនូវអ្វីដែលបានកើតឡើងនិងរក្សាការចងចាំអំពី

របបកម្ពុជាប្រជាធិបតេយ្យ ។

ពេលខ្លះ ខ្ញុំមានការឆ្ងល់ថា តើជីវិតរបស់ខ្ញុំនឹងទៅជាយ៉ាងម៉េច ប្រសិនបើខ្ញុំមិនបាននិយាយជាមួយជីតារបស់ខ្ញុំនៅថ្ងៃនោះ គឺនៅពេលខ្ញុំមានអាយុ១៦ឆ្នាំ ។ លទ្ធភាពដែលខ្ញុំនឹងក្លាយទៅជាមនុស្សរបៀបណានោះគឺមានច្រើនរាប់មិនអស់ ។ ប៉ុន្តែខ្ញុំមិនបានជ្រើសរើសយកការរស់នៅ"តើវានឹងទៅជាយ៉ាងម៉េច...ប្រសិនបើ..." របៀបនេះទេ ហើយងាកមកគិតអំពីអនាគត ដូចជាការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ការសិក្សានៅសាកលវិទ្យាល័យ និងតទៅមុខទៀត ។ ខ្ញុំគិតអំពីការចងចាំអតីតកាលពីអ្នកទាំងឡាយដែលបានស្លាប់ក្នុងរយៈកាលនៃអំពើហួសហេតុនិងអំពើប្រល័យពូជសាសន៍ផ្សេងៗទៀត ហើយនិងជួយធ្វើយ៉ាងណាដើម្បីធានាឲ្យបានថា អំពើប្រល័យពូជសាសន៍នឹងមិនកើតឡើងទៀតទេនាពេលអនាគត ។ ខ្ញុំគិតអំពីអ្វីដែលខ្ញុំអាចធ្វើបានដើម្បីជួយសង្គ្រោះជីវិតមនុស្សសូម្បីតែម្នាក់ក្តី ។ ខ្ញុំគិតថានឹងធ្វើឲ្យជីតារបស់ខ្ញុំមានមោទនភាពចំពោះរូបខ្ញុំ ។

**លីហ្សាប៊េត ម៉ៃយើរ**

## ព័ត៌មាន

ប្រសិនបើអ្នកចង់ចូលរួមនៅក្នុងគម្រោងនេះ ឬត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោងប្រវត្តិសាស្ត្រ ដែលមានអ្នកសម្របសម្រួល សូ ហ្វារីណា តាមរយៈអ៊ីម៉ែល *frnso@yahoo.com* ឬតាមរយៈទូរស័ព្ទលេខ ០១២ ៩៦៧ ៥៦៥ ឬ ០២៣ ២២១ ១៦៥ ។

## ពាក្យស្លោកខ្មែរក្រហម

**◆ កម្ចាត់របៀបរបបដឹកនាំ និងធ្វើការខ្ជះខ្ជាយមាយាយើករយាកប៉ាតណាប៉ាតណីប្រថុយប្រថានគ្មានស្មារតីទទួលខុសត្រូវជាដាច់ខាត។**

**◆ កម្ចាត់គោលជំហរអនុធន នាយទុន សក្តិភូមិ ព្រមទាំងកសិករនិងសិប្បករ ហើយចំពាក់និងពង្រឹងគោលជំហរអធនរបស់បក្សជាដាច់ខាត។**

## រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

**មហាសន្និបាតជាតិលើកទី៣អនុម័តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៧៥ ប្រកាសប្រើជាផ្លូវការនៅថ្ងៃ៥ ខែមករា ឆ្នាំ ១៩៧៦**

### ជំពូក៣ : អំពីវប្បធម៌

**មាត្រា៣**

វប្បធម៌របស់ប្រទេសកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជាតិប្រជាជន និងចម្រើនស្អាតស្អំ ដើម្បីបម្រើភារកិច្ចការពារប្រទេសនិងកសាងប្រទេសកម្ពុជាឲ្យបានរុងរឿងសម្បូរសប្បាយ ។ វប្បធម៌ថ្មីនេះប្រឆាំងដាច់ខាតនឹងវប្បធម៌ពុករលួយប្រតិកិរិយារបស់វណ្ណៈជិះជាន់ផ្សេងៗ និងរបស់អាណានិគមនិយមចក្រពត្តិនិយមនៅកម្ពុជា ។

### ជំពូក៩ : អំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាជនកម្ពុជាម្នាក់ៗ

**មាត្រា១២**

ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជីវភាពពេញទីខាងសម្ភារៈខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឲ្យរីកចម្រើនកាន់តែខ្ពស់ឡើងជានិច្ច ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែត្រូវបានធានាអះអាងខាងជីវភាពទាំងអស់ ។

- ◆ កម្មករគ្រប់រូបជាម្ចាស់រោងចក្រ
- ◆ កសិករគ្រប់រូបជាម្ចាស់ស្រែចម្ការ
- ◆ ពលករផ្សេងទៀតមានសិទ្ធិមានការងារធ្វើទាំងអស់

ភាពគ្មានការងារធ្វើមិនមានដាច់ខាតក្នុងកម្ពុជាប្រជាធិបតេយ្យ ។

### ជំពូក១៥ : សិទ្ធិខាងជំនឿនិងសាសនា

**មាត្រា២០**

ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនជឿជំនឿអ្វី ឬមិនជឿសាសនាណាក៏បាន ។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជាដាច់ខាត ។

**(ដកស្រង់ចេញពីឯកសារខ្មែរក្រហម)**

# ជនជាតិចាមបានីនៅប្រទេសវៀតណាម

ច្បាប់អ៊ីស្លាមសម្រាប់ជនជាតិចាមបានីពុំសូវមានលក្ខណៈតឹងរ៉ឹងប៉ុន្មានទេ ។ អ្នកមានឋានៈខ្ពស់ៗខាងសាសនាបានចាក់ស្រាក្នុងប៉ាន់តែមួយដើម្បីធ្វើឲ្យគេជឿថា ពួកគេកំពុងផឹកតែ ។ ប៉ុន្តែតាមការពិតគឺជាសុរាសោះ ។

ផ្សៀន វ៉ាន់ទី ជាចាមបានី “បានី មានន័យថាកូនប្រុសរបស់ព្យាការីដែលជាតំណាងរបស់ព្រះ” បានរៀបរាប់ពីការប្រណិប័តន៍សាសនារបស់គាត់ ។ លក្ខណៈពិសេសនេះគ្រាន់តែជាការប្រព្រឹត្តបំពានមួយក្នុងចំណោមការប្រព្រឹត្តបំពានជាច្រើនចំពោះក្បួនតម្រារបស់អ៊ីស្លាមដែលប្រតិបត្តិដោយជនជាតិចាមមួយក្រុមដែលមានមនុស្សប្រមាណជា១សែននាក់ប៉ុណ្ណោះ ។ អ្នកទាំងនេះរស់នៅតាមជម្រាលភ្នំភាគអាគ្នេយ៍ប្រទេសវៀតណាមក្នុងខេត្តធិញធន់និងបិញធន់ ។ ពួកចាមទទួលស្គាល់សាសនាអ៊ីស្លាមមួយដែលមានលក្ខណៈប្លែកដោយសារសេរីភាពក្នុងការបកស្រាយពីកាតព្វកិច្ចរបស់ខ្លួនខាងផ្នែកសាសនាដូចមាននិយាយណែនាំក្នុងសាសនាអ៊ីស្លាមភាគច្រើនដែលប្រកាន់តាមគម្ពីរដែរ ។

## ជនជាតិចាមនៅប្រទេសវៀតណាម

ក្នុងពេលដែលជនជាតិចាមនៅប្រទេសកម្ពុជាមានជាង៥កន្លះលាននាក់ នៅប្រទេសវៀតណាមជនជាតិចាមមានមិនដល់១សែននាក់ផង ហើយរស់នៅក្នុងភូមិចំនួន៣៦ ។ ជនជាតិចាមមានដើមកំណើតអូស្ត្រូណេស៊ីយាង ដូចប្រជាជនឥណ្ឌូនេស៊ី ម៉ាឡេស៊ីនិងហ្វីលីពីនពួកគេត្រូវរាប់បញ្ចូលចូលក្នុងចំណោមជាតិសាសន៍ ភាសាខាងពិភពម៉ាឡេ ។ ជនជាតិចាមមានដើមកំណើតនៅចម្ប៉ាជាព្រះរាជាណាចក្រចំណាស់មួយដែលកើតមានរូបរាងនៅចុងទសវត្សរ៍ទី២នៃសករាជនិងធ្វើឲ្យមានលក្ខណៈឥណ្ឌានៅសតវត្សរ៍ទី៧ ។ ចម្ប៉ាលាតសន្ធឹងលើចំណែកទាំងអស់នៅភាគខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្ន ។ នៅពេលធ្វើសង្គ្រាមចាប់ពីសតវត្សរ៍ទី១១ជាមួយប្រទេសជិតខាងភាគខាងជើងរបស់ខ្លួនគឺ ព្រះរាជាណាចក្រដាយវៀត ប្រវត្តិសាស្ត្ររបស់ចម្ប៉ាក្លាយទៅជាប្រវត្តិសាស្ត្រនៃការបាត់បង់ទឹកដីរបស់ខ្លួនជាលំដាប់លំដោយរហូតដល់ការរលាយបាត់ទាំងស្រុងនៅឆ្នាំ១៨៣៥ ។ ការភ្ជាប់ទឹកដីរបស់កងទ័ពវៀតណាមដែលដណ្តើមការត្រួតត្រាព្រះរាជាណាចក្រជាបន្តបន្ទាប់ បានស្គាល់នូវរបត់ប្រកបដោយគ្រោះថ្នាក់មួយនៅឆ្នាំ១៤៧១ ជាមួយនឹងការវិនាសរបស់រាជធានីវិជ័យ ។ ប៉ុន្តែប្រទេសបានបន្តនៅមានអត្ថិភាពដោយការផ្លាស់ប្តូររាជធានីរបស់ខ្លួនមកភាគត្បូង ។ នៅឆ្នាំ១៨៣៥ នគរចម្ប៉ាបានរលាយបាត់ក្នុងឋានៈជារដ្ឋស្វយ័តមួយ ប៉ុន្តែជនជាតិចាមមិនរលាយបាត់រូបទេ ។ សព្វថ្ងៃនេះ ចំនួននៃជនជាតិចាមបានកើនឡើងនៅខាងត្បូងគឺភាគដែលលយចេញនៃអតីតនគរចម្ប៉ាដែលបង្រួមមកត្រឹមដែនដីនៃអតីតក្សត្រប្រទេសប៉ង់ឌុយរ៉ង់ហ្គា ទីក្រុងនានាដូចជា ផាន់រ៉ាង ផាន់រីនិងផាន់ធៀត (បណ្តាខេត្តរបស់វៀតណាមគឺ និញធន់និងបិញធន់) ជាដើម ។

## ការខ្វែងគំនិតគ្នាស្តីពីពិធីផ្សេងៗ

ជនជាតិចាមបានីបានបំបាត់ជំនឿសាសនាពីកាតព្វកិច្ចផ្សេងៗរបស់ខ្លួន ។ ក្នុងសាសនាអ៊ីស្លាមស៊ុននី ដែលភាគច្រើនគឺពុំមានបព្វជិតទេ ។ សាសនាទាំងអស់មានលក្ខណៈស្មើភាពគ្នា ។ ចំណែកឯជនជាតិចាមបានីក៏ដូចពួកស៊ីអ៊ីតដែរ សាសនាត្រូវបានគ្រប់គ្រងដោយថ្នាក់ដឹកនាំសាសនាមួយក្រុមដែលគេហៅថាអាចារ្យស្លៀកពាក់ស ដូតឈ្នួតក្បាលលំអដោយរំយោលពណ៌ក្រហម ។ មានតែអាចារ្យប៉ុណ្ណោះដែលអាចអានគម្ពីរគួរអានដែលចម្លងឡើងវិញតាមភាសាអារ៉ាប់មួយដែលបំភ្លៃខុសពីសភាពដើម ។ ការផ្សាយឲ្យដឹងព្ទរបស់ខ្លួនក៏ត្រូវហាមឃាត់ផងដែរ ពីព្រោះសាសនាអ៊ីស្លាមរបស់ចាម គឺផ្អែកលើការសម្ងាត់និងបម្រុងទុកសម្រាប់តែអ្នកចេះដឹងជ្រៅជ្រះជាអាចារ្យប៉ុណ្ណោះ ។ ដោយហេតុនេះ វាឃ្លាតឆ្ងាយពីគំរូរបស់មនុស្សភាគច្រើនដែលម្នាក់ៗមានសិទ្ធិក្នុងការអាននិងស្វែងយល់ពីគម្ពីរគួរអាន ។

ជនជាតិចាមបានីមិនអនុវត្តការថ្វាយបង្គំព្រះ៥ដងក្នុងមួយថ្ងៃទេ ។ គេថ្វាយបង្គំព្រះនិងសូត្រធម៌មួយដងក្នុងមួយខែ ឬសូត្ររៀងរាល់ថ្ងៃសុក្រ ។ នេះជាការបញ្ជាក់របស់ ទុយ កុងដាត់ ជាអាចារ្យនៅភូមិវ៉ាន់ឡាម ។ អាចារ្យដឹកនាំការសូត្រធម៌ ហើយការសូត្រធម៌របស់គេស្ថិតលើការក្រាបថ្វាយបង្គំឆាប់រហ័សនិងការបន្ទន់ជង្គង់ ។ ចំណែកជនជាតិចាមបានីធម្មតាប្រតិបត្តិការសូត្រធម៌តែក្នុងពេលយប់នៃថ្ងៃបុណ្យរ៉ាម៉ាឌនប៉ុណ្ណោះដោយដាក់ខ្លួនទាំងមូលផ្ទាល់ដីដើម្បីក្រាបថ្វាយបង្គំ ។


កន្លែងបញ្ចុះសាកសពរបស់ស្ត្រីចាមបានី

ចំពោះបុណ្យរ៉ាម៉ាឌនគឺមានតែអាចារ្យប៉ុណ្ណោះដែលត្រូវបំពេញភារកិច្ចនេះ ។ ក្នុងអំឡុងខែរ៉ាម៉ាឌន ជនជាតិចាមលាក់ខ្លួនក្នុងផ្ទះមិនចេញទៅណាទេ ដោយតមអាហារនិងដេកនៅក្នុងវិហារអ៊ីស្លាមតង់គី និងប្រតិបត្តិការសូត្រធម៌៥ដងក្នុងមួយថ្ងៃ ។ ចំណែកប្រជាជនមិនហូបអាហារតែ៣ថ្ងៃប៉ុណ្ណោះ ។ ដូចការសូត្រធម៌ដែរ អាចារ្យប្រតិបត្តិពិធីបុណ្យរ៉ាម៉ាឌនដើម្បីផលប្រយោជន៍សាសនិករបស់ខ្លួន ។ ប៉ុន្តែអ៊ីស្លាមគឺជាសាសនាមួយដែលមានលក្ខណៈរួម ដែលការចូលរួមរបស់មនុស្សម្នាក់ៗចំពោះការប្រតិបត្តិពិធីផ្សេងៗមានលក្ខណៈស្អិតល្មួត ។ អាចារ្យបញ្ឈប់ការតមអាហារពីរម៉ោងមុនព្រះអាទិត្យអស្តង្គត ។ ទោះបីដឹងថា នេះជាទង្វើមួយដែលខុសពីវិន័យសាសនាអ៊ីស្លាមក៏ដោយ ។

ដើម្បីបំភ័ន្តការបរិភោគក្នុងទីងងឹត អ្នកទាំងនោះនាំគ្នាបិទទ្វារនិងបង្អួចវិហារដើម្បីឲ្យមើលទៅថាដល់ពេលស្រាយបួស និងដក់បារីមួយដើមដែរដើម្បីរង់ចាំស្រាយបួស ។ កាតព្វកិច្ចចំនួនពីរចុងក្រោយគឺហ្សាកាត់ (ការធ្វើទាន) ត្រូវបានគោរពធ្វើតាម ប៉ុន្តែគ្មានអ្នកណាម្នាក់បំពេញធម្មយាត្រាបានទេ ដោយសារគ្មានមធ្យោបាយឬការឧបត្ថម្ភផ្សេងៗ ។ ការប្រតិបត្តិផ្សេងៗទៀតដែលជនជាតិចាមបានីពុំគ្រាប់តាម ដូចជាការកាត់ស្បែកចុងលិង្គ ។ អ្នករៀបចំពិធីនេះគ្រាន់តែធ្វើកាយវិការរបៀបកាត់ស្បែកអង្គជាតិបុរសប៉ុណ្ណោះ ។ ទុយ កុងដាត់ បញ្ជាក់ថា "ការកាត់ស្បែកអង្គជាតិគឺជាពិធីបុណ្យអឹកធឹកមួយដែលក្នុងអំឡុងពេលនោះគេប្រើប្រាស់កាំបិតមួយឬឫស្សីមួយដើមដើម្បីធ្វើជានិមិត្តរូបឧបកិច្ច តែប៉ុណ្ណោះ" ។ ជនជាតិចាមបានីមិនសូវតឹងរ៉ឹងក្នុងការបរិភោគអាហារដែលសាសនាអ៊ីស្លាមហាមឃាត់ទេ ។ ង្វៀន វ៉ាន់ទី ជាជនជាតិចាមនៅភូមិភួកញ៉ូនបាននិយាយថា "ចាមបានីមិនដែលហូបសាច់ជ្រូកនៅផ្ទះរបស់ខ្លួនទេ ប៉ុន្តែពេលដែលពួកគេស្ថិតនៅក្នុងភូមិមួយផ្សេងទៀត ទើបពួកគេបរិភោគដោយស្ងាត់កំបាំង ។ ការមិនប្រកាន់ទោសនេះក៏ត្រូវអនុវត្តចំពោះការផឹកសុរាផងដែរ ដូចដែលអាចារ្យ ទុយ កុងដាត់ រៀបរាប់ពីរឿងនេះថា នៅខាងក្រៅផ្ទះគេអាចផឹកស្រាបានគឺពុំមានការដាក់ទណ្ឌកម្មទេ ។ ប៉ុន្តែបើអ្នកណាម្នាក់ស្រវឹង អ្នកនោះពុំអាចចូលរួមពិធីបុណ្យបានទេ" ។

ប៉ុន្តែ គេមិនត្រូវប្រកាន់ចាមបានីថា មិនដឹងច្បាប់គោលរបស់សាសនាអ៊ីស្លាមបានឡើយ ។ អ្នកទាំងនោះយល់ពីច្បាប់សារីអះដែលជាច្បាប់ដ៏ពិសិដ្ឋរបស់សាសនាអ៊ីស្លាម ។ ឧទាហរណ៍

ទំនាក់ទំនងស្នេហាមុនការរៀបអាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ និងត្រូវរងការធ្វើទារុណកម្មដោយវាយ ១០០រំពាត់ឬផ្តៅ ។ ទោសនេះត្រូវបណ្តាប្រទេសកាន់សាសនាអ៊ីស្លាមដែលអនុវត្តច្បាប់គ្រឹះសារីអះធ្វើការទាមទារជាលើកដំបូងបំផុត ។ ប៉ុន្តែការផ្តន្ទាទោសនេះត្រូវបានបន្ធូរបន្ថយក្នុងចំណោមជនជាតិចាមបានី ។ ទុយ កុងដាត់ អះអាងថា "ពួកយុវជនដែលមានទំនាក់ទំនងស្នេហាមុនការរៀបការរបស់ខ្លួនសុទ្ធតែត្រូវដាក់ទណ្ឌកម្ម ។ កាលបើគេសម្គាល់ឃើញពីការបាត់ភាពបរិសុទ្ធ គេរៀបចំពិធីជួបជុំគ្នាមួយ ហើយអ្នកដែលធ្វើខុសត្រូវទទួលការវាយដំ ។ ប៉ុន្តែពុំមែនជាមួយផ្តៅនិងរំពាត់ទេ គឺជាមួយនឹងម្រាមដៃ" ។ ទុយ កុងដាត់ ធ្វើកាយវិការដោយការរលាស់ចង្អុលដៃរបស់គាត់ទាំងសើចញឹមៗ ។

ចំពោះការជិតក្បត់ចិត្តស្វាមីឬភរិយា បាបកម្មមួយក្នុងចំណោមបាបកម្មធ្ងន់ធ្ងរបំផុតក្នុងច្បាប់សាសនាអ៊ីស្លាមគឺទាមទារឲ្យដាក់ទោសចំពោះគូសង្សារទាំងពីរ ។ ទុយ កុងដាត់ បានសម្តែងឲ្យឃើញជាថ្មីម្តងទៀតថា "ក្នុងករណីដែលអាចារ្យម្នាក់មានទំនាក់ទំនងជាមួយស្ត្រីមានប្តី គឺទី១) អាចារ្យនោះត្រូវដកហូតពីមុខតំណែង ទី២) ត្រូវតែរៀបចំពិធីមួយដើម្បីលាងជម្រះបាបកម្មបន្ទាប់មកទើបអាចារ្យនោះអាចទទួលតំណែងឡើងវិញ" ។

## ជនជាតិចាមបានីដែលចាត់ទុកស្ត្រីជាធំ

ឥទ្ធិពលនៃស្ត្រីក្នុងពិធីបុណ្យផ្សេងៗគឺមានលក្ខណៈខុសពីធម្មតា ។ ស្ត្រីចាមបានីភាគច្រើនធ្វើដំណើរទៅកាន់ព្រះវិហារដោយគ្មានទទូរក្រណាត់បាំងមុខ ។ ពិតណាស់ពួកអ្នកមានបណ្តាសក្តិធំៗសុទ្ធតែជាបុរស ប៉ុន្តែគឺស្ត្រីទេដែលជាអ្នកបំពេញពិធីផ្សេងៗខាងសាសនាដូចជាការឲ្យទាននិងក្រាបថ្វាយបង្គំព្រះ ។ ក្នុងវិហារអ៊ីស្លាមជាច្រើន បុរសចាមបានីមួយចំនួនតូចប៉ុណ្ណោះ លើកលែងតែបុរសដែលមានមុខមាត់ក្នុងភូមិ ដែលធ្វើដំណើរទៅធ្វើបុណ្យរ៉ាម៉ាឌន សូត្រធម៌ និងថ្វាយបង្គំ រៀងរាល់យប់ ។ អ្នកទាំងនេះបង្ហាញភ័ស្តុតាងឲ្យឃើញពីវិសមតានេះដោយហេតុថាស្ត្រីគឺជាមេគ្រួសារ ។ ជនជាតិចាមគោរពធ្វើតាមច្បាប់ដែលចាត់ទុកស្ត្រី (មាតា) ជាធំ ។

បវេណីដែលសម្អាងលើខ្សែស្រឡាយខាងម្តាយមានឫសគល់តាំងពីជំនាន់ដ៏ដូនមកម្ល៉េះ ។ កាលពីដើម ការចាត់ទុកស្ត្រីជាធំបានសាយភាយនៅអាស៊ីអាគ្នេយ៍រហូតដល់មានការបញ្ចូលព្រះពុទ្ធសាសនានិងអ៊ីស្លាមសាសនាដែលតម្រូវឲ្យមានការគោរពឪពុកជាធំវិញ ដោយធ្វើឲ្យរលាយបាត់ការគោរពស្ត្រីជាធំដែលត្រូវជំនួសដោយប្រព័ន្ធរស់នៅមួយគឺស្វាមីភរិយាត្រូវមករស់នៅក្នុងគ្រួសារខាងប្រពន្ធដូចនៅប្រទេសកម្ពុជាឬប្រទេសថៃដែរ ។ ក្នុងចំណោមជនជាតិចាមនៅប្រទេសវៀតណាមការចាត់ទុកស្ត្រីជាធំនៅតែមិនផ្លាស់ប្តូរ ។






ដំណែលដូនតាបានធ្លាក់ពីម្តាយមកកូនស្រី ចំណែកកូនប្រុសមិនបានទទួលអ្វីទាំងអស់ ។ ង៉ៀន វ៉ាន់ទី រំឭកថា "ផ្ទះសម្បែង ការទទួលមរតក និងកូនៗ ជាកម្មសិទ្ធិរបស់ប្រពន្ធនិងកូនចៅរបស់ប្រពន្ធ គឺពុំមែនជាកម្មសិទ្ធិរបស់បុរសទេ" ។ ទំនៀមទម្លាប់នេះមានលក្ខណៈខុសនឹងច្បាប់អ្នកកាន់សាសនាអ៊ីស្លាមដែលថា កូនប្រុសត្រូវទទួលមរតកពីរដងលើសកូនស្រី ។ ក្នុងចំណោមចាមបានី អ្នករៀបការថ្មីៗបានចេញទៅរស់នៅក្នុងគ្រួសារខាងប្រពន្ធនិងធ្វើការដើម្បីគ្រួសារប្រពន្ធរបស់ខ្លួន ។ បាធី វិញ ស្ត្រីចាមវ័យចំណាស់ម្នាក់រស់នៅភូមិវ៉ាន់ឡាមបានបញ្ជាក់ថា "រៀបការរួច គ្រួសារខាងប្រុសប្រគល់កូនកំលោះឲ្យគ្រួសារខាងស្រី ។ គ្រួសារនេះមានអំណាចចាត់ចែងអ្វីៗទាំង

អស់” ។ ដោយការលែងលះបានប្រព្រឹត្តទៅជាគុណប្រយោជន៍ដល់ស្ត្រីស្ទើរតែដាច់មុខក្នុងការលែងលះ កូនៗពុំត្រូវបានបែងចែកទេ កូនៗត្រូវបានទៅខាងប្រពន្ធជានិច្ច ។ ផៀន វ៉ាន់ទី បានអះអាងថា “ទោះជាប្តីជាអ្នកសាងសង់ផ្ទះក៏ដោយ ក៏បុរសនោះមិនអាចទាមទារជាកម្មសិទ្ធិរបស់ខ្លួនបានដែរ ។ ហេតុដូច្នេះហើយបានជាមនុស្សប្រុសខ្លាចមិនហ៊ានលែងប្រពន្ធ ពីព្រោះវាធ្វើឲ្យសាមីខ្លួនបាត់បង់អ្វីៗទាំងអស់” ។



កូនស្រីត្រូវបានផ្តល់តម្លៃច្រើនជាងកូនប្រុសផ្ទុយពីទម្លាប់របស់វៀតណាមដែលនៅតែផ្តល់បុព្វសិទ្ធិឲ្យកូនប្រុសជានិច្ចសម្រាប់ការទទួលខុសត្រូវក្នុងការគោរពបូជាដូនតា ។ បា ធិញវិញ បាននិយាយថា “ស្ត្រីមានការយល់ដឹងច្រើនជាងបុរស ។ ពួកគេមានកូននិងមរតក ។ ហេតុដូច្នេះហើយបានជាក្នុងបវេណីចាម គេស្រឡាញ់ចង់បានកូនស្រីជាងកូនប្រុស” ។ អាចារ្យ ទុយ កុងដាត់ បន្ថែមថា “ជនជាតិចាមស្រឡាញ់កូនស្រីជាងពីព្រោះកូនស្រីនឹងក្លាយជាមេផ្ទះ” ។ ចាមបានីគោរពតាមសាសនារបស់ប្រពន្ធក្នុងករណីដែលមានការរៀបការឆ្លងសាសន៍ ។ នៅពេលនរណាម្នាក់ស្លាប់ ជនជាតិចាមតែងតែគោរពធ្វើតាមអំណាចរបស់សាច់ញាតិខាងម្តាយជានិច្ច ។ កន្លែងបញ្ចុះសពរបស់ចាមបានីគឺត្រូវបានរៀបផ្លូវជាជួរៗ ។ ជួរនីមួយៗមានសញ្ញាសម្គាល់ដោយផ្អែកលើដីដូនជីតាខាងម្តាយ ។ សាកសពម្តាយត្រូវបញ្ចុះជាមួយសាកសពកូនៗរបស់ខ្លួន ហើយបន្តដោយចៅៗរបស់ខ្លួន (កូនៗរបស់កូនស្រី) ។ ចំណែកសាកសពឪពុកត្រូវបញ្ចុះជាមួយសាកសពម្តាយរបស់ខ្លួន ពីព្រោះត្រូវរាប់បញ្ចូលទៅក្នុងក្រុមញាតិខាងម្តាយមិនមែនក្រុមញាតិខាងប្រពន្ធទេ ។ ចាមបានីគ្រាន់តែមករស់នៅក្នុងវង្សត្រកូលខាងប្រពន្ធប៉ុណ្ណោះ ។

## អ៊ីស្លាមូបនីយកម្មរបស់ជនជាតិចាម

សាសនាអ៊ីស្លាមចូលមកតាំងនៅនគរចម្ប៉ានៅចុងសតវត្សរ៍ទី១៦និងរីករាលដាលនៅសតវត្សរ៍ទី១៧ ដោយសារការទាក់ទងជាមួយឈ្មួញអារ៉ាប់ ពែក្ស (អ៊ីរ៉ង់) ឥណ្ឌា ជនជាតិចិនដែលកាន់សាសនាអ៊ីស្លាមដែលមកឈប់សំចតក្នុងកំពង់ផែចម្ប៉ា និងក្រុមអន្តោប្រវេសន៍ម៉ាឡេដែលមកផ្សព្វផ្សាយសាសនាអ៊ីស្លាមក្នុងពេលជាមួយគ្នាដែរ ។ ប៉ុន្តែជនជាតិចាមទាំងអស់នៅចម្ប៉ាពុំត្រូវញ៉ាំងឲ្យជឿសាសនាអ៊ីស្លាមទេ ។ ជនជាតិចាមជាច្រើននៅរក្សាសាសនាដើមរបស់ខ្លួនគឺព្រហ្មញ្ញសាសនា (ជាទម្រង់មុនគេបំផុតនៃលទ្ធិហិណ្ឌូលាយបញ្ចូលនឹងអបិយជំនឿក្នុងស្រុក) ។ ចាមបានីគ្រាន់តែតំណាងឲ្យមួយភាគបីនៃប្រជាជនចាមនៅប្រទេសវៀតណាមប៉ុណ្ណោះ ។ ការបញ្ចូលសាសនាអ៊ីស្លាមពុំមែនដឹកនាំធ្វើដោយគ្មានការបាត់បង់ស្ថិរភាពក្នុងសង្គមទេ ។ តាមរឿងព្រេងជាច្រើននិទានថា ការបញ្ចូលគ្នានេះបានបណ្តាលឲ្យកើតមានការទាស់ទែងគ្នាដ៏យូរមួយរវាងអ្នកកាន់សាសនាព្រហ្មញ្ញនិងបានី ។ ការប្រឈមនឹងជម្លោះខាងសាសនានេះ ច្បាប់ប្រពៃណីក្នុងសាសនាបានរាយការណ៍ឲ្យដឹងថា ស្តេចចាម ប៉ូរ៉ូមេ (១៦២៧-១៦៥១) បានតម្រូវឲ្យអ្នកកាន់សាសនាទាំងពីរទទួលស្គាល់អាទិទេពរបស់សាសនាម្ខាងទៀត ដើម្បីសម្រុះសម្រួលគ្នា ។ ក្នុងរជ្ជកាលរបស់ ប៉ូរ៉ូមេ មានលក្ខណៈអនុគ្រោះខ្លាំងណាស់ចំពោះអ្នកកាន់សាសនាអ៊ីស្លាម ។ ព្រះអង្គយាងទៅកាឡាន់តាន់ (រដ្ឋមួយរបស់ប្រទេសម៉ាឡេស៊ី) មុនការឡើងគ្រងរាជ្យរបស់ព្រះអង្គ ដើម្បីរៀនមន្តអាគមម៉ាឡេ និងសាសនាអ៊ីស្លាមទំនើប ។ ព្រះអង្គបានបន្ថែមឈ្មោះ “អល់ឡោះ” ដែលត្រូវប្រសិទ្ធិនាមឡើងវិញថា អាលវ៉ាស (Po Alwah) ។ សព្វថ្ងៃនេះ មានការសូត្រធម៌ឧទ្ទិសដល់អល់ឡោះនិងព្យាការី (Prophete) របស់ព្រះអង្គអមដោយការបួងសួងចំពោះព្រលឹង យ៉ាង (ទេវតារក្សាក្នុងស្រុក) ដូចជាទេវតារក្សាភ្លៀង ភ្នំ និងសមុទ្រ អាទិទេព ទឹករលក ឬទេពធីតាម្តាយប៉ូណាហ្គា ។ អ្វីដែលសំខាន់បំផុតគឺ ប៉ូណាហ្គា ត្រូវបានគោរពបូជាដោយចាមបានី ។ សម្រាប់អាចារ្យ ទុយ កុងដាត់ យល់ថា “ប៉ូណាហ្គាគឺជាមាតារបស់ប្រជាជនទាំងអស់នៅក្នុងពិភពលោក ពុំមែនតែជនជាតិចាមទេ ។ យើងគោរពបូជាប៉ូណាហ្គាដូចគោរពភរិយារបស់ អាដាមដែរ” ។

ការបែងចែកពូជចាមបានីនិងជាអ្នកកាន់សាសនាព្រហ្មញ្ញ

នេះគឺតម្រូវទៅតាមសមតា (ការថ្លឹងឲ្យស្មើគ្នា) មួយដែលរៀបចំឡើងលើទំនាក់ទំនងទ្វេភាគ (ដែលមានពីរជាគោល) មួយនិងបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ។ ពួកកាន់សាសនាព្រហ្មណ្ឌមានភាពស៊ីគ្នានឹងភេទប្រុសគឺផ្នែកខាងលើនៃដងខ្លួនដែលជាផ្នែកទល់មេឃនិងមានលេខ៣ ។ ចំណែកចាមបានីមានភាពស៊ីគ្នានឹងភេទស្រីគឺផ្នែកខាងក្រោមនៃដងខ្លួនជាប់ដីនិងមានលេខ៦ ។ អ្នកកាន់សាសនាព្រហ្មណ្ឌនៅពេលស្លាប់សុទ្ធតែត្រូវបូជា ។ វិញ្ញាណរបស់អ្នកទាំងនោះអណ្តែតឡើងលើមេឃ ដែលជាអាណាចក្ររបស់ឪពុក ។ សាកសពចាមបានី សុទ្ធតែត្រូវបញ្ចុះ ។ វិញ្ញាណរបស់អ្នកស្លាប់នឹងចុះទៅក្រោម ដីដែលជាអាណាចក្ររបស់ម្តាយ ។

បើបញ្ចូលគ្នារវាងសាសនារបស់ចាមបានីនិងអ្នកកាន់សាសនាព្រហ្មញ្ញដែលមានលេខ៩ (៣+៦) ក្លាយទៅជាសាសនាចំណាស់ជាងគេបំផុត ។ នេះជាចំនួនលេខដែលសុក្រឹត្យបំផុតមានន័យថា ជានិមិត្តរូបសន្តិភាពនិងស្ថិរភាព ។ សាសនាទាំងពីរមិនអាចស្ថិតនៅបានទេ ប្រសិនបើខ្វះសាសនាមួយ ។ ជនជាតិចាមដែលកាន់សាសនាព្រហ្មណ្ឌពុំមានសិទ្ធិសម្លាប់សត្វជើង៤ទេ គឺមានតែជនជាតិចាមបានីប៉ុណ្ណោះដែលអាចសម្លាប់បាន ។ រៀងរាល់បីឆ្នាំម្តង មន្ត្រីដឹកនាំជាន់ខ្ពស់ខាងចាមបានី និងខាងអ្នកកាន់សាសនាព្រហ្មណ្ឌបានជួបជុំគ្នាដើម្បីពិភាក្សារកភាពស្របគ្នារវាងប្រក្រតិទិនទាំងពីរ (ប្រព័ន្ធសុរិយគតិសម្រាប់អ្នកកាន់សាសនាព្រហ្មញ្ញ ហើយចន្ទគតិសម្រាប់ជនជាតិចាមបានី) ។ ដូច្នេះចាមបានីនៅរក្សាពិធីបុណ្យកាតេដែលជាពិធីបុណ្យធំមួយរបស់ពួកព្រហ្មញ្ញ ។ ពិធីបុណ្យនេះពុំមែនធ្វើក្នុងអំឡុងបុណ្យរ៉ាម៉ាឌនទេ ដើម្បីនឹងឲ្យអ្នកតំណាងសាសនាទាំងពីរបានចូលរួមពិធីបុណ្យនៅសហគមន៍មួយទៀត ។ ជនជាតិចាមបានីបានមកចូលរួមពិធីបុណ្យកាតេយ៉ាងច្រើន ហើយអ្នកកាន់សាសនាព្រហ្មញ្ញបានទៅចូលរួមពិធីបុណ្យរបស់ចាមបានីវិញ ។ ទុយ កុងដាត់ ក្រើនរំឭកថា "ពួកអ្នកកាន់សាសនាព្រហ្មញ្ញចូលក្នុងវិហារអ៊ីស្លាម ដើម្បីបំពេញហរ្សាកាត់ សម្រាប់អ្នកក្រីក្រក្នុងអំឡុងបុណ្យរ៉ាម៉ាឌន" ។ ការទប់ទល់នឹងសាសនាអ៊ីស្លាមប្រកាន់តាមគម្ពីរទំនាក់ទំនងក្នុងការរួមរស់ដោយសន្តិវិធី នេះពុំដែលរំលងហួសពីដែនដីតូចចង្អៀតនៃអតីតប៉ង់ឌុយ រ៉ង់ហ្កាដែលជាកន្លែងការពារដ៏មាំទាំចុងក្រោយរបស់នគរចម្ប៉ាឡើយ ។ ម្យ៉ាងទៀត ជនជាតិចាមដែលត្រូវបំបែកចេញពីគ្នាបានរត់គេចខ្លួនមកប្រទេសកម្ពុជានិងទៅប្រទេសម៉ាឡេស៊ី ហើយត្រូវញុាំងឲ្យផ្លាស់ប្តូរសាសនាមកជឿសាសនាអ៊ីស្លាម ប្រកាន់តាមគម្ពីរវិញ ។ ជនជាតិចាមដែលជាជនអន្តោប្រវេសន៍ បានពឹងផ្អែកលើការប្រតិបត្តិតាមក្បួនច្បាប់អ៊ីស្លាមដើម្បីរកឲ្យឃើញឡើងវិញនូវការរួបរួមនៃសង្គមមួយដែលរកកលនឹងចាកផុតពីដែនការពាររបស់ព្រលឹងយ៉ាង (ជាព្រលឹងដែលព្រហ្មញ្ញសាសនិកគោរព) ។ សាសនាអ៊ីស្លាមបែបសាហ៊្វីអ៊ីបានបញ្ចូលជនជាតិចាមដែលទើបផ្លាស់ប្តូរសាសនាក្នុងពេលថ្មីៗមកក្នុងមណ្ឌលនៃភាសាម៉ាឡេជាភាសាសម្រាប់សាសនានៃអាស៊ីអាគ្នេយ៍ ប៉ុន្តែក៏ជាភាសាសម្រាប់ពាណិជ្ជកម្មតាមសមុទ្រដែលការធ្វើជំនួញផ្តាច់មុខស្ថិតក្នុងកណ្តាប់ដៃអ្នកកាន់សាសនាអ៊ីស្លាមដែរ ។ អ៊ីស្លាមូបនីយកម្មរបស់ម៉ាឡេបានបើកចំហផងដែរសម្រាប់វិសាលភាពសង្គមដ៏ទូលំទូលាយមួយដោយប្រមូលផ្តុំជាសហព័ន្ធសម្រាប់សហគមន៍នៃអ្នកជឿសាសនាទាំងអស់ហៅម្យ៉ាងទៀតថា "អ៊ុមម៉ាស់" ។ ប៉ុន្តែជាថ្នូរមកវិញជនជាតិចាមដែលរស់នៅបែកខ្ញែកគ្នាបានបាត់បង់មួយចំណែកធំនៃវប្បធម៌របស់ខ្លួនគឺការចាត់ទុកស្ត្រីជាធំ ។ អ្នកទាំងនោះមិនបានដឹងទាំងអស់ពីប្រវត្តិសាស្ត្ររបស់ចម្ប៉ា ។ ផ្ទុយទៅវិញជនជាតិចាមដែលស្ថិតនៅលើដែនដីនៃអតីតនគរចម្ប៉ានៅតែចាត់ទុកទឹកដីដើមរបស់ចាមដដែលជាមួយនឹងព្រលឹង "យ៉ាង" អ្នកការពាររបស់ខ្លួន ហើយមិនសូវចាប់អារម្មណ៍នឹងសាសនាអ៊ីស្លាមដែលផ្សព្វផ្សាយដោយជនជាតិម៉ាឡេប៉ុន្មានឡើយ ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ សាសនាអ៊ីស្លាមប្រកាន់តាមគម្ពីរបានធ្វើការជ្រៀតចូលក្នុងភូមិនានារបស់បានី ។ អ្នកកាន់សាសនាអ៊ីស្លាមប្រកាន់យកតាមគម្ពីរជនជាតិចាមនិងអន្តោប្រវេសន៍តណ្ហាដែលមកពីក្រុងព្រៃនគរនិងដែនដីសណ្តទន្លេមេគង្គបានខំប្រឹងកែទម្រង់ការប្រតិបត្តិបែបអនាធិបតេយ្យនៃសាសនាអ៊ីស្លាម ។ ដោយមានជំនួយមូលនិធិពីបរទេស វិហារអ៊ីស្លាមចំនួនបីដែលមានរចនាបថអ៊ីស្លាមត្រូវបានសាងសង់ក្នុងភូមិរបស់បានីចំនួនបីរបស់ខេត្តនិញធន់ ។ នៅពេលនោះមានចាមបានីមួយចំនួន

តួចបានផ្លាស់ប្តូរចិត្តមកជឿសាសនាអ៊ីស្លាមបែបសាហ្វីអ៊ីវិញ ។ បុរសស្លៀកពាក់សារុងក្រឡាការ៉ូនិងពាក់កាតីប (កាពះ) ពណ៌ស ចំណែកនារីពាក់ហ៊ីចាប (ក្រណាត់ទទូរក្បាលនិងគ្របដងខ្លួន) និងស្លៀកសម្លៀកបំពាក់សូត្រធម៌ពណ៌ស ដែលគ្របដណ្តប់ខ្លួនប្រាណទាំងស្រុងលើកលែងតែដៃនិងមុខ ។

អ្នកផ្លាស់ប្តូរសាសនាខំប្រឹងប្រែងពង្រីកសាសនាថ្មីក្នុងបណ្តាភូមិរបស់ខ្លួន ប៉ុន្តែអ្នកទាំងនេះប៉ះទង្គិចនឹងជនជាតិចាមបានីដែលមិនអាចសម្រុះសម្រួលបាន ។ ហាជ្ជី អាមីន ដែលជាអ៊ីមុាំនៃវិហារអ៊ីស្លាមនៅវ៉ាន់ឡាម (អតីតចាមបានីដែលផ្លាស់ប្តូរសាសនា) បានសម្តែងការសោកស្តាយពីអសមត្ថភាពរបស់ខ្លួនក្នុងការបញ្ចុះបញ្ចូលអតីតអ្នកកាន់សាសនាដូចគ្នា ។ អាមីន និយាយថា «យើងបានជួបបណ្តាព្រឹទ្ធាចារ្យបានីជាច្រើនលើកដើម្បីរំឭកពីករណីយកិច្ចឲ្យគាត់សូត្រធម៌រាល់ថ្ងៃចំនួន៥ដង ប៉ុន្តែពួកគាត់ពុំបានប្រត្តិបត្តិតាមទេ ។ ម្យ៉ាងទៀត សាសនាអ៊ីស្លាមតម្រូវឲ្យយើងបើកទ្វារវិហារអ៊ីស្លាមនៅថ្ងៃសុក្រ ព្រោះជាថ្ងៃនៃពិធីជួបជុំធំមួយ ប៉ុន្តែពួកគេបានបើកទ្វារវិហារអ៊ីស្លាមតែមួយដងប៉ុណ្ណោះក្នុងមួយខែ» ។

ជនជាតិចាមបានីមានតែ១០ភាគរយប៉ុណ្ណោះដែលបានផ្លាស់ប្តូរសាសនា ។ មូលហេតុសំខាន់នៃការបរាជ័យនេះ គឺបណ្តាលមកពីប្រព័ន្ធចាត់ទុកស្ត្រីជាធំដែលជាមូលដ្ឋានក្នុងសង្គមចាម ។ ប្រព័ន្ធនេះបង្ខំឲ្យស្វាមីធ្វើតាមប្រពន្ធក្នុងករណីដែលមានការរៀបការចម្រុះ(ឆ្លងសាសន៍) ដើម្បីរឹតត្បិតការរាលដាលសាសនាអ៊ីស្លាមថ្មី ។ អេនស៊ី គៀវ ចាមបានីនៅភូមិវ៉ាន់ឡាមបានរៀបរាប់ថា «ខ្ញុំបានផ្លាស់ប្តូរទៅជឿសាសនាអ៊ីស្លាមប្រកាន់តាមគម្ពីរ នៅពេលដែលខ្ញុំមានអាយុ១៨ឆ្នាំ ប៉ុន្តែនៅពេលខ្ញុំរៀបការ ខ្ញុំបានក្លាយទៅជាចាមបានីដូចដើមវិញ ។ ទំនៀមទម្លាប់ចាមស្ថិតនៅត្រង់ថា ប្តីត្រូវធ្វើតាមប្រពន្ធបន្ទាប់ពីរៀបការរួច» ។


អាចារ្យចាមបានីចូលក្នុងវិហារដើម្បីលាងជម្រះបាប

ជនជាតិបានីមិនសូវចាប់អារម្មណ៍នឹងដំណើរប្រែត្រឡប់ក្នុងការប្រកាន់តាមគម្ពីររបស់សាសនាអ៊ីស្លាមដែលបើកផ្លូវឲ្យស្គាល់នូវជម្រៅនៃសាសនាតាំងពីសតវត្សរ៍ទី១៩ដោយចលនាផ្សេងៗដែលជាអ្នកនិយមកែទម្រង់ ។ ប៉ុន្តែ ហាជ្ជី អាមីន ដែលជាអ៊ីស្លាមសាសនិកប្រកាន់តាមគម្ពីរបានរំឭកពីគុណសម្បត្តិប្រសើរលើសលប់នៃវប្បធម៌ខាងសាសនាថា «យើងទាំងអស់ជាជនជាតិចាមហើយ យើងតម្កល់អត្តសញ្ញាណចាមពីលើអ្វីៗទាំងអស់ ។ យើងជាជនជាតិចាមដែលធ្វើតាមសាសនាអ៊ីស្លាមមិនមែនសាសនាអ៊ីស្លាមដែលមានវប្បធម៌ចាមលាយឡំទេ ។ យើងនៅតែជាជនជាតិចាមតាមប្រព័ន្ធចាត់ទុកស្ត្រីជាធំ ហើយជាវប្បធម៌របស់យើងដែលត្រូវតែការពារ» ។

**អារញ៉ា ឌីហ្វូ**

# ជនជាតិមិល

មិល (នៅក្នុងវចនុក្រមខ្មែរបោះពុម្ពឆ្នាំ១៩៦៧សរសេរ មិលក្ទុះ) ជាជនជាតិភាគតិចមួយក្រុមដែលប្រជាជនខ្មែរភាគច្រើនស្ទើរតែមិនដឹងថាអ្នកទាំងអស់នោះកំពុងតែមានវត្តមាននៅក្នុងប្រទេសកម្ពុជាផង ។ ជនជាតិនោះហៅខ្លួនឯងថា មិល ។ ជនជាតិមិលគ្មានសាសនាដូចជនជាតិដទៃទេ ។ បច្ចុប្បន្នជនជាតិនេះមានចំនួន៦១គ្រួសារកំពុងរស់លាយឡំជាមួយប្រជាជនខ្មែរនៅក្នុងភូមិមួយចម្ងាយ៤០គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ។ ភូមិកំណើតរបស់ជនជាតិនេះពីដើមឡើយស្ថិតនៅភូមិឆក់ត្រាចហៅភូមិក្ងិក្ងក់ ចម្ងាយប្រហែល៣០គីឡូម៉ែត្រខាងកើតភូមិអូរពោធិ៍ ខេត្តក្រចេះ ។ ដោយសារមានជំងឺអុតធំរាតត្បាតពេញភូមិនិងដោយមានព្នងមួយក្រុមចូលមកកាប់សម្លាប់ប្រជាជនក្នុងភូមិ ជនជាតិមិលបានរត់ភៀសខ្លួនមករស់នៅវាលមួយហៅថា«ស្រែចង្ហួប» ។ នៅក្នុងរបបសង្គមរាស្ត្រនិយម ភូមិនេះត្រូវបានប្តូរទីតាំងមកនៅជាប់ផ្លូវជាតិវិញដើម្បីងាយស្រួលទំនាក់ទំនងជាមួយសង្គមនិងដើម្បីឲ្យកុមារបានចូលរៀននៅសាលាផង ។ អំឡុងពេលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧០ដល់១៩៧៥ និងនៅក្នុងរបបខ្មែរក្រហម បុរសមិលជាច្រើននាក់បានបម្រើបដិវត្តន៍ខ្មែរក្រហម ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ ជនជាតិមិលមួយចំនួនបានទទួលតួនាទីខ្ពស់ មួយចំនួនត្រូវខ្មែរក្រហមសម្លាប់ចោល ហើយមួយចំនួនទៀតបាត់ខ្លួន ។

តេង ជនជាតិមិល ជាប្រធានឈ្លបនៅក្នុងរបបខ្មែរក្រហម ។ អ្នកភូមិចង្ហួបបានដឹងគ្រប់ៗគ្នាថា តេង ជាមនុស្សកាចសាហាវបំផុតនៅជំនាន់នោះ ។ ប្រសិនបើប្រជាជនណាធ្វើខុស ជាពិសេសប្រជាជន១៧មេសា តេង បញ្ជាឲ្យឈ្លបមកហៅទៅ ហើយអ្នកនោះបាត់ខ្លួនរហូត ។ តេង បានសម្លាប់ប្រជាជន១៧មេសាអស់ជាច្រើននាក់ ។ នៅឆ្នាំ១៩៧៩ តេង ត្រូវកងទ័ពវៀតណាមចាប់ខ្លួន និងបញ្ជូនទៅដាក់គុកនៅប្រទេសវៀតណាមអស់រយៈពេលជាងមួយឆ្នាំ ។ ក្រោយពីត្រឡប់ចូលភូមិវិញ តេង ត្រូវប្រជាជន១៧មេសានៅស្រុកតាមូងព្រួតគ្នាវាយសម្លាប់នៅតាមផ្លូវ ។

កក វ៉ែន ជនជាតិមិល អាយុ៥៩ឆ្នាំ ប្រាប់ថា គាត់បានបាត់កូនប្រុសម្នាក់បន្ទាប់ពីទៅបម្រើខ្មែរក្រហម ។ ក្រោយមកបានឮអ្នកស្រុកនិយាយថាកូនរបស់គាត់ត្រូវតាម៉ុកសម្លាប់ ។



ស្ត្រីមិលនៅភូមិចង្ហួប

សឿ ឃ្លឹម អាយុ៤៥ឆ្នាំ បានចូលធ្វើកងទ័ពខ្មែរក្រហមតាំងពីអាយុ១៥ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៦ ។ កាលណោះ អង្គការបញ្ជូនគាត់ទៅបម្រើការនៅខេត្តក្រចេះ រយៈពេលមួយឆ្នាំ ក្រោមការដឹកនាំរបស់ឈ្មោះ យី និង កួន ។ ចុងឆ្នាំ ១៩៧៧ គាត់ត្រូវអង្គការឲ្យទៅខេត្តរតនគិរី ធ្វើជាយុទ្ធជននៅកងពល ៩២០ ។ នៅក្នុងឆ្នាំ១៩៧៨ អង្គការលើបានចាប់ខ្លួន យី និង កួន ដោយចោទអ្នកទាំងពីរថាក្បត់បដិវត្តន៍ ។ ក្រោយពីចាប់ យី និង កួន រួចអង្គការក៏តាមចាប់ខ្លួន ឃ្លឹម និងយុទ្ធជនផ្សេងទៀត ។ ឃ្លឹម បានរត់ទៅលាក់ខ្លួនក្នុងព្រៃ រហូតដល់ឆ្នាំ១៩៨២ទើបហ៊ានត្រឡប់ចូលភូមិវិញ ។


សឿ ឃ្លឹម

ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អ្នកភូមិចន្លួបទាំងអស់ត្រូវបានជម្លៀសចេញពីភូមិទៅរស់នៅសហករណ៍ស្រែចន្លួប ចំណែកផ្ទះសម្បែងត្រូវអង្គការយកធ្វើឃ្លាំងសម្រាប់ដាក់អំបិល អង្ករ និងសម្ភារផ្សេងៗ ។ យុវជនត្រូវបង្ខំឲ្យចូលធ្វើកងទ័ព ។ បុរសវ័យកណ្តាលត្រូវអង្គការឲ្យធ្វើជាជាងសាងសង់ផ្ទះ លើកទំនប់ និងធ្វើស្រែ ។ ស្ត្រីវ័យចំណាស់នៅថែរក្សាកុមារតូចនៅមណ្ឌលកុមារ ។ ខេន និង ជូតាំង បានប្រាប់ឲ្យដឹងថា គាត់ត្រូវអង្គការចាត់តាំងឲ្យសាងសង់ផ្ទះគ្រប់ទីកន្លែង ក្នុងរយៈពេលពីរបីខែទើបអង្គការអនុញ្ញាតឲ្យមកជួបក្រុមគ្រួសារម្តង ។ ក្រៅពីការងារសាងសង់ អង្គការបានបញ្ជូនគាត់ទៅលើកទំនប់នៅអូរគ្រៀងនិងនៅកន្លែងផ្សេងទៀតដែលគាត់មិនចាំឈ្មោះ ។ ខេន បានប្រាប់ថា កាលជំនាន់នោះ គាត់ធ្វើស្រែនិងប្រមូលផលស្រូវបានច្រើនណាស់ ប៉ុន្តែគាត់នៅតែហូបបបររាវៗជារៀងរាល់ថ្ងៃ ។ នៅរដូវប្រមូលផលស្រូវគាត់ឃើញមានរថយន្តមកដឹកអង្ករទៅបាត់ៗមិនដឹងថាដឹកយកទៅទុកនៅកន្លែងណាទេ ។ កម្មាភិបាលខ្មែរក្រហមនិយាយប្រាប់ប្រជាជនថា សហករណ៍ផ្សេងខ្វះអង្ករ ហើយក៏ដឹកស្រូវយកទៅ ជួនកាលដឹកចូលទៅក្នុងព្រៃបាត់ ។

ចាប់ពីឆ្នាំ១៩៧៧ សហករណ៍ចន្លួបមានសមាជិកកាន់តែច្រើនដោយសារអង្គការដឹកប្រជាជនជម្លៀសគ្រប់ជនជាតិមាន ខ្មែរ ចិន ចាម មករស់នៅលាយឡំជាមួយប្រជាជនមិល ។ ប្រជាជនទាំងអស់គ្រប់ជាតិសាសន៍មិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរឡើយ ។

ជូ តាំង ជនជាតិមិល អាយុ៦០ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិចន្លួបនិយាយថា «ចិនគេអត់ឲ្យនិយាយភាសាចិន ចាមក៏គេអត់ឲ្យនិយាយភាសាចាម មិលក៏គេអត់ឲ្យនិយាយ ឲ្យនិយាយតែភាសាខ្មែរ ហើយជនជាតិចាមសាច់គោ ក៏អត់ឲ្យស៊ី គេបំបិទទាំងអស់ ។ ផ្ទះខ្ញុំនៅពីរគ្រួសារ កូនផ្ទះតូចមួយហ្នឹង ចាមមួយគ្រួសារ ចិនមួយគ្រួសារ» ។


ជូ តាំង


កូវ ខេន

កូវ ខេន ជនជាតិមិល អាយុ៧៤ឆ្នាំ និយាយថា ប្រជាជនជម្លៀសស្លាប់ច្រើនណាស់កាលជំនាន់នោះព្រោះមិនចេះអត់ធ្មត់នឹងការងារនិងរអ៊ូរទាំច្រើន ។ ចំណែកអ្នកភូមិចន្លួបមិនសូវមានស្លាប់ដោយការសម្លាប់ទេ ភាគច្រើនស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាលទៅវិញ ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានរៀបគម្រោងធ្វើនំបញ្ចុកដោយដាក់ថ្នាំបំពុលនៅក្នុងសម្លឲ្យប្រជាជនហូបនៅថ្ងៃទី៣០ ខែធ្នូ ក្នុងគោលបំណងសម្លាប់ប្រជាជនទាំងអស់នៅសហករណ៍ចន្លួប ។ ផែនការនេះត្រូវបរាជ័យទៅវិញដោយសារកងទ័ពវៀតណាមបានបណ្តេញខ្មែរក្រហមឲ្យរត់ខ្ចាត់ខ្ចាយ ។ ខេន បានដឹងអំពីផែនការនេះដោយចៃដន្យនៅពេលគាត់ធ្វើដំណើរទៅកាន់វាលស្រែៈ «ថ្ងៃមួយខ្ញុំបានឮមេធំៗប្រជុំគ្នានៅក្រៅភូមិថា ថ្ងៃទី៣០ ទុកក្រមុំខ្មែរស្អាតៗតែមួយពាន់នាក់ទេបង្កាត់ពូជជាមួយចិន ក្រៅពីហ្នឹងបំពុលទាំងអស់ ។ ដល់ឆ្នាំ៧៩កុំតែវៀតណាមមកទាន់ កុំអីខ្មែរយើងអត់សល់ពូជទេ» ។

កែវ ណន អាយុ៥៣ឆ្នាំ ជនជាតិខ្មែរដែលបានមករស់នៅភូមិចន្លួបតាំងពីឆ្នាំ១៩៦៩ ក៏បានឮអំពីគម្រោងសម្លាប់ប្រជាជនដោយដាក់ថ្នាំបំពុលក្នុងនំបញ្ចុកដែរ ។

នៅពេលបាក់ទ័ពរត់ចូលព្រៃ កងទ័ពខ្មែរក្រហមបានកៀរប្រជាជនទៅជាមួយខ្លួន ហើយថែមទាំងឃោសនាថា អ្នកណាមិន


កែវ ណន

រត់នឹងត្រូវវៀតណាមអារ-ក ។ ប្រជាជនភូមិចង្ហូបខ្លះដែលភ័យខ្លាច បាននាំគ្នារត់ទៅជាមួយខ្មែរក្រហម ខ្លះទៀតត្រឡប់មកភូមិវិញ ។ ជូ តាំង បាននិយាយថា កាលណោះ គាត់បានរត់ទៅរហូតដល់ស្រុកសំបូរ ហើយបានជួបក្រុមគ្រួសាររបស់គាត់នៅកំពង់ញ្ញោ ។ តាំង បានប្រគល់អាវុធឲ្យកងទ័ពវៀតណាម រួចនាំប្រពន្ធនិងកូន ត្រឡប់មកភូមិវិញ ។ ចំណែក ខេន ក៏ដូចជាអ្នកភូមិរបស់គាត់ដែរ បានរត់ភៀសខ្លួនរហូតដល់អូរកាច់ព្រួល ហើយបានជួបកងទ័ពវៀតណាមនៅតាមផ្លូវ ។ កងទ័ពវៀតណាមបានប្រាប់គាត់ឲ្យត្រឡប់មកស្រុកភូមិកំណើតវិញ ។

បន្ទាប់ពីឆ្នាំ១៩៧៩ ជនជាតិមិលវិលត្រឡប់មកភូមិចង្ហូបវិញ ។ វៀតណាមបានចាត់តាំងមេភូមិចង្ហូបដើម្បីចែកស្រូវអង្ករ អំបិល គោក្របី និងជ័យភណ្ឌ ឲ្យប្រជាជនស្មើៗគ្នា ។ ក្នុងរយៈពេលនោះ កងទ័ពខ្មែរក្រហមតែងលួចវាយឆ្មក់ចូលភូមិចង្ហូបជាញឹកញាប់ ធ្វើឲ្យអ្នកភូមិមួយចំនួនត្រូវគ្រាប់ស្លាប់ ។ ម្ដាយមីងរបស់ តាំង បានស្លាប់ក្នុងពេលខ្មែរក្រហមវាយឆ្មក់ចូលភូមិចង្ហូប ។ តាំង និយាយថា «ខ្ញុំអត់ភ្លេចទេ ទាល់តែខ្ញុំស្លាប់ទើបខ្ញុំភ្លេចជិតនាន់៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ។ ខ្ញុំមានបានពីមុនមកក៏រលាយសូន្យ នេះខ្ញុំកសាងសាជាថ្មីទេ ក្រោយ ៧៩នេះអត់ភ្លេចទេ» ។

នៅពេលរំឭកដល់របបខ្មែរក្រហមប្រជាជនមិលនៅក្នុងភូមិចង្ហូបបាននិយាយថាគាត់មិនចង់ឮពីរបបនេះទៀតឡើយ ។ គាត់គ្រាន់តែចង់រស់នៅដោយសុខសាន្តដូចសព្វថ្ងៃតែប៉ុណ្ណោះ ទោះបីមានអ្នកមកឃោសនាថា ខាងនេះល្អខាងនោះមិនល្អក៏គាត់មិនជឿទៀតដែរ ។ **លី សុផល**

## ពន្យល់ពាក្យខ្មែរក្រហម

◆ មូលដ្ឋាន ៖ ជាគ្រឹះដ៏រឹងមាំ ឬ ជាទម្រង់ដ៏រឹងមាំ

◆ សមូហភាព ៖ ការប្រមូលផ្ដុំសង្គមមនុស្ស (សៀវភៅកំណត់ហេតុអ៊ី)

## វេទិកាថែរក្សាប្រវត្តិសាស្ត្រនិងវប្បធម៌ជនជាតិភាគតិច

មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំកម្មវិធី "ថែរក្សាវប្បធម៌ចាម និងជនជាតិភាគតិចនៅកម្ពុជា" ចាប់ពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៧ ។ កម្មវិធីនេះសូមអំពាវនាវដល់ហាកិម គ្រូ អ្នកស្រាវជ្រាវ សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្ដីវប្បធម៌ចាមនិងវប្បធម៌ជនជាតិភាគតិចផ្សេងៗទៀតនៅប្រទេសកម្ពុជាបច្ចុប្បន្ន និងផ្ដល់ព័ត៌មានទាំងឡាយស្ដីអំពីការប្រព្រឹត្តរបស់ខ្មែរក្រហមមកលើជនជាតិភាគតិចក្នុងចន្លោះឆ្នាំ១៩៧៥ដល់ ១៩៧៩ ដែលលោកអ្នកបានដឹងឮដើម្បីចូលរួមចំណែកចងក្រងប្រវត្តិសាស្ត្រជនជាតិភាគតិចឲ្យកាន់តែប្រសើរ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រនិងវប្បធម៌ជនជាតិភាគតិចទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរក្សាអត្តសញ្ញាណជនជាតិចាមនិងជនជាតិភាគតិចផ្សេងៗទៀត និងតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រដែលរួមបញ្ចូលទាំងអក្សរនៃជនជាតិនីមួយៗ ចាប់ពី៣ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្ដីស្វែងរកការពិត ព្រមទាំងការបោះពុម្ពផ្សាយស្ដីពីវប្បធម៌ជនជាតិភាគតិច ។ លោកអ្នកអាចផ្ញើអត្ថបទមកមជ្ឈមណ្ឌលឯកសារកម្ពុជាអាស័យដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចម្ការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៩៦៧ ៥៦៥ ។ សូមអរគុណ ។

# ក្រុមយុវជនចាមមូស្លីមនិងយុវនិស្សិតច្បាប់ : ស្វែងយល់ពីអំពើប្រល័យពូជសាសន៍និងសាលាក្តីខ្មែរក្រហម

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ យុវជនចាមមូស្លីមចំនួន១០០នាក់(សិស្សនិងនិស្សិត) បានចូលរួមទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជើងឯកនិងនៅថ្ងៃបន្ទាប់មានយុវនិស្សិតច្បាប់មួយក្រុមទៀតចំនួន៣៥០នាក់មកសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក៏បានចូលរួមជាមួយក្រុមយុវជនចាមមូស្លីមក្នុងកម្មវិធីទៅកាន់អគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ឬសាលាក្តីខ្មែរក្រហម) ។ ដំណើរទស្សនកិច្ចលើកនេះខុសគ្នាបន្តិចពីលើកមុនៗ លើកនេះផ្តោតសំខាន់លើយុវវ័យដែលស្ថិតក្នុងវ័យចន្លោះពី១៧-២៥ឆ្នាំ កើតក្រោយរបបប្រល័យពូជសាសន៍ ។ ក៏ប៉ុន្តែគោលបំណងនៃដំណើរទស្សនកិច្ចនៅដដែល គឺសង្កត់ធ្ងន់ទៅលើការអប់រំប្រជាជនកម្ពុជាពីអំពើប្រល័យពូជសាសន៍ និងផ្តល់តួនាទីដល់ប្រជាជននៅក្នុងដំណើរការសាលាក្តីខ្មែរក្រហម ។

អស់រយៈកាលជិត៣០ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានៅតែមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិនៅឡើយ ។ អ្វីដែលក្មេងជំនាន់ក្រោយបានដឹងទាក់ទងនឹងអំពើប្រល័យពូជសាសន៍គឺដឹងតែតាមរយៈការនិយាយប្រាប់របស់ឪពុកម្តាយខ្លួនប៉ុណ្ណោះ ។ ចំពោះបញ្ហាតុលាការ ជាប្រធានបទមួយដែលធ្វើឲ្យមានការនឿយណាយសម្រាប់អ្នកតាមដានដំណើរការចរចាដ៏តានតឹងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានៅក្នុងរយៈកាល៩ឆ្នាំកន្លងមកនេះ ។ អ្នកខ្លះបានបោះបង់ចោលក្តីសង្ឃឹមក្នុងការតាមដានព្រឹត្តិការណ៍នេះ ។ យ៉ាងណាមិញរដូវក្តៅឆ្នាំ២០០៦បាននាំមកនូវក្តីសង្ឃឹមថ្មីក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមមកកាត់ទោសជាមួយនឹងការចាប់ផ្តើមដំណើរការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញនៅពេលនេះបានក្លាយទៅជាប្រធានបទដ៏ចម្បងនៅក្នុងទំព័រសារព័ត៌មានក្នុងស្រុក ។

ថ្ងៃទី១នៃដំណើរទស្សនកិច្ចនេះរៀបចំដោយកញ្ញា សូហ្វារីណា ជាប្រធានកម្មវិធីប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ជនជាតិចាមមូស្លីមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យុវជនចាមមូស្លីមទាំងនេះមកពីខេត្តក្រុងចំនួន១១ ដែលរួមមាន ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ ។ នេះជាលើកទីមួយសម្រាប់យុវជនចាមមូស្លីមក្នុង



យុវជនចាមមុស្លីមស្តាប់ការពន្យល់អំពីគម្រោងសម្រាប់យុវជននៅវាលពិឃាដជើងឯក

ការមកទស្សនាសារមន្ទីរប្រល័យពូជសាសន៍គុកទួលស្លែងនិងបូជនីយដ្ឋានប្រល័យពូជសាសន៍ជើងឯក ។

កម្មវិធីចាប់ផ្តើមនៅម៉ោង១និង៣០នាទីរសៀលគឺនៅពេលដែលនិស្សិតធ្វើដំណើរមកដល់សារមន្ទីរគុកទួលស្លែង ។ យុវនិស្សិតស្រីខ្លះស្លៀកសម្លៀកបំពាក់ប្រពៃណីជនជាតិចាម ។ ជាមួយកន្សែងរុំក្បាលពណ៌ខ្មៅ កញ្ញា ហ្វារីណា បាននាំក្រុមនិស្សិតទៅកាន់អគារ“ក”និងពន្យល់ប្រាប់ពីប្រវត្តិនៃសារមន្ទីរ ។

នៅក្នុងសម័យសង្គមរាស្ត្រនិយមចន្លោះទសវត្សរ៍ឆ្នាំ ១៩៥០និង១៩៦០ សារមន្ទីរគុកទួលស្លែងជាអតីតវិទ្យាល័យមួយឈ្មោះវិទ្យាល័យពោញាយ៉ាត។ បន្ទាប់ពីថ្ងៃរដ្ឋប្រហារនាដើមឆ្នាំ១៩៧០ វិទ្យាល័យនេះត្រូវបានប្តូរឈ្មោះទៅជាវិទ្យាល័យទួលស្វាយព្រៃ។ រយៈពេលខ្លីបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច និងជម្លៀសប្រជាជនឲ្យទៅតាំងលំនៅដ្ឋានតាមជនបទ វិទ្យាល័យនេះត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំងនិងសួរចម្លើយវិញ។ កម្មាភិបាលថ្នាក់ដឹកនាំរបស់ខ្មែរក្រហម បានដាក់ឈ្មោះថ្មីឲ្យវិទ្យាល័យនេះថា “មន្ទីរស-២១” ដែលជាមន្ទីរសន្តិសុខកម្រិតខ្ពស់ក្នុងចំណោមមន្ទីរសន្តិសុខខ្មែរក្រហមទាំង១៩៨កន្លែងដែលមាននៅទូទាំងប្រទេសក្នុងចន្លោះឆ្នាំ១៩៧៥និង១៩៧៩។ អ្នកទោសប្រមាណ២ម៉ឺននាក់បានឆ្លងកាត់ខ្លោងទ្វារគុកនេះ។ អ្នកទោសទាំងនោះត្រូវដឹកចូលមកជាក្រុម ដោយបិទមុខ ដោយការបំភ័ន្តនិងបំភិតបំភ័យ។ អ្នកទោសត្រូវបានថតរូបដោយអ្នកថតរូបម្នាក់ក្នុងចំណោមអ្នកថតរូប៦នាក់ មុនពេលដែលត្រូវនាំទៅសួរចម្លើយពី “បទល្មើស” របស់ខ្លួន។ អំពើដែលចាត់ទុកថាជាបទល្មើសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលួចអង្ករនិងមិនព្រមរៀបការជាមួយមនុស្សចម្លែក (មនុស្សដែលមិនធ្លាប់ស្គាល់គ្នា)។ មានអ្នកទោសតិចតួចណាស់ដែលបានរួចផុតពីមន្ទីរនេះ។ សារមន្ទីរនេះជាកន្លែងគួរឲ្យភ័យខ្លាច សាហាវឃោរឃៅ និងជាកន្លែងសម្លាប់ដែលវិលវល់ពេញប្រទេសក្នុងអំឡុងពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃនៃរបបដែលដឹកនាំកម្ពុជាប្រជាធិបតេយ្យ។

យុវជនចាមមូស្លីមបានដើរទស្សនាអគារទាំងបួននៃសារមន្ទីរដែលមានតាំងសម្ភារៈធ្វើទារុណកម្ម ពិព័រណ៍រូបថត បន្ទប់គុកធ្វើពីថ្មនិងឈើ និងលលាដ៍ក្បាលតម្កល់នៅក្នុងអតីតបន្ទប់រៀនទាំងនោះ។ យុវសិស្សខ្លះមានការរំជួលចិត្តចំពោះអ្វីដែលពួកគេបានឃើញ ហើយយុវនិស្សិតខ្លះទៀតមើលទិដ្ឋភាពទាំងនោះក្នុងភាពភ្ញាក់ផ្អើលតាមរបៀបកូនក្មេងដែលចង់ដឹងចង់ឮពីអ្វីមួយ។

តាមកាំជណ្តើរខាងក្រៅអគារ “គ” ខាងក្រោមលួសបន្លាដែលព័ទ្ធស្ទើរតែពេញផ្នែកខាងមុខអគារ ហ្វារីណា សម្មាសនិស្សិតម្នាក់ឈ្មោះ លី ម៉ី អាយុ២០ឆ្នាំ និងជាកូនច្បងក្នុងចំណោមបងប្អូន៤នាក់។ ទោះបីជានាងរៀនបានត្រឹមថ្នាក់ទី១២ក៏ដោយ ក៏ម៉ី បានរៀបរាប់ពីអំពើប្រល័យពូជសាសន៍និងសាលាក្តីប្រកបដោយការយល់ដឹង ភាពស្មោះត្រង់និងភាពប៉ិនប្រសប់របស់ខ្លួន។

មុនពេលមកដល់សារមន្ទីរ ម៉ី មិនបានឲ្យតម្លៃខ្ពស់លើដំណើរទស្សនកិច្ចនេះទេ។ ម៉ី គិតទុកថា ខ្លួននឹងបានឃើញរូបថតដែលនៅសល់ពីរបបខ្មែរក្រហម និងទទួលបានចំណេះដឹងបន្តិចបន្តួចតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលដើរកាត់ជួររូបថតអ្នកទោសមន្ទីរស-២១ ម៉ី បែរជារំជួលចិត្តយ៉ាងខ្លាំង។ ម៉ី ប្រាប់ថា “ខ្ញុំស្ទើរតែស្រក់ទឹកភ្នែកទៅហើយ ហើយមិនដែលនឹកស្រម៉ៃថាទិដ្ឋភាពនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩មានសភាពសាហាវយ៉ាងដូច្នេះសោះ”។ ការមកទស្សនាសារមន្ទីរនេះពិតជាបានបង្ហាញឲ្យម៉ី ដឹងថា ប្រជាជនឈឺចាប់ដល់កម្រិតណា។ ថ្វីបើមុនពេលចូលរួមដំណើរទស្សនកិច្ចនេះ ម៉ី ជឿថាពិតជាមានអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏ការមកឃើញនឹងភ្នែកនូវវត្ថុតាងនៅសារមន្ទីរ ពិតជាបានផ្សារភ្ជាប់ទៅនឹងរឿងរ៉ាវដែលឪពុកម្តាយនិយាយប្រាប់មែន។ ម៉ី បន្តថា កាលពីក្មេង ឪពុកម្តាយនិងគ្រូបង្រៀនរបស់នាងក៏ធ្លាប់និយាយប្រាប់ពីប្រវត្តិជីវិតរបស់ពួកគាត់នៅក្នុងរបបនោះដែរ។ ម៉ី ប្រាប់អ្នកគ្រូថា មិន ជឿទេ ហើយអ្នកគ្រូបានឲ្យ ម៉ី ទៅសួរឪពុកម្តាយ។ ឪពុកម្តាយ របស់ ម៉ី បានបញ្ជាក់បន្ថែមទៅលើអ្វីដែលគ្រូរបស់ ម៉ី បាននិយាយទៀត។

ឪពុករបស់ ម៉ី ឈ្មោះ ឯល ជប់ ជាអតីតអ្នកមើលថែក្របីនៅក្នុងរបប ប៉ុល ពត។ ការងារនេះ ក៏ដូចជាការងារផ្សេងទៀតដែរ ដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើនៅពេលនោះដែលអាចកំណត់ពីជោគវាសនារបស់មនុស្ស។ ការធ្វើឲ្យមានកំហុសមួយគឺអាចនាំឲ្យអ្នកបាត់បង់ជីវិតបាន។ ដូចជាករណីឪពុករបស់ ម៉ី, ការធ្វើឲ្យបាត់ក្របីមួយមានន័យថា ជាការបាត់ជីវិតរបស់គាត់។ ជាអកុសល ក្របីមួយក្បាលបានបាត់ចេញពីហ្វូង ប្រធានក្រុមបានទុកពេលឲ្យ ឪពុក ម៉ី ៣ថ្ងៃដើម្បីរកក្របីនោះឲ្យឃើញ។ ឯល ជប់ ដឹងថាគាត់នឹងត្រូវសម្លាប់ប្រសិនបើគាត់រកក្របីនោះមិនឃើញក្នុងរយៈពេល៣ថ្ងៃទេ។ ជប់ រកក្របីនោះមិនឃើញសោះ គាត់បានត្រៀមខ្លួនជាស្រេចដើម្បីស្លាប់។ ប្រហែលជាមកពីការអាណិត ទើបប្រធានក្រុមសម្រេចទុកឲ្យគាត់មានជីវិតរស់បន្តទៀត។ ជប់ ត្រូវទទួលពិន័យឲ្យទៅរែកដីនិងថ្មដោយមិន

បានទទួលរបបអាហារមួយរយៈពេល ។ ជប់ អាចរស់រានជីវិតបានដោយការចាប់ក្តាមហូបនៅពេលយប់ ។ ជប់ មិនដែលជឿថាគាត់អាចរស់រានមានជីវិតនៅក្នុងរបបនោះឡើយ ។ ច្រើនទសវត្សរ៍បន្ទាប់មក ឪពុករបស់ ម៉ី ពិតជាមានការពិបាកក្នុងការនិយាយពីអតីតកាលរបស់គាត់ ។

ចំណែកពូរបស់ ម៉ី វិញ ស្នាកស្នាមពីរបបប្រល័យពូជសាសន៍របស់គាត់មានទាំងខាងចិត្តនិងផ្លូវកាយ ។ កេ រូសាត ជាកុមារ និងធ្វើការកើបអាចម៍គោដើម្បីធ្វើជី ។ នៅថ្ងៃមួយគាត់ត្រូវ បានចោទប្រកាន់ពីបទលួចទឹកត្នោតជីក ។ ម៉ី និយាយថាខ្មែរក្រហមបានវាយពូរបស់ខ្លួនស្ទើរតែកម្រើកខ្លួនមិនរួច បន្ទាប់មកខ្មែរក្រហម ចាប់គាត់ចងដើងព្យួរឡើងលើដើម្បីបង្ហាញឲ្យប្រជាជនមើល ។ ចាប់តាំងពីពេលនោះមក ភ្នែករបស់គាត់អាចមើលឃើញព្រិលៗ ហើយអាចធ្វើតែកិច្ចការណាស្រាលៗប៉ុណ្ណោះ ។ រាល់លើកនៅពេលដែល រូសាត ព្យាយាមរំឭកពីប្រវត្តិជូរចត់របស់ខ្លួន គាត់តែងស្រក់ទឹកភ្នែកជានិច្ច ។

នៅពេលសួរពីសាលាក្តីខ្មែរក្រហម ម៉ី បានបញ្ជាក់ពីគំនិតច្របូកច្របល់គ្នា ។ ម៉ី ចង់ដឹងការពិតពីអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នោះ ហើយនាងសប្បាយចិត្តការដែលអង្គការសហប្រជាជាតិកំពុងជួយប្រទេសកម្ពុជា ព្រោះថាបន្ទាប់មកអ្វីៗនឹងប្រព្រឹត្តទៅតាមបញ្ញត្តិច្បាប់ ។ នៅពេលសួរថាតើអ្នកណាខ្លះគួរតែត្រូវទទួលការកាត់ទោស ម៉ី និយាយថាពិបាកនិយាយឆ្លើយណាស់ ព្រោះនៅពេលនោះមនុស្សជាច្រើនបានធ្វើតាមបញ្ជាគេ ហើយអ្នកទាំងនោះនឹងមានគ្រោះថ្នាក់ប្រសិនបើមិនស្តាប់បញ្ជា គឺមេដឹកនាំដែលជាអ្នកចេញបទបញ្ជា ឬគំនិតក្នុងការធ្វើទារុណកម្ម ឬសម្លាប់មនុស្ស ។ ម៉ី បង្អង់បន្តិច បន្ទាប់មកនិយាយថា ខ្លួនក៏មិនច្បាស់ថាយុត្តិធម៌នឹងមានសម្រាប់ជនរងគ្រោះទេ ដោយលើកហេតុផល អំពើប្រល័យពូជសាសន៍បានកើតឡើងយូរមកហើយ និងថាវាមានឧបសគ្គជាច្រើនក្នុងដំណើរការតុលាការនេះ ។ ម៉ី សង្ឃឹមថា នឹងមិនមានការពន្យារពេលទៀតទេ និងសង្ឃឹមថាមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញនឹងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីស្វែងរកការពិតជូនប្រជាជនដែលកំពុងរង់ចាំស្តាប់នូវសវនាការដំបូង ។ ចំពោះ ម៉ី យល់ថា ប្រសិនបើតុលាការនេះដំណើរការទៅបានសម្រេច វានឹងផ្តល់នូវយុត្តិធម៌ដល់ជនរងគ្រោះតែបន្តិចបន្តួចប៉ុណ្ណោះ ព្រោះថាយុត្តិធម៌នឹងមិនអាចលុបបំបាត់ការឈឺចាប់ដែលជនរងគ្រោះបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមនោះទេ “វានឹងនៅតែដក់ជាប់ក្នុងចិត្តរបស់ជនរងគ្រោះជានិច្ច” ។

យុវនិស្សិតអាយុ២១ឆ្នាំ សុខ វាសនា ក៏មានការគិតទុកជាមុនពីសាលាក្តីខ្មែរក្រហមដែរ ។ ដូចគ្នានិង លី ម៉ី, វាសនា ធ្លាប់ឮព័ត៌មានពីសាលាក្តីខ្មែរក្រហម ។ បន្ទាប់ពីបានស្តាប់ការផ្សាយតាមវិទ្យុនៅពេលថ្មីៗនេះ វាសនា យល់ថាបញ្ហាដែលសាលាក្តីដែលកំពុងជួបប្រទះមិនមែនបញ្ហាថវិកាទេ គឺបញ្ហាដែលភាគីទាំងសងខាង(ខ្មែរនិងបរទេស)ត្រូវសហប្រតិបត្តិការគ្នា ។ វាជាការពិបាកសម្រាប់ភាគីទាំងពីរក្នុងការធ្វើការជាមួយគ្នាដោយយោងលើហេតុផលមួយចំនួន ដែលជាហេតុធ្វើឲ្យភាគីត្រូវចំណាយពេលច្រើនដើម្បីស្រុះស្រួលគ្នាក្នុងការបំពេញភារកិច្ច ។ ចំណែកមួយនៃបញ្ហានេះគឺការស្វែងយល់ពីអ្វីដែលបានកើតឡើងនៅក្នុងរបបប៉ុលពត ។ ពីដំបូង វាសនា គិតថាការមកទស្សនាសារមន្ទីរទួលស្លែងគឺជាការធម្មតាមួយសម្រាប់ខ្លួន ។ នៅពេលដើរឆ្លងកាត់ខ្លោងទ្វារដំបូង វាសនា មានអារម្មណ៍ធម្មតាដូចសព្វដង ។ ប៉ុន្តែពេលដើរចូលដល់អគារមន្ទីរនិងបានឃើញរូបថតនៅតាមបន្ទប់នីមួយៗ វាសនា ចាប់ផ្តើមអួលដើមក ខំទប់អារម្មណ៍ និងទប់ទឹកភ្នែកដែលបម្រុងនឹងហូរធ្លាក់មក ។ វាសនា នឹកឃើញដល់ជីដូននិងជីតារបស់ខ្លួនដែលមិនធ្លាប់បានឃើញមុខសោះ ប៉ុន្តែបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។

វាសនា ធ្លាប់បានឮពីរបបប្រល័យពូជសាសន៍នេះតាមរយៈការរៀបរាប់ប្រាប់ពីឪពុកម្តាយកាលពីខ្លួននៅក្មេង ។ ឪពុករបស់ វាសនា ប្រាប់ថា អំឡុងពេលនោះគឺជាពេលដែលពិបាកបំផុតនៅក្នុងជីវិតរបស់គាត់ ពីព្រោះគាត់គ្មានសិទ្ធិសេរីភាព គ្មានអាហារ ហើយសូម្បីតែអំបិលញ៉ាំក៏គ្មានដែរ ។ ឪពុករបស់ វាសនា ត្រូវបានបង្ខំឲ្យទៅធ្វើការនៅកងកុមារ ហើយគាត់ត្រូវក្រោកពីព្រលឹមរៀងរាល់ថ្ងៃដើម្បីទៅធ្វើការ ។ នៅពេល វាសនា អាយុបាន១៨ឆ្នាំ គ្រូបង្រៀនក៏បាននិទានពីប្រវត្តិរបស់គាត់នៅក្នុងសម័យខ្មែរក្រហមប្រាប់ដែរ ហើយខ្លួនចាប់អារម្មណ៍យ៉ាង

ខ្លាំងនៅក្នុងជំពូកនៃប្រវត្តិសាស្ត្រកម្ពុជានេះ ។ ចំណែក ឯល យ៉ាគីន អាយុ២០ឆ្នាំ មានយោបល់ថា នាងចង់ឲ្យមានការបញ្ចូលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីអប់រំថ្នាក់ជាតិ ពីព្រោះនេះជាមធ្យោបាយមួយដើម្បីទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតមានម្តងទៀត ។


យុវជនចាមមុស្លីមនិងយុវនិស្សិតច្បាប់នៅក្នុងបន្ទប់សវនាការ

បន្ទាប់ពីបានទស្សនាសារមន្ទីរទួលស្លែងរួចហើយ យុវនិស្សិតទាំងនោះបានបន្តដំណើរទស្សនកិច្ចទៅបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជើងឯក ។ យុវជនចាមមូស្លីមបានដើរបែកខ្ញែកគ្នាជាក្រុមៗដើម្បីដើរមើលជុំវិញវាលពិឃាដនោះ ។ រយៈពេល៤៥នាទីក្រោយមក ហ្សារីណា បានហៅអ្នកទាំងអស់ឲ្យមកជួបជុំគ្នានៅកន្លែងសម្រាក ដើម្បីពន្យល់អំពីគម្រោងដល់អ្នកចូលរួមទាំងអស់ ។ គម្រោងនេះជាផ្នែកមួយនៃគម្រោងស្រាវជ្រាវទាំងមូលស្តីពីសហគមន៍ចាមមូស្លីមនិងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ហ្សារីណា និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកគារាងស្ទង់មតិដែលមានសំណួរជាច្រើនទាក់ទងនឹងរបបខ្មែរក្រហម ការយល់ដឹងអំពីយុត្តិធម៌ និងយោបល់ជុំវិញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ។ លើសពីនេះទៀត ដោយសង្ឃឹមថា នឹងទាក់ទាញចំណាប់អារម្មណ៍នៅក្នុងរបបខ្មែរក្រហមនិងជំរុញឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងឪពុកនិងកូនលើប្រធានបទនេះ ហ្សារីណា បានពិភាក្សាជាមួយក្រុមយុវជនអំពីការប្រកួតប្រជែងក្នុងការចងក្រងសាច់រឿងជាអត្ថបទ ។ បន្ទាប់មកបានប្រគល់សៀវភៅមួយក្បាលនិងប៊ិចមួយដើមដល់យុវជនម្នាក់ៗ ។ យុវជនទាំងអស់ត្រូវបានស្នើឲ្យសរសេរសាច់រឿងស្តីពីបទពិសោធន៍របស់ឪពុកម្តាយខ្លួនក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដោយមិនមានកំណត់ទំព័រ ។ សាច់រឿងដែលជាប់ចំណាត់ថ្នាក់នឹងចុះផ្សាយក្នុងទស្សនាវដ្តីសម្រាប់សហគមន៍ប្រចាំត្រីមាសនិងលេខបន្តបន្ទាប់ទៀត ។ បន្ទាប់មកយុវសិស្សនិស្សិតម្នាក់ៗទទួលបានទស្សនាវដ្តីស្វែងរកការពិតមួយច្បាប់សម្រាប់អានដើម្បីឲ្យយល់ដឹងពីសាច់រឿងរបស់អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ សិស្សទាំងអស់ហាក់ដូចជារំភើបចិត្តនៅពេលស្តាប់ពីគម្រោងនេះហើយថែមទាំងបានសួរសំណួរជាច្រើនមកកាន់អ្នកដឹកនាំគម្រោង ។ ហ្សារីណា បានបកស្រាយនូវចម្ងល់ទាំងឡាយហើយបានពន្យល់បន្ថែមដើម្បីឲ្យសិស្សទាំងអស់រឹតតែងាយយល់ ។

នៅថ្ងៃទី២ និស្សិតច្បាប់និងយុវជនចាមមូស្លីម បានជួបជុំគ្នានៅបន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រុមនិស្សិតត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីមន្ត្រីទំនាក់ទំនងកិច្ចការសាធារណៈ មាន លោក រាជ សម្បត្តិ, លោកស្រី ជា លាង សហព្រះរាជអាជ្ញាខ្មែរ, និងកញ្ញា ជាមេឡារីស្ស ជាជំនួយការជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា ។ វាគ្មិនកិត្តិយសបានបកស្រាយលើប្រធានបទផ្សេងៗគ្នាទាក់ទិននឹងសាលាក្តីខ្មែរក្រហមនិងបានឆ្លើយនូវសំណួរជាច្រើនរបស់ក្រុមនិស្សិតផងដែរ ។

*ការប្រជុំចាប់ផ្តើមនៅម៉ោង៩:១៥នាទី ចម្រៀងចាប៉ីដងវែងបន្លឺឡើងមុនពេលលោក រាជ សម្បត្តិ ស្វាគមន៍ការមកដល់របស់និស្សិត ។ លោក រាជ សម្បត្តិ, ចិន ហែមវិចិត្រ (ជំនួយការលោក រាជ សម្បត្តិ) និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកកូនសៀវភៅពណ៌ទឹកប៊ិកស្តីពីសំណួរចម្លើយជុំវិញសាលាក្តីខ្មែរក្រហមដល់និស្សិតទាំងអស់ ។ បន្ទាប់មកលោក រាជ សម្បត្តិ ចាប់ផ្តើមនិយាយអំពីរចនាសម្ព័ន្ធសវនាការនិងផ្នែកផ្សេងៗរបស់អង្គជំនុំជម្រះវិសាមញ្ញនិងនិយាយពីការវិវត្តន៍ថ្មីៗរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយក៏បានពន្យល់អំពីផ្ទាំងរូបភាពផ្សព្វផ្សាយទាំង ៤ ដែលមានលោក ភីធ័រ ហ៊ុសទ័រ (មន្ត្រីកិច្ចការសាធារណៈតំណាងឲ្យខាងអង្គការសហប្រជាជាតិ) ជាអ្នកលើកបង្ហាញ ។ លោក រាជ សម្បត្តិ បានចោទសួរនិស្សិតបីបួនសំណួរដែលជាសំណួរកូនៗរបស់គាត់តែងតែសួរ ។ សំណួរទី១ "ប្រសិនបើប៉ុលពត បងប្អូនតែបបរ រាវៗរាល់ថ្ងៃ តើមានកម្លាំងឯណាដឹកប្រឡាយបានជ្រៅម្ល៉េះ?" សិស្សនិស្សិតជាច្រើននាំគ្នាសើចនៅពេលឮសំណួរនេះ ។ សំណួរមួយទៀតសួរថា "នៅពេលដែលគេធ្វើឲ្យយើងឈឺនិងវាយដំអ្នក ហេតុអីបានជាយើងមិនតដៃ?" ជាថ្មីម្តងទៀតនិស្សិតទាំងអស់នាំគ្នាសើចតិចៗ ។ ការណ៍នេះប្រហែលមកពីពួកគេធ្លាប់សួរសំណួរទាំងនេះដល់ឪពុកម្តាយរបស់ខ្លួនក្រោយពីស្តាប់រឿងរ៉ាវប្រល័យពូជសាសន៍រួច ។ លោក សម្បត្តិ បានពន្យល់បន្ថែមទៀតអំពីការលំបាកទាក់ទិននឹងការគេចវេះប្តូរបតរបស់កម្មាភិបាលខ្មែរក្រហម ។*

*ដោយមានសំណួរត្រៀមទុកជាស្រេច និស្សិតកម្ពុជាបានដើរតម្រង់ទៅក្បាលមីក្រូហ្វូន និយាយណែនាំខ្លួនថ្លែងអំណរគុណដល់វាគ្មិននិងចោទជាសំណួរឡើង ។ ឡាយ ប៊ុន្នី និស្សិតច្បាប់និងជាអ្នកដឹកនាំក្រុមនិស្សិតមកពីសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានសួរសំណួរមុនគេបង្អស់ ។ ប៊ុន្នី បានចាប់ផ្តើមសង្ខេបសេចក្តីដែលដកស្រង់ចេញពីវិទ្យុ* ***FM93.5MHz*** *ទាក់ទងនឹងការពន្យារពេលសម្រេចវិធានផ្ទៃក្នុង ។ ប៊ុន្នី ចង់ដឹងថាតើការពន្យារពេលជាលទ្ធផលនៃអំពើពុករលួយនិងអសមត្ថភាពក្នុងការសហការគ្នារវាងចៅក្រមជាតិនិងអន្តរជាតិដូចដែលកម្មវិធីវិទ្យុខាងលើបានផ្សព្វផ្សាយមែនឬទេ? លោក ជូស៊ុរ បានឆ្លើយតបនឹងសំណួរនេះថា ក្នុងរយៈពេលដ៏ខ្លីនេះចៅក្រមទាំងសងខាងនឹងជួបគ្នានៅការិយាល័យរដ្ឋបាលដើម្បីពិភាក្សាវិធានផ្ទៃក្នុង ហើយ បញ្ហាជាច្រើននឹងត្រូវបានដោះស្រាយនៅចុងសប្តាហ៍នេះ ហើយនៅថ្ងៃទី១៦ ខែមីនានេះនឹងមានសន្និសីទកាសែតមួយ ដើម្បីពិភាក្សាពីលទ្ធផលនៃការប្រជុំ ។ សំណួរជាច្រើនទៀតបានចោទសួរអំពីនិយមន័យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ហេតុអ្វីបានជាច្បាប់កម្ពុជានិងច្បាប់អន្តរជាតិចាំបាច់ច្របាច់បញ្ចូលគ្នាដើម្បីអនុវត្តជាជាងប្រើប្រាស់ច្បាប់អន្តរជាតិសុទ្ធដូចករណីតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងកាលៈទេសៈផ្សេងៗទាក់ទិននឹងការមិនយល់ស្របរវាងចៅក្រមជាតិនិងអន្តរជាតិ ។*

*និស្សិតម្នាក់សួរសំណួរដាច់ដោយឡែកពីសំណួរខាងលើដោយបង្ហាញថា តុលាការខ្មែរក្រហមដូចដែលមានឈ្មោះជាផ្លូវការថា "អង្គជំនុំជម្រះវិសាមញ្ញ" បង្កើតឡើងដើម្បីវិនិច្ឆ័យទោសអតីតមេដឹកនាំខ្មែរក្រហម ។ ហេតុដូច្នេះ តើយើងគួរបង្កើតតុលាការមួយទៀតដើម្បីកាត់ក្តីរវាងប្រទេសនិងប្រទេសប្តូជនបរទេសដែលបានគាំទ្ររបបខ្មែរក្រហម ហើយតាមរយៈនេះវាអាចជួយរកយុត្តិធម៌ដល់ការស្លាប់បាត់បង់ជីវិតមនុស្សជិតពីរលាននាក់ដែរឬទេ?*

*នៅវេលាម៉ោង១០ព្រឹក លោកស្រី ជា លាង និង លោកស្រី ផាម៉េឡា រីស បានអញ្ជើញមកដល់ ។ លោកស្រី ជា លាង បាននិយាយដោយសង្ខេបអំពីច្បាប់កម្ពុជានិងកំណាកំណើតតុលាការខ្មែរក្រហម ។ ហើយសង្កត់ធ្ងន់ថា តុលាការនេះគឺរដ្ឋាភិបាលកម្ពុជាជាអ្នកស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ហេតុដូច្នេះហើយវាមិនសមហេតុផលសម្រាប់ភាគីកម្ពុជាក្នុងការបង្អាក់ដំណើរតុលាការដោយចេតនាឡើយ ។ ភាគីទាំងសងខាងកំពុងធ្វើការយ៉ាងសកម្មនិងស្វែងយល់ពីគ្នាទៅវិញទៅមក ។ លោកស្រី រីស បានបញ្ជាក់ឡើងវិញថា ភាគីកម្ពុជានិងអន្តរជាតិកំពុងធ្វើសហប្រតិបត្តិការគ្នាយ៉ាងស្អិតល្មួត ។*

*បន្ទាប់ពីនិយាយដោយសង្ខេប វាគ្មិនទាំងបីនាក់បានអនុញ្ញាតឲ្យសិស្សនិស្សិតទាំងអស់សួរសំណួរ ។*

*សំណួរផ្សេងៗដែលលើកឡើងគឺដូចគ្នានឹងសំណួរពីមុន និងសំណួរដែលអ្នកចូលរួមដំណើរទស្សនកិច្ចមុនៗបានសួរ ។ សំណួរ*

ទាំងនោះរួមបញ្ចូលទាំងសន្តិសុខមន្ទីរស–២១ ដំណើរការស៊ើបអង្កេត ពេលវេលាសម្រាប់ការកាត់ក្តី ច្បាប់ខ្មែរក្រហម ការដាក់ទណ្ឌកម្មនិងការកាត់ទោស តើព្រះរាជអាជ្ញាបានជួបនិយាយជាមួយមេដឹកនាំខ្មែរក្រហមហើយឬនៅ? តើអ្នកដែលជាប់ចោទនឹងត្រូវនាំទៅកាន់កន្លែងឃុំឃាំងដោយរបៀបណា? តើមានជម្រើសអ្វីខ្លះដែលត្រូវបានផ្តល់ដល់ចុងចោទប្រសិនបើចុងចោទមិនយល់ស្របនឹងសាលក្រមតុលាការ តើតុលាការនេះអាចក្លាយជាតុលាការគំរូដែរឬទេ? លោកស្រី ជា លាង និង លោកស្រី រីស មានការរីករាយក្នុងការឆ្លើយសំណួររបស់សិស្ស–និស្សិត ។

ការប្រជុំបានកំណត់ចប់នៅម៉ោង១១ព្រឹក សិស្ស–និស្សិតចង់សួរសំណួរជាច្រើនទៀត ប៉ុន្តែដោយសារវាគ្មិនទាំងបីមិនមានពេលវេលាក្នុងការឆ្លើយបន្តទៅទៀតបាន លោកស្រី ជា លាង បានមានប្រសាសន៍បញ្ចប់ការប្រជុំ ។ ចុងបញ្ចប់ លោក រាជ សម្បត្តិ បានដឹកនាំក្រុមនិស្សិតទាំងអស់ឲ្យទស្សនារូបចម្លាក់លោកតាដំបងដែកនៅពីចំហៀងអគារសវនាការ ។

កិច្ចសម្ភាសន៍ចុងក្រោយធ្វើឡើងដោយក្រុមកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមុនពេលនិស្សិតច្បាប់ឡើងរថយន្តក្រុងត្រឡប់មកវិញ ។ ឡាំ ចិន្តា អាយុ២៣ឆ្នាំ ជានិស្សិតច្បាប់មកពីសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានប្រាប់ថា នាងចាប់អារម្មណ៍ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាំងពីពេលដែលឪពុកម្តាយនិងសាច់ញាតិរបស់គាត់និយាយរៀបរាប់អំពីបទពិសោធន៍នៅក្នុងរបបនោះ ។ ចិន្តា ធ្លាប់អានអត្ថបទទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយថ្មីៗនេះនាងចាប់អារម្មណ៍អំពីតុលាការខ្មែរក្រហម ។ ចិន្តាសង្ឃឹមថា សវនាការនឹងប្រព្រឹត្តទៅតាមច្បាប់ ហើយអ្នកដែលធ្វើការនៅក្នុងតុលាការនេះនឹងប្រឹងប្រែងធ្វើការដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។ ចិន្តា បន្ថែមថា ការអប់រំពីអំពើប្រល័យពូជសាសន៍គឺចាំបាច់ខ្លាំងណាស់ ដើម្បីទប់ស្កាត់ប្រល័យពូជសាសន៍កុំឲ្យវិលមកវិញ ។ នាងចង់ដឹងយ៉ាងខ្លាំងថា ប្រសិនបើសាច់ញាតិរបស់សហព្រះរាជអជ្ញាឬមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញផ្សេងទៀតមានជាប់ពាក់ព័ន្ធនឹងរឿងក្តី តើពួកគេនៅតែបន្តកិច្ចការរបស់ខ្លួនដោយគ្មានការផ្លាស់ប្តូរឬដាក់កម្រិតផ្សេងៗឬយ៉ាងណា ។

សម្រាប់យុវជនចាមមូស្លីមប្រហែល៩០នាក់ដែលបានចូលរួមប្រជុំនៅសវនាការអង្គជំនុំជម្រះវិសាមញ្ញនេះ បានបន្តទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទៀត ។ សិស្សនិស្សិតទាំងនោះមានឱកាសជួបជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងបានទស្សនាខ្សែភាពយន្ត «នៅកៀនជញ្ជាំងមន្ទីរសន្តិសុខ



យុវជនចាមមូស្លីមកំពុងសួរសំណួរទៅកាន់លោកស្រីសហព្រះរាជអាជ្ញា

ស–២១» ផលិតដោយលោក ឆាំង យុ, ដឹកនាំដោយ លោក ដាក កាស និងនិយាយរៀបរាប់ដោយ លោក រ៉ូឡង់ ជូហ្វ ។ ភាពយន្តឯកសារនេះបង្ហាញពីអតីតអ្នកទោសនៅមន្ទីរស–២១ និងអតីតសន្តិសុខជាន់ខ្ពស់ ដែលសាច់រឿងរបស់អ្នកទាំងនោះពាក់ព័ន្ធគ្នា ហើយភាគច្រើនមានទំនាស់គ្នាទៅវិញទៅមក ។ តាមរយៈខ្សែភាពយន្តឯកសារ យើងអាចដឹងអំពីរឿងរ៉ាវដែលអតីតអ្នកទោសទាំងពីរត្រូវបានចាប់ខ្លួនបញ្ចូលមកមន្ទីរស–២១ ទារុណកម្មដែលពួកគាត់ទទួលរងនិងវិធីដែលពួកគាត់អាចរស់រានពីភាពឃោរឃៅនិងការអត់ឃ្លាននៅក្នុងមន្ទីរសន្តិសុខ ។

សាច់រឿងនោះធ្វើឲ្យមានការចោទសួរគ្នាអំពីឆ្នាំគុកជាន់ខ្ពស់របស់ខ្មែរក្រហមដែលអះអាងថា សកម្មភាពទាំងឡាយរបស់ខ្លួនមិនមានអ្វីលើសពីការកិច្ចយាមកាមអ្នកទោសឡើយ ។ ខ្សែភាពយន្តនេះក៏អាចឲ្យទស្សនិកជនគិតពីបញ្ហាដែលមិនមានការបែងចែកច្បាស់លាស់រវាងជនរងគ្រោះនិងជនដៃដល់ខណៈពេលដែល



សាច់រឿងសង្កត់ធ្ងន់ទៅលើការតស៊ូដែលយើងមិនសង្ឃឹមថាអ្នកទោសខ្លះនឹងអាចរស់រានមានជីវិតពីមន្ទីរសន្តិសុខនេះ ។

សរុបមក ដំណើរទស្សនកិច្ចដែលរួមមានយុវជនចាមមូស្លីមនិងនិស្សិតច្បាប់ដំណើរការទៅដោយរលូន ទាំងនិស្សិត និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសហការគ្នាធ្វើឲ្យដំណើរទស្សនកិច្ចនេះទទួលបានជោគជ័យ ។ ដំណើរទស្សនកិច្ចលើកនេះនិងលើកមុនបានផ្តល់ឱកាសឲ្យយុវជនជាច្រើនចូលរួមបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនអំពីអតីតកាលនិងតុលាការខ្មែរក្រហម ។ ដូច្នេះយុវជនគួរតែត្រូវបានផ្តល់ឲ្យនូវឱកាសដើម្បីរៀនសូត្រអំពីអតីតកាលរបស់ប្រទេស ។ ការនាំយុវជនទៅកាន់សារមន្ទីរទួលស្លែង បូជនីយដ្ឋានប្រល័យពូជសាសន៍ជើងឯក និងអង្គជំនុំជម្រះវិសាមញ្ញគឺជាឱកាសដ៏មានតម្លៃសម្រាប់យុវជនក្នុងការរៀនសូត្រនិងស្វែងយល់អំពីអ្វីដែលបានកើតឡើងនៅក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត ការលើកទឹកចិត្តគឺមានសារសំខាន់ណាស់ក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍ ។ ការប្រឡងប្រជែងក្នុងការតែងនិពន្ធដែលស្ថិតនៅក្រោមគម្រោងប្រវត្តិសាស្ត្រចាមមូស្លីមអាចជំរុញឲ្យយុវជនដែលកើតក្រោយរបបខ្មែរក្រហមមានឱកាសនិយាយជាមួយអ្នករស់រានមានជីវិតអំពីបទពិសោធន៍របស់ពួកគេដោយផ្ទាល់ ។ សៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩» ដែលរៀបរៀងលោក ឌី ខាំបូលី បុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងក្លាយជាសៀវភៅយោងដ៏សំខាន់សម្រាប់យុវជនសិក្សារៀនសូត្រអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសន្ទនាជាមួយឪពុកម្តាយនិងការរៀនសូត្រពីមេរៀនក្នុងថ្នាក់នឹងជួយឲ្យយុវជនរកឃើញរឿងរ៉ាវខ្មោងងឹតនៃប្រវត្តិសាស្ត្រកម្ពុជាគឺប្រល័យពូជសាសន៍នៅក្រោមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមិនអាចបំភ្លេចនិងអត់ឱនឲ្យបាន ។

**កែវ ជាស៊ីល**

# ដំណឹងស្វែងរកមិត្តភក្តិ

ខ្ញុំបាទឈ្មោះ ម៉ាត់ សាលីម ហៅ លីម អាយុ៤៥ឆ្នាំ រស់នៅភូមិបារ៉ែនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ។

សូមស្វែងរកឈ្មោះ បងវ៉ា, បងធី, បងរ៉ា ដែលធ្លាប់ធ្វើការជាមួយខ្ញុំនិងបងស្រីខ្ញុំឈ្មោះ ម៉ាត់ ស្រីម៉ាស់ នៅសហករណ៍ព្រែកប្បាសចង្ហារ) ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧៦ ពួកគាត់ត្រូវប្រធានកងដាក់ទិសឲ្យទៅធ្វើការនៅសហករណ៍ផ្សេងទៀត តាំងពីពេលនោះមកយើងមិនដែលជួបគ្នាសោះ ។

ប្រសិនបើបងៗទាំងបីបានឮឬញាតិមិត្តបានស្គាល់ឈ្មោះខាងលើ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# ស្លាប់ដោយសារអង្ករ

*នៅពេលទទួលទានបាយម្តងៗ កូប ម៉ាត់ តែងតែរំឭកប្រាប់កូនៗរបស់គាត់អំពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ ម៉ាត់ ប្រាប់កូនថា "ដោយសារតែអាហារនេះហើយដែលធ្វើឲ្យប៉ាព្រាត់ប្រពន្ធជាទីស្រឡាញ់រហូតមកដល់សព្វថ្ងៃនេះ ហើយជីវិតរបស់ប៉ាត្រូវរងទុក្ខវេទនាស្ទើរស្លាប់ស្ទើររស់" ។*

មុនឆ្នាំ១៩៧៥ កូប ម៉ាត់ រស់នៅជួបជុំប្រពន្ធកូននៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។ ក្រុមគ្រួសាររបស់ ម៉ាត់ រស់នៅក្នុងភូមិដដែលរហូតដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារគាត់និងអ្នកភូមិចាមលើទៅភូមិកំពង់សំបួរ ខេត្តកណ្តាល ។ ខ្មែរក្រហមបានបំបែកជនជាតិចាមជាក្រុមតូចៗ ហើយដាក់ឲ្យរស់នៅលាយឡំគ្នាជាមួយជនជាតិខ្មែរ ។ ម៉ាត់ រស់នៅក្នុងសហករណ៍កំពង់សំបួរជាមួយក្រុមគ្រួសារ ប៉ុន្តែគាត់ត្រូវចាត់តាំងឲ្យទៅភ្ជួរដីដាំអំពៅនិងធ្វើស្រែចម្ការ ។

នៅរដូវនេសាទ គាត់ត្រូវចាត់តាំងឲ្យចុះទៅនេសាទត្រី ។ ប្រពន្ធរបស់ ម៉ាត់ ចូលក្នុងក្រុមធ្វើអង្ករជាមួយនារីដទៃទៀតនៅភូមិកំពង់សំបួរ ។ ចំណែកកូនទាំង៥នាក់ធ្វើការនៅក្នុងកងចល័តយុវជននិងកងកុមារ ។ គ្រួសាររបស់ ម៉ាត់ ទទួលបានបាយលាយពោតតិចតួចសម្រាប់មួយថ្ងៃៗ ។ ដោយសារអាណិតកូនហូបមិនឆ្អែត ប្រពន្ធរបស់ ម៉ាត់ បានលួចវេចខ្ចប់អង្ករពីកន្លែងធ្វើអង្ករដើម្បីដាំបបរឲ្យកូនៗហូប ។ ប៉ុន្តែអ្នកធ្វើការក្នុងក្រុមជាមួយគ្នាម្នាក់បានឃើញហេតុការណ៍នេះ ហើយក៏លួចរាយការណ៍ប្រាប់អង្គការ ។ ភ្លាមៗនោះ ប្រពន្ធរបស់ ម៉ាត់ ក៏ត្រូវអង្គការចុះមកស្នើយកទៅធ្វើការនៅព្រែកដូង ។ ប្រពន្ធរបស់ ម៉ាត់ មិនបានជួបមុខ ម៉ាត់ ឡើយ បានត្រឹមតែស្រែកផ្តាំអ្នកជិតខាងថា អង្គការយកគាត់ទៅធ្វើការនៅកន្លែងផ្សេងហើយ សុំឲ្យអ្នកជិតខាងជួយមើលកូនៗរបស់គាត់ផង រួចហើយឈ្លបក៏បណ្តើរគាត់ចេញទៅ ។ ម៉ាត់ ឡើងមកពីភ្ជួរវិញក៏ជ្រួសជ្រាវជាមួយប្រពន្ធ ។ ក្រោយពីទទួលដំណឹងពីអ្នកជិតខាងភ្លាម ម៉ាត់ ក៏រត់ទៅតាមប្រពន្ធ ប៉ុន្តែតាមមិនទាន់ព្រោះឈ្លបបាននាំប្រពន្ធរបស់គាត់ឆ្លងទូកទៅត្រើយម្ខាងទន្លេបាត់ទៅហើយ ។ ម៉ាត់ មិនបានឃើញខ្មែរក្រហមសម្លាប់ប្រពន្ធរបស់គាត់ផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់ដឹងច្បាស់ថាប្រពន្ធរបស់គាត់ត្រូវអង្គការយកទៅសម្លាប់ហើយ ព្រោះតាំងពីពេលនោះមក ប្រពន្ធរបស់ ម៉ាត់ មិនដែលឃើញត្រឡប់មកវិញឡើយ ។

ក្រោយពីខ្មែរក្រហមយកប្រពន្ធរបស់ ម៉ាត់ ទៅ ស្ថានភាពរស់នៅរបស់ ម៉ាត់ កាន់តែលំបាកជាងមុនដោយខ្មែរក្រហមចាត់ឲ្យគាត់ធ្វើការងារច្រើន ហើយតាមដានគាត់ជាប់ជានិច្ច ។ ប្រហែលឆ្នាំ១៩៧៧ ម៉ាត់ ត្រូវអង្គការចាត់ចាត់ឲ្យទៅរំងាស់ទឹកត្នោតធ្វើស្ករ ដែលមានមនុស្សប្រហែល១០នាក់ក្នុង១ក្រុម ។ ម៉ាត់ ត្រូវដាក់កម្រិតឲ្យអាររណៀនិងរកខសឲ្យបានមួយរទេះក្នុងមួយថ្ងៃ ដើម្បីដុតរំងាស់ទឹកត្នោត ។ នៅទីនោះទំនាក់ទំនងរវាងគ្នានឹងគ្នាមានការលំបាកព្រោះមនុស្សម្នាក់ៗត្រូវប្រឹងប្រែងធ្វើការរៀងខ្លួន លើសពីនេះអង្គការមិនអនុញ្ញាតឲ្យមានការជជុំគ្នាលើសពី២នាក់ឡើយ ។ ការប្រតិបត្តិសាសនាអ៊ីស្លាមក៏ដូចជាសាសនាព្រះពុទ្ធត្រូវបានហាមឃាត់ដែរ ។ ម៉ាត់ រំឭកថា គាត់មិនហ៊ាននិយាយភាសាចាមជាមួយកូនរបស់គាត់ទេ ហើយកូនៗក៏មិនហ៊ានងាកមើលមុខគាត់ដែរ ។ ម៉ាត់ និយាយថា *"ខ្ញុំស្រែកហៅវាថា អាលីៗ វាអត់ងាកសោះ វាសុខចិត្តខិនដើរត្រុកៗ ។ វាខ្លាចគេ (ខ្មែរក្រហម) ដល់ថ្នាក់ហ្នឹង ។ គិតទៅសង្គមហ្នឹងសាហាវណាស់ សូម្បីមនោសញ្ចេតនាឪពុកនិងកូនក៏ត្រូវកាត់ផ្តាច់"* ។ ម៉ាត់ មិនបានថ្វាយបង្គំព្រះតាមគោលការណ៍គ្រឹះទី២នៃសាសនាអ៊ីស្លាមទេ ព្រោះឈ្លបតាមដានគាត់និងគ្រួសារជនជាតិចាមដទៃទៀតដែលត្រូវបានចាត់ទុកជាប្រជាជនបញ្ញើ ។

នៅឆ្នាំដដែល ដោយសារមិនអាចទ្រាំនឹងការលំបាកបានប្រជាជនមួយចំនួនបាននាំគ្នាភៀសខ្លួនទៅប្រទេសវៀតណាម ។ អង្គការចាប់ផ្តើមស៊ើបរកចាប់ខ្លួនអ្នកដែលពាក់ព័ន្ធនឹងការ

បះបោរនេះ ។ ម៉ាត់ ត្រូវជាប់ចោទពីបទមានចេតនាលួចឆ្លងដែនទៅប្រទេសវៀតណាមខណៈពេលដែលគាត់និងអ្នកភូមិនិយាយគ្នានៅកន្លែងរំងាស់ទឹកត្នោត ។ ម៉ាត់ រៀបរាប់ថា គាត់មិនដែលមានបំណងរត់ទៅប្រទេសវៀតណាមម្តងណាទេ ។ គាត់ ត្រូវបានអង្គការនាំខ្លួនទៅឃុំនៅមន្ទីរសន្តិសុខឃុំព្រែកថ្មីនិងត្រូវសួរចម្លើយនៅទីនោះ ។ នៅមន្ទីរឃុំឃាំងបាន១០ថ្ងៃ សន្តិសុខគុកក៏ដោះលែង ម៉ាត់ ឲ្យទៅរែកដីនិងលើកទំនប់ទទឹងថ្ងៃ ។ សន្តិសុខគុកគំរាមគាត់ថា ប្រសិនបើគាត់រត់ចេញពីគុកនឹងត្រូវស្លាប់ ។ ម៉ាត់ និងអ្នកទោសម្នាក់ទៀតត្រូវអង្គការដាក់កម្រិតឲ្យរែកដីចាក់បំពេញប្លង់ដីមន្ទីរពេទ្យដែលមានបណ្តោយ១៥ម៉ែត្រ និងទទឹង៧ម៉ែត្រក្នុងរយៈពេល៧ថ្ងៃ ។ ម៉ាត់ ខិតខំធ្វើទាំងថ្ងៃទាំងយប់រហូតដល់សម្រេចមុនផែនការក្នុងរយៈពេលតែ៤ថ្ងៃប៉ុណ្ណោះ ។ ម៉ាត់ រំពឹកថា ប្រសិនបើគាត់ធ្វើការមិនបានគ្រប់ផែនការ អង្គការប្រហែលជាបញ្ជូនគាត់ទៅគុកពោធិ៍ទន្លេជាមិនខាន ។ គុកពោធិ៍ទន្លេជាកន្លែងលត់ដំនិងសម្លាប់មនុស្សយ៉ាងក្តៅគគុករបស់ខ្មែរក្រហម ។ «នៅរដូវទឹកឡើងពេលខ្ញុំទៅមុជទឹកនៅក្បាលស្ពានម្តងៗ ចិត្តខ្ញុំចង់តែរត់ ប៉ុន្តែចិត្តមួយអាណិតកូន ព្រោះបើខ្ញុំរត់ កូនៗរបស់ខ្ញុំនឹងត្រូវខ្មែរក្រហមសម្លាប់ ។ ដូច្នេះខ្ញុំចេះតែទ្រាំរស់ទាំងលំបាកនិងភ័យខ្លាច» ។

ម៉ាត់ មិនបានទទួលដឹងដំណឹងពីកូនៗរបស់គាត់ឡើយ ។ មិនយូរប៉ុន្មានកូនប្រុសរបស់គាត់អាយុប្រហែល៦ឆ្នាំដែលនៅជាមួយម្តាយខាងប្រពន្ធធ្លាក់ខ្លួនឈឺហើមដោយសារហូបមិនគ្រប់គ្រាន់ ។ ដោយគ្មានថ្នាំព្យាបាល កូនប្រុសរបស់គាត់ត្រូវស្លាប់ដោយគ្មានឪពុកម្តាយនៅក្បែរ ។

រយៈពេល៧ខែក្រោយមក ដោយឃើញ ម៉ាត់ អាចលត់ដំខ្លួនបានល្អ អង្គការក៏ដោះលែងឲ្យមករស់នៅក្នុងភូមិវិញ និងរៀបការ ម៉ាត់ ជាមួយនារីម្នាក់ដែលជនជាតិចាមដែរ (ប្រពន្ធរបស់គាត់សព្វថ្ងៃ) ដោយគ្រាន់តែឡើងប្តេជ្ញាថានឹងយកគ្នាជាប្តីប្រពន្ធនិងសម្រេចផែនការរបស់អង្គការឲ្យបាន៣តោនក្នុងមួយហិកតា ។ ដោយគិតថាការប្តេជ្ញាបែបនេះមិនសមស្របតាមច្បាប់សាសនាអ៊ីស្លាម ម៉ាត់ និងប្រពន្ធបានលួចធ្វើពិធីនីកាស (ចាស់ទុំទាំងសងខាងដឹងព្រមនិងទទួលស្គាល់តាមសាសនាអ៊ីស្លាម) នៅផ្ទះឪពុកម្តាយក្មេកនៅភូមិខ្ពុល ។

ម៉ាត់ រៀបការបាន៧ខែ កងទ័ពវៀតណាមក៏ចូលមករំដោះប្រទេសកម្ពុជា ។ ក្រុមគ្រួសាររបស់ ម៉ាត់ វិលត្រឡប់មកស្រុកកំណើតវិញ ។ ក្រោយមក ម៉ាត់ បានជួបមនុស្សដែលយកគាត់ទៅដាក់គុកនិងយកប្រពន្ធរបស់គាត់ទៅសម្លាប់ ហើយគាត់ថែមទាំងបានគំរាមថា «មនុស្សនៅស៊ីបាយជាមួយគ្នាសោះ ឯងមិនគួរចាប់អញដាក់គុក ហើយយកប្រពន្ធអញទៅវាយចោលទៀត ។ គង់ថ្ងៃណាមួយអញនឹងយកឯងទៅវាយចោលវិញទេ» ។ គ្រាន់តែព្រុំប៉ុណ្ណឹង បុរសនោះក៏រត់ចោលភូមិហើយបាត់ដំណឹងរហូតមកដល់សព្វថ្ងៃ ។ ម៉ាត់ និយាយថា «ខ្ញុំមិនមានគំនិតសងសឹកទេមកដល់ឥឡូវនេះ ប៉ុន្តែបើហេតុការណ៍នោះនៅថ្មីៗ ប្រហែលជាខ្ញុំមិនអាចរំសាយកំហឹងបានទេ» ។

ទោះបីរបបខ្មែរក្រហមផុតរលត់ទៅក៏ដោយ ប៉ុន្តែការចងចាំរបស់គាត់ចំពោះខ្មែរក្រហមដែលចោទគាត់ថាចង់រត់ទៅប្រទេសវៀតណាម ហើយយកគាត់ទៅដាក់គុកលត់ដំឲ្យធ្វើការធ្ងន់ៗនិងយកប្រពន្ធគាត់ទៅសម្លាប់ដោយសារហេតុផលអង្គរបន្តិចបន្តួចមិន ទាន់រលុបបាត់នៅឡើយ ។ ម៉ាត់ និយាយថា «ខ្ញុំឆ្ងល់ណាស់ យើងអត់ឃ្លានប៉ុណ្ណឹងហើយ គ្រាន់តែយកអង្ករដែលយើងធ្វើទៅដាំបបរឲ្យកូន ក៏អង្គការមិនលើកលែងឲ្យដែរ» ។

ម៉ាត់ រស់នៅជាមួយប្រពន្ធនិងកូនរបស់គាត់នៅភូមិចាមលើ ។ បងស្រីម្នាក់របស់ ម៉ាត់ បានស្លាប់មុនរបបខ្មែរក្រហមដោយសារដួលនៅលើទូកហើយត្រូវច្រវាវាយចំផ្ទៃពោះរបស់គាត់ពេលដែលគាត់កំពុងតែនេសាទត្រីជាមួយប្តី ។ ដោយសារជីវភាពលំបាក កូនប្រុសម្នាក់របស់ ម៉ាត់ ក៏ទៅស៊ីឈ្នួលនេសាទនៅប្រទេសថៃ ហើយបាត់ដំណឹងរហូតមិនដឹងថាស្លាប់ឬរស់ ។ ជាមួយមុខរបរនេសាទត្រីដែលទទួលបានប្រាក់កម្រៃតិចតួច ម៉ាត់ តស៊ូឲ្យកូនៗបានរៀនសូត្រទាំងអស់គ្នា ។

ម៉ាត់ ពេញចិត្តនឹងការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គាត់ចង់មានការកាត់ទោសទាំងខ្មែរក្រហមថ្នាក់ក្រោមដែលជាអ្នកប្រព្រឹត្តផ្ទាល់ផង ពីព្រោះអ្នកទាំងនោះជាអ្នកធ្វើឲ្យគាត់រងទុក្ខ ហើយធ្វើឲ្យប្រពន្ធនិងកូនរបស់គាត់ស្លាប់ ។

**សូ ហ្វារីណា**

# ការជម្លៀសប្រជាជន និង ការនិរទេសក្នុងប្រទេស

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានប្រឆាំងនឹងការជម្លៀសប្រជាជនទាំងហ្វូងៗ ប៉ុន្តែពុំបានថ្កោលទោសឲ្យច្បាស់នូវការជម្លៀស ដោយគ្មានការស្ម័គ្រចិត្តទាំងអស់នោះទេ ។ ការជម្លៀសចេញខ្លះអាចត្រូវបានចាត់ទុកថាជាលក្ខណៈគួរឲ្យទទួលយកបាន ប្រសិនបើផលប្រយោជន៍សហគមន៍វាលើសលប់ទៅលើការខាតបង់របស់បុគ្គល ហើយមនុស្សតិចណាស់ដែលផ្តល់ទឡ្ហីករណ៍ថា តាមនិយមន័យរាល់ការជម្លៀសដោយបង្ខំទាំងអស់គឺសុទ្ធតែខុសច្បាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ការជម្លៀសមហាជនជាច្រើនបានរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ហេតុដូច្នេះហើយចលនាទាំងនោះគឺជាការរំលោភលើច្បាប់អន្តរជាតិដែលត្រូវបានទទួលយក ។ ដូចការពន្យល់ខាងក្រោមនេះ ច្បាប់ជាវិជ្ជមានដែលមានស្រាប់ស្តីអំពីការជម្លៀសគឺសំដៅដោះស្រាយ ដោយផ្ទាល់បានតែនៅក្នុងស្ថានការណ៍មួយចំនួនតូចប៉ុណ្ណោះ ។

ច្បាប់និយាយពីប្រធានបទនេះ បានកើតចេញពីការជំនុំជម្រះក្តីនៅនូរិមប៊ឺក ដែលជាលើកដំបូងដាក់ឲ្យការជម្លៀសប្រជាជន ឬដែនសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ការបណ្តេញឬបង្ខំឲ្យជម្លៀសចេញទាំងហ្វូងឆ្លងកាត់ព្រំដែនអន្តរជាតិ ស្រដៀងគ្នាទៅនឹងសកម្មភាពទាំងឡាយដែល ហ៊ីត្លែរបានអនុវត្តក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ ហេតុដូចនេះការជម្លៀសចេញត្រូវបានចាត់ទុកថាជាការរំលោភបំពានយ៉ាងច្បាស់មកលើច្បាប់មនុស្សធម៌អន្តរជាតិ ។ ការជម្លៀសចេញទាំងនេះដែលសំដៅទៅលើក្រុមជនជាតិភាគតិច និងការនិរទេសជនស៊ីវិលទាំងហ្វូងៗចេញពីដែនដីក្រោមការកាន់កាប់របស់ខ្លួន គឺជាការរំលោភបំពានដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូររវាងរដ្ឋនិងរដ្ឋអាចត្រូវបានអនុញ្ញាតក្រោមលក្ខខណ្ឌមួយចំនួនឲ្យតែរដ្ឋដែលមានបំណងចង់ផ្លាស់ប្តូរគ្នាទាំងនោះ គឺជាប្រទេសដែលបានចុះហត្ថលេខាលើអនុសញ្ញាក្រុងហ្សឺណែវលើកទី៤ ។ ទោះជាយ៉ាងណាក៏ដោយកត្តាជាច្រើនអាចជះឥទ្ធិពលលើស្ថានភាពផ្លូវច្បាប់នៃការផ្លាស់ប្តូរ ឬជម្លៀសដទៃទៀត ។ កត្តាទាំងនេះរួមមានដូចខាងក្រោម ហើយ អាចមានលើសពីនេះទៀត អំពើនោះគឺ ÷

- ក្នុងប្រទេសឬឆ្លងកាត់ព្រំដែនអន្តរជាតិ ។
- កើតឡើងពេលមានជម្លោះប្រដាប់អាវុធឬក្នុងពេលមានសន្តិភាព ។
- ទាក់ទងដល់ការជម្លៀសនូវបុគ្គលឬមនុស្សទាំងហ្វូងៗ ។
- សំដៅលើក្រុមជនជាតិភាគតិចច្បាស់លាស់ណាមួយ ។

លើសពីនេះទៅទៀត ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទាំងឡាយដែលបន្តឡើងដោយជំរុញឲ្យតាំងលំនៅដ្ឋាននានាក្នុងតំបន់ច្បាស់លាស់ណាមួយ ឬក្នុងទឹកដីក្រោមការកាន់កាប់ណាមួយកំពុងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ។ ទោះបីជាយ៉ាងណាក៏ដោយ ការរំលោភបំពានទាំងនេះ ជារឿយៗត្រូវបានដោះស្រាយដោយឡែកពីការជម្លៀសទាំងឡាយដែលបានពិភាក្សាខាងលើ ។ សកម្មភាពដទៃទៀតដូចជាការផ្លាស់ទីលំនៅរបស់ជនភៀសខ្លួន ឬការផ្លាស់ទីលំនៅដើម្បីប្តូរបរិយាកាសសេដ្ឋកិច្ចគឺពុំត្រូវបានចាត់ទុកថាស្ថិតក្នុងអង្គច្បាប់នេះឡើយ ។

### ក) ប្រភពនៃច្បាប់

១) គោលការណ៍ច្បាប់

ភាពគួរឲ្យរន្ធត់នៃការជម្លៀសមនុស្សទាំងហ្វូងៗគឺត្រូវបានទទួលស្គាល់ជាផ្លូវការលើកដំបូងនៅក្នុងការជំនុំជម្រះទាំងឡាយនៅនូរិមប៊ឺក ដែលចាត់ចំណាត់ថ្នាក់ការជម្លៀសមនុស្សរបស់ពួកណាហ្ស៊ីជាច្រើនថាជា «ឧក្រិដ្ឋកម្មសង្គ្រាម» និងជា«ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ»មាត្រាទី៦(គ) នៃរដ្ឋធម្មនុញ្ញ តុលាការយោធាអន្តរជាតិកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា«អំពើមនុស្សឃាត ការសម្លាប់រង្គាល ការបង្ខំធ្វើទាសករ ការនិរទេស និងសកម្មភាពអមនុស្សធម៌មួយចំនួនដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលមុនឬនៅពេលសង្គ្រាម» ។ ការនិរទេសប្រជាជនដើមកំណើតនិងការប៉ុនប៉ង «ធ្វើណាហ្ស៊ីភាវូបនីយកម្ម»

លើដែនដីដែលនៅក្រោមការកាន់កាប់ទាំងឡាយ គឺត្រូវបានថ្កោលទោសម្តងហើយម្តងទៀតក្នុងពេលជំនុំជម្រះក្តីទាំងនេះ ។

២) អនុសញ្ញាក្រុងហ្សឺណែវ

មាត្រា៤៩ នៃអនុសញ្ញាក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ហាមឃាត់ការជម្លៀសបុគ្គល និងមនុស្សទាំងហ្វូងៗ ហើយនិងការនិរទេសមនុស្សដែលទទួលបានការការពារពីរដ្ឋដែលនៅក្រោមការកាន់កាប់ ទៅរដ្ឋរបស់អ្នកដទៃកាន់កាប់ ឬទៅកាន់ទឹកដីនៃប្រទេសអំណាចណាមួយផ្សេងទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងឬអត់ ដោយមិនគិតពីទស្សនៈយល់ឃើញរបស់ខ្លួន ។ អនុសញ្ញាទីក្រុងហ្សឺណែវជាទូទៅត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់អន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ "១" ទាំងឡាយនេះនិយាយជាចម្បងតែពីជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ ។ មាត្រារួមពនិយាយពីជម្លោះទាំងឡាយដែលមិនមែនជាលក្ខណៈអន្តរជាតិ ។ មាត្រានេះចែងថា បុគ្គលទាំងឡាយណាដែលមិនបានចូលប្រឡូកយ៉ាងសកម្មក្នុងជម្លោះប្រទូសរ៉ាយទាំងនោះ "ទោះក្នុងកាលៈទេសៈណាក៏ដោយត្រូវទទួលនូវការប្រព្រឹត្តមកលើខ្លួនក្នុងភាពថ្លៃថ្នូរជាមនុស្ស ហើយពុំមានការបែងចែកឲ្យប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿសាសនា ឬភេទ ការចាប់កំណើត ឬទ្រព្យសម្បត្តិ ឬដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដទៃផ្សេងទៀតឡើយ" ។ ទោះបីជាយ៉ាងណាក៏ដោយ មាត្រានេះពុំបាននិយាយឲ្យច្បាស់ពីការជម្លៀសប្រជាជនឡើយ ។ ជាងនេះទៅទៀត ភាពដែលអាចអនុវត្តទៅបាននៃការហាមឃាត់ទៅលើការជម្លៀសទាំងហ្វូងៗក្នុងមាត្រា៤៩គឺមានកម្រិតចំពោះជនស៊ីវិលទាំងឡាយក្នុងដែនដីក្រោមការកាន់កាប់ដែលមានការលើកលែងដូចតទៅនេះ ÷

- ◆ ភាគីរដ្ឋដែលពុំចងដោយអនុសញ្ញានេះ ។
- ◆ ប្រជាជាតិនៃរដ្ឋដែលមានតំណាងការទូតនៅក្នុងរដ្ឋមួយទៀតដែលប្រជាជនរបស់ពួកខ្លួននៅក្រោមការកាន់កាប់ ។
- ◆ បុគ្គលទាំងឡាយនៅក្រោមអនុសញ្ញាក្រុងហ្សឺណែវ រួមមានទាហានដែលរបួសក្នុងទីលានប្រយុទ្ធឬនៅក្នុងសង្គ្រាមឈ្លូងសមុទ្រឬអ្នកទោសសង្គ្រាម ។

៣) អនុសញ្ញាសហព័ន្ធអឺរ៉ុប

មាត្រា២និងមាត្រា៣នៃពិធីសារទី៤នៃអនុសញ្ញាសហព័ន្ធអឺរ៉ុបចំពោះការការពារសិទ្ធិមនុស្ស ក៏បាននិយាយពីស្ថានការណ៍ច្បាប់ស្តីពីការជម្លៀសប្រជាជន ។ មាត្រា២ធានានូវសិទ្ធិសេរីភាពក្នុងការដើរហើរ និងសិទ្ធិសេរីភាពក្នុងការជ្រើសរើសលំនៅដ្ឋានរបស់ខ្លួនដែលនៅក្រោមការរឹតត្បិតមួយចំនួនដូចជា "ត្រូវធ្វើយ៉ាងណាឲ្យស្របទៅតាមច្បាប់ និងចាំបាច់ត្រូវអនុលោមទៅតាមតម្រូវការក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីបម្រើផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ ដើម្បីថែរក្សាសណ្តាប់ធ្នាប់


ប្រជាជនកំពុងធ្វើល្អីនៅក្នុងភូមិ

សាធារណៈ ដើម្បីទប់ស្កាត់ខុក្រិដ្ឋកម្មការពារសុខភាពនិងសីលធម៌សង្គ្រាម ឬដើម្បីការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ ។

មាត្រា៣ បានចែងថា ÷

◆ គ្មាននរណាម្នាក់ត្រូវបង្ខំឲ្យជម្លៀសដោយប្រើប្រាស់វិធានការជម្លៀសជាបុគ្គលឬទាំងហ្វូងៗពីទឹកដីរបស់ខ្លួនឡើយ ។

◆ គ្មាននរណាម្នាក់ត្រូវបានដកហូតយកសិទ្ធិចេញចូលទឹកដីរបស់ខ្លួនឡើយ ។

ក្នុងរឿងក្តីវាង ប្រទេសស៊ីប្រ៍ ទល់នឹង ទួរគី គណៈកម្មការសហព័ន្ធអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សក៏បានផ្សារភ្ជាប់ការជម្លៀសប្រជាជនទៅនឹងសិទ្ធិរស់នៅដោយពុំមានការជ្រៀតជ្រែក ។ គណៈកម្មការនេះថ្កោលទោសទាំងចំពោះការជម្លៀសក្នុងប្រទេសនិងការជម្លៀស ឆ្លងកាត់ព្រំដែនអន្តរជាតិ ។ ជាការពិតណាស់ "ខ" ទាំងនេះគឺអាចយកទៅអនុវត្តបានតែចំពោះប្រទេសជាហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សប៉ុណ្ណោះ ក៏ប៉ុន្តែក៏អាចចង្អុលបង្ហាញដល់ការហាមឃាត់មួយដែលទើបនឹងចាប់បដិសន្ធិឡើងប្រឆាំងនឹងការជម្លៀសទាំងហ្វូងដែរ ។

ការជម្លៀសជាច្រើនដែលពុំត្រូវឥតខ្ចោះទៅនឹងចំណាត់ប្រភេទខាងលើ អាចត្រូវបានយកមកនិយាយដោយអនុសញ្ញាស្តីអំពីសិទ្ធិមនុស្សនៅត្រង់មាត្រា៣ បានទទួលស្គាល់នូវសិទ្ធិទទួលសុវត្ថិភាពផ្ទាល់ខ្លួននិងត្រង់មាត្រា២៥ សិទ្ធិទទួលកម្រិតជីវភាពរស់នៅគ្រប់គ្រាន់ ។

៤) ការជម្លៀសគឺជាខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ការជម្លៀសដោយបង្ខំមួយចំនួនត្រូវបានចាត់ទុកថាខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬជាការរំលោភលើច្បាប់មនុស្សធម៌ ។ ការជម្លៀស ការផ្លាស់ប្តូរឲ្យទៅនៅទីកន្លែងផ្សេងៗ ភាពសាហាវឃោរឃៅ ឬលក្ខណៈរើសអើងដែលរំលោភទៅលើមនសិការរបស់មនុស្ស និងបទដ្ឋានមនុស្សធម៌ជាមូលដ្ឋានទាំងឡាយពុំចាំបាច់ត្រូវបញ្ចូលក្នុងប្រភេទណាមួយក្នុងចំណោមបទល្មើសខាងលើ អាចចាត់ទុកជាប្រការរំលោភលើច្បាប់អន្តរជាតិនោះឡើយ ។ ការជម្លៀសដែលអាចចាត់ទុកជាបទល្មើសណាមួយដូចបានរៀបរាប់ខាងលើ លុះត្រាតែការជម្លៀសនោះត្រូវបានធ្វើឡើងដោយពុំមានការស្ម័គ្រចិត្ត ហើយមានការចុះស្នាមនិងជីងព្រដោយរដ្ឋ ។ ប្រសិនបើការជម្លៀសនេះសំដៅបំផ្លាញទាំងស្រុងឬដោយផ្អែកលើក្រុមជនជាតិភាគតិចមួយ ការជម្លៀសនេះ ក៏អាចត្រូវបានចាត់ទុកខុក្រិដ្ឋកម្មប្រល័យពូជសាសន៍បានដែរ ។

៥) ការដាក់កម្រិតនានាដោយឈរលើអធិបតេយ្យភាព

មាត្រា២("៧") នៃធម្មនុញ្ញអង្គការសហប្រជាជាតិដល់កម្រិតធ្ងន់ធ្ងរបំផុតលើច្បាប់ជាវិជ្ជមានស្តីអំពីការជម្លៀសប្រជាជន ។ មាត្រានេះនិយាយថា"គ្មានអ្វីដែលមានចែងក្នុងធម្មនុញ្ញនាពេលបច្ចុប្បន្នផ្តល់សិទ្ធិអំណាចសមត្ថកិច្ចឲ្យដល់អង្គការសហប្រជាជាតិ




ដើម្បីជ្រៀតជ្រែកក្នុងបញ្ហានានា ដែលមានសារសំខាន់ក្នុងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋទាំងឡាយនោះឡើយ" ។

ហេតុដូច្នេះហើយការជម្លៀសទាំងឡាយដែលបានកើតឡើងក្នុងសង្គ្រាមស៊ីវិល ហើយមិនសំដៅបំផ្លិចបំផ្លាញដល់ក្រុមជនជាតិភាគតិចណាមួយនោះ អាចត្រូវបានចាត់ទុកថាស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ លុះត្រាតែការជម្លៀសទាំងនោះមានលក្ខណៈធ្ងន់ធ្ងរល្មមដល់ក្លាយទៅជាខុក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ល្មមរហូតដល់ក្លាយទៅជាខុក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឬការរំលោភបំពានលើបទដ្ឋានច្បាប់អន្តរជាតិជាមូលដ្ឋានដទៃទៀត ។

### ខ) ការអនុវត្តចំពោះប្រទេសកម្ពុជា

ភាពសាហាវឃោរឃៅនិងទំហំនៃការជម្លៀសទាំងហ្វូងក្នុងប្រទេសកម្ពុជារវាងពីឆ្នាំ១៩៧៥ដល់១៩៧៨ បង្ហាញពីស្ថានការណ៍តែមួយគត់នៅក្នុងច្បាប់អន្តរជាតិ ។ ទីក្រុងនិងទីប្រជុំជនទាំងមូលត្រូវស្ងាត់ឈឹងដោយប្រជាជនទីក្រុងទាំងអស់ ត្រូវបានជម្លៀសទៅតំបន់ជនបទ ។ ជាបន្តបន្ទាប់ អ្នកទាំងនោះត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ដើម្បីប្រែក្លាយតំបន់ថ្មីៗទាំងឡាយឲ្យទៅជាតំបន់កសិកម្ម ។ ទំហំនៃការបាត់បង់ជីវិតមនុស្សដ៏ធំមហិមា ដោយសារ




ម្ចាស់គំនូរ អាយុ១៨ឆ្នាំ

ការជម្លៀស គ្រោះទុរ្ភិក្ស និងការលំបាកដ៏ធ្ងន់ធ្ងរជាផលវិបាក ដែលរបបនេះបានបន្សល់ទុក បង្ហាញភស្តុតាងថាការជម្លៀសទាំងនេះគឺជាឧក្រិដ្ឋកម្មសង្គ្រាម ។ ការជម្លៀសទាំងនេះពុំមានការយល់ព្រមឡើយគឺធ្វើឡើងដោយបង្ខំ ហើយពុំត្រូវបានអនុវត្តក្នុងលក្ខណៈជាមនុស្សជាតិ មានវប្បធម៌ជឿនលឿន និងបណ្តាលឲ្យមនុស្សស្លាប់ច្រើនរាប់មិនអស់ ។ ទោះបីជាយ៉ាងណាក៏ដោយការជម្លៀសដោយអមនុស្សធម៌ទាំងនេះពុំមានចែងច្បាស់នៅក្នុងការហាមឃាត់ដែលបានកំណត់យ៉ាងតឹងរ៉ឹងស្តីអំពីការជម្លៀសប្រជាជនឡើយ ។ ការជម្លៀសទាំងនេះគឺងាយនឹងចាត់ចំណាត់ថ្នាក់ចូលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាង ។

ដោយសារការជម្លៀសទាំងនេះស្ថិតនៅក្នុងប្រទេសដែលលំបាកកំណត់ថាជា«ការនិរទេស» ដែលនឹងមានលក្ខណៈចាំបាច់សម្រាប់ដាក់អំពើជម្លៀសទាំងនេះក្រោមការហាមឃាត់នៅក្នុងមាត្រា៦នៃរដ្ឋធម្មនុញ្ញ IMT ។ ជាងនេះទៅទៀតដោយហេតុថាអ្នកដែលត្រូវជម្លៀសទាំងនោះគឺជាប្រជាពលរដ្ឋរបស់រដ្ឋ ដែលទទួលខុសត្រូវលើការជម្លៀសទាំងនោះ ស្រដៀងគ្នានេះដែរ ការជម្លៀសទាំងនេះពុំបាននិយាយដល់មាត្រា៤៩នៃអនុញ្ញាក្រុងហ្សឺណែវលើកទី៤ ។ ទោះជាយ៉ាងណាក៏ដោយ ភាពអមនុស្សធម៌នៃការជម្លៀសទាំងនោះគឺប្រឆាំងយ៉ាងច្បាស់ក្រឡែតចំពោះមាត្រា៣រួមនៃអនុសញ្ញាក្រុងហ្សឺណែវ ដែលអំពាវនាវឲ្យប្រព្រឹត្តក្នុងភាពថ្លៃថ្នូរជាមនុស្សមកលើជនស៊ីវិលដែលពុំបានចូលប្រឡូកសកម្មភាពប្រទូសរ៉ាយនោះ ។

**អេលីហ្សាប៊េត វ៉ាន់ស្វាក់**

## ដំណឹងស្វែងរកប្អូនប្រុស

ខ្ញុំបាទឈ្មោះ សុះ ម៉េត ហៅ មីត អាយុ៥១ឆ្នាំ រស់នៅភូមិចាមក្រោម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ។

សូមស្វែងរកប្អូនប្រុសឈ្មោះ តាំ ហ៊ីម អាយុ១៧ឆ្នាំនៅពេល ហ៊ីម ចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាមការហៅរបស់គណៈស្រុកឈ្មោះ ស្វាយ ម៉ាត់ នៅឆ្នាំ១៩៧៣ ។ ហ៊ីម ធ្វើដំណើរទៅស្នាក់នៅវត្តព្រែកអំបិលជាមួយយុវជននៅក្នុងភូមិចាមក្រោម២៤នាក់ទៀត ។ នៅក្នុងឆ្នាំដដែលខ្ញុំបានទៅលេងនឹងប្អូនដោយយកម្ហូបអាហារនិងបារីបន្តិចបន្តួចទៅឲ្យវា ។ ហ៊ីម ប្រាប់ខ្ញុំថា អង្គការនឹងបញ្ជូនកងរបស់ខ្លួនទៅសមរភូមិឆ្ងាយពីភូមិនេះ ប៉ុន្តែខ្ញុំមិនបានដឹងថាទៅទីណាទេ ។ ចាប់តាំងពីពេលនោះមកខ្ញុំមិនដែលបានទទួលដំណឹងពីប្អូនប្រុសរហូត ។

ប្រសិនបើប្អូនប្រុសឬបងប្អូនបានឮដំណឹងនេះ សូមមេត្តាផ្តល់ដំណឹងមកដល់ខ្ញុំនៅភូមិចាមក្រោម ឬមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ និងទូរសារលេខ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។

# តើខ្មែរក្រោមជាជនជាតិភាគតិចឬ?

ដូចយើងបានពិភាក្សារួចមកហើយ ការប្រព្រឹត្តមកលើកម្ពុជាក្រោមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យលើកឡើងនូវសំណួរផ្លូវច្បាប់លំបាកមួយ ។ ជាពិសេស យើងនៅមិនទាន់ច្បាស់ថាតើខ្មែរកម្ពុជាក្រោមគួរត្រូវបានចាត់ទុកជាក្រុម "ជនជាតិ" ឬ "ជាតិពន្ធ" ដែលស្ថិតនៅក្រោមការការពារនៃសេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហម ។ ចំណុចនេះទាក់ទិនទៅនឹងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ខណៈពេលដែលយើងមិនអាចប៉ាន់ស្មានពីដំណើរស្រុង ឬមួយផ្នែកនៃពូជសាសន៍ ពណ៌សម្បុរ សាសនា ជាតិពន្ធ ឬក្រុមជនជាតិណាមួយ ។ យើងអាចបែងចែកចេតនានេះជាពីរផ្នែកគឺ ÷

## ការដៅទៅរកក្រុមដែលទទួលបានការការពារ

ជនដៃដល់បានដៅទៅរកក្រុមមនុស្សដែលទទួលបានការការពារ រួមមានក្រុមសម្គាល់តាមរយៈអត្តសញ្ញាណ ជនជាតិ ពូជសាសន៍ ពណ៌សម្បុរ សាសនា និងជាតិពន្ធ ។ ដោយឡែកបញ្ហាសាសនានៅក្នុងទឹកដីកម្ពុជាក្រោមមិនមែនជាបញ្ហាចោទឡើយ ។



ព្រះសង្ឃខ្មែរក្រោម

ប្រព្រឹត្តរបស់សាលាក្តីចំពោះកម្ពុជាក្រោម អនុស្សរណៈនេះសរសេរពីការវែកញែកដែលយើងលើកឡើងមកពិភាក្សាជំនួសមុខឲ្យជនរងគ្រោះកម្ពុជាក្រោម ។

## អំពើប្រល័យពូជសាសន៍

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចទាក់ទងនឹងសកម្មភាពទម្រង់ផ្សេងៗដូចដែលយើងបានលើកយកមកពិភាក្សា ។ ឧក្រិដ្ឋ-កម្មប្រល័យពូជសាសន៍ទាក់ទងនឹងធាតុចេតនាផ្នែកសតិអារម្មណ៍ ហើយ សកម្មភាពទាំងអស់នេះធ្វើឡើងក្នុងចេតនាបំផ្លាញទាំងបញ្ហាពូជសាសន៍ ពណ៌សម្បុរ (ដូចជាស្បែកស ខ្មៅ ឬអាស៊ី) ក៏មិនជាប់ពាក់ព័ន្ធដែរ ។ ដូច្នេះយើងអាចអះអាងថា ខ្មែរកម្ពុជាក្រោមអាចចាត់ទុកជាក្រុម "ជនជាតិ" ឬ "ជាតិពន្ធ" ក៏បាន ។

យើងអាចលើកឡើងថាកម្ពុជាក្រោមស្ថិតនៅក្នុងក្រុមមួយនៃ"ជនជាតិ" ។ ទីមួយ កម្ពុជាក្រោម ជាក្រុមជនជាតិកម្ពុជា (ខ្មែរ) ។ ក្រុមនេះតំណាងឲ្យជនជាតិខ្មែរភាគច្រើន ប៉ុន្តែយើងអាចឬមិនអាចចាត់ទុកកម្ពុជាក្រោមជាក្រុមទទួលបានការការពារនៃសេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហម ។ ទីពីរ យើងអាច

តបវិញថា កម្ពុជាក្រោមស្ថិតក្នុងក្រុមជនជាតិវៀតណាម យោងទៅតាមសញ្ជាតិនិងការប្រព្រឹត្តចំពោះប្រជាជនកម្ពុជាក្រោមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្ពុជាក្រោមក៏អាចចាត់ទុកជា "ក្រុមជាតិពន្ធ" ដែលជាទូទៅសំដៅលើប្រជាជនមួយចំនួនតូចដែលមានចរិតលក្ខណៈខាងវប្បធម៌ ឬប្រវត្តិសាស្ត្រគួរឲ្យកត់សម្គាល់ ដូចជា ភាសា សាសនា ឬរឿងរ៉ាវប្រវត្តិសាស្ត្រ ។

សេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហមមិនមានស្នើនិយមន័យជាក់លាក់ណាមួយពីក្រុម "ជនជាតិ" ឬ "ជាតិពន្ធ" ណាមួយឡើយ ហើយការវែកញែកតាមផ្លូវច្បាប់នឹងនាំមកនូវឥទ្ធិពលដល់សេចក្តីសម្រេចចិត្តរបស់សាលាក្តីនេះចំពោះបញ្ហាឲ្យនិយមន័យ ។ ទោះបីជាយើងនឹងមិនជជែកវែកញែកពីបញ្ហានេះមុនពេលមានតុលាការក៏ដោយ ភ័ស្តុតាងយើងប្រមូលមកគួបផ្សំនឹងការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ យើងអាចទទួលបាននូវគំនិតមួយចំនួនសម្រាប់ព្រះរាជអាជ្ញា ។ និយមន័យនៃ "ជនជាតិ" ឬ "ជាតិពន្ធ" អាចជះឥទ្ធិពលដល់ការអប់រំ និងមតិសាធារណៈទាក់ទិននឹងប្រធានបទប្រល័យពូជសាសន៍ ។ ដូច្នេះ ខ្ញុំអាចសរុបគំនិតខ្ញុំជាសង្ខេបពីអ្វីដែលខ្ញុំយល់ឃើញថា ការស្រាវជ្រាវរបស់អ្នកអាចពាក់ព័ន្ធនឹងសំណួរផ្លូវច្បាប់ដ៏សំខាន់មួយ ។

១) កម្ពុជាក្រោមជាផ្នែកមួយនៃជនជាតិខ្មែរភាគច្រើន ។ នៅក្នុងការសិក្សារបស់អ្នក ប្រសិនបើអ្នកយល់ឃើញថា ទង្វើរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជាក្រោមដូចគ្នានឹងអ្វីដែលខ្មែរក្រហមធ្វើចំពោះជនជាតិខ្មែរគ្រប់ពេលនោះ ការវែកញែកមួយរបស់យើងអាចសរុបថា ប្រជាជនកម្ពុជាក្រោមជាផ្នែកមួយនៃ "ក្រុមជនជាតិ"ខ្មែរ ។ យើងមិនទាន់ច្បាស់ថាតើប្រជាជនកម្ពុជាក្រោមស្ថិតនៅក្រោមការការពារនៃលក្ខខណ្ឌអំពើប្រល័យពូជសាសន៍ចែងក្នុងសេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហមឡើយ ។

២) កម្ពុជាក្រោមជាផ្នែកមួយនៃក្រុមជនជាតិវៀតណាម ។ ប្រជាជនកម្ពុជាក្រោមណាមួយដែលកាន់សញ្ជាតិវៀតណាមសុទ្ធតែអាចចាត់ទុកជាផ្នែកមួយនៃក្រុមជនជាតិវៀតណាម ប្រសិនបើ ជនជាតិកម្ពុជាក្រោមនោះត្រូវបានខ្មែរក្រហមគិតថា ជាជនជាតិវៀតណាម ហើយដោយសារគោលគំនិតនេះនាំឲ្យទង្វើរបស់ខ្មែរក្រហមចំពោះប្រជាជនកម្ពុជាក្រោមខុសគ្នានឹងជនជតិខ្មែរ ។ កំណត់ត្រារបស់ខ្មែរក្រហមដែលថា ប្រជាជនកម្ពុជាក្រោម "បម្រើការឲ្យវៀតណាម" ឬជា "ភ្នាក់ងារវៀតណាម" មិនគ្រប់គ្រាន់នឹងបង្ហាញថា កម្ពុជាក្រោមទាំងនោះជាផ្នែកមួយនៃក្រុមជនជាតិវៀតណាមឡើយ ។

ករណីប្រជាជនកម្ពុជាក្រោមមិនកាន់សញ្ជាតិវៀតណាមពិតជាករណីពិបាកនិងស្មុគស្មាញ ។ ទោះបីជាខ្មែរក្រហមចាត់ទុកប្រជាជនកម្ពុជាក្រោមថា "ជាផ្នែកមួយនៃវៀតណាម" ក៏ដោយ ក៏យើងពិបាកនឹងអះអាងថា ប្រជាជនទាំងនោះពិតជាផ្នែកមួយនៃក្រុមជនជាតិវៀតណាម ដោយសារភាពជាក់ស្តែង ប្រជាជនកម្ពុជាក្រោមនិយាយភាសាខ្មែរនិងនិយមវប្បធម៌មានលក្ខណៈខ្មែរ ។ ដូច្នេះយើងគប្បីលើកឡើងថាប្រជាជនកម្ពុជាក្រោមជាផ្នែកមួយនៃក្រុមជនជាតិភាគតិចរបស់ខ្មែរ ។

៣) ករណីប្រជាជនកម្ពុជាក្រោមចាត់ចូលជាក្រុមជាតិពន្ធមួយនៅមិនទាន់ច្បាស់លាស់ទេ ។ ភ័ស្តុតាងសំខាន់គឺជាភ័ស្តុតាងដែលបង្ហាញថា ខ្មែរក្រហម ៖ ក) ចាត់ទុកប្រជាជនកម្ពុជាក្រោមមិនមែនខ្មែរ និង ខ) បានប្រព្រឹត្តចំពោះប្រជាជនទាំងនោះខុសពីប្រជាជនខ្មែរឯទៀត ។ ប្រសិនបើយើងនិយាយពីភាពខុសគ្នាជាក់ស្តែងរវាងកម្ពុជាក្រោមនិងជនជាតិខ្មែរ ផ្នែកវប្បធម៌និងប្រវត្តិសាស្ត្រជាចំណុចពាក់ព័ន្ធ ពីព្រោះចំណុចទាំងពីរនេះជាមូលដ្ឋានដែលខ្មែរក្រហមអាចសម្គាល់និងបែងចែកកម្ពុជាក្រោមជាក្រុមមួយដាច់ដោយឡែក ។ យ៉ាងណាក៏ដោយ ការបង្ហាញពីភាពខុសគ្នាជាក់ស្តែងតែម៉្យាងគឺមិនគ្រប់គ្រាន់នឹងបញ្ជាក់ថា ជនដៃដល់ខ្មែរក្រហមត្រូវបានចាត់ទុកប្រជាជនកម្ពុជាក្រោមជាក្រុមជនជាតិភាគតិចឡើយ ។

## ប៉ុនប៉ងបំផ្លាញក្រុមមួយដោយផ្នែក ឬបំបាត់ចោលទាំងស្រុង

ផ្នែកចម្បងទីពីរនៃធាតុចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺ ជនដៃដល់ខ្មែរក្រហមបម្រុងនឹងកម្ទេចក្រុមមួយដោយផ្នែក ឬបំបាត់ចោលទាំងស្រុង ។ ប្រសិនបើប្រជាជនកម្ពុជាក្រោមត្រូវបានចាត់ទុកជាក្រុមជាតិពន្ធស្ថិតក្រោមការការពារ យើងចាំបាច់ត្រូវមានភ័ស្តុតាងបង្ហាញថាខ្មែរក្រហមប៉ុនប៉ងលុបបំបាត់ជាតិពន្ធនេះចោល ដោយសារអត្តសញ្ញាណខ្លួនជាកម្ពុជាក្រោម ។ ការបង្ហាញពីតួលេខស្លាប់តិចឬច្រើនរបស់ប្រជាជន

កម្ពុជាក្រោមគឺមិនគ្រប់គ្រាន់ទេ ។ ការប្រល័យពូជសាសន៍ទាមទារធាតុដែលបញ្ជាក់ថាប្រជាជនកម្ពុជាក្រោមពិតជាត្រូវបានចាត់ចេញដោយឡែកដោយចេតនា ។

ប្រសិនបើប្រជាជនកម្ពុជាក្រោមត្រូវបានចាត់ទុកជាផ្នែកមួយនៃក្រុមជនជាតិវៀតណាមនោះ ភ័ស្តុតាងត្រូវបង្ហាញថា ខ្មែរក្រហមប៉ុនប៉ងលុបបំបាត់ផ្នែកមួយនៃជាតិសាសន៍វៀតណាម (ជនជាតិវៀតណាមរស់នៅលើទឹកដីកម្ពុជា) ។ ករណីនេះអាចការពារប្រជាជនកម្ពុជាក្រោមកាន់សញ្ជាតិវៀតណាម ប៉ុន្តែប្រហែលមិនអាចការពារប្រជាជនកម្ពុជាក្រោមដែលមានសញ្ជាតិខ្មែរឡើយ ។ ទោះបីជាយើងអាចរកឃើញភ័ស្តុតាងបញ្ជាក់ថា ខ្មែរក្រហមចង់កម្ទេចក្រុមជនជាតិវៀតណាម ក៏ភ័ស្តុតាងនេះត្រឹមតែទាក់ទិននឹងផ្នែកតូចមួយនៃជនរងគ្រោះកម្ពុជាក្រោមក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។

ទីបី ប្រសិនបើភ័ស្តុតាងលើកឡើងថាប្រជាជនកម្ពុជាក្រោមជាផ្នែកមួយនៃក្រុមជនជាតិខ្មែរ ប្រជាជនកម្ពុជាក្រោមនឹងស្ថិតក្រោមការពារពារប្រសិនបើសាលាក្តីសម្រេចថាជនជាតិភាគច្រើនជាក្រុមប្រជាជនដែលទទួលបានការការពារក្រោមលក្ខខណ្ឌអំពើប្រល័យពូជសាសន៍ចែងនៅក្នុងសេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហម ។ ក្នុងករណីនេះ យើងអាចវែកញែកថា ខ្មែរក្រហមប៉ុនប៉ងកម្ទេចជនជាតិខ្មែរដោយផ្នែក និងជនរងគ្រោះភាគច្រើនដែលខ្មែរក្រហមប៉ុនប៉ងកម្ទេចគឺកម្ពុជាក្រោម ។ មតិអះអាងនេះសំដៅលើជនរងគ្រោះខ្មែរគ្រប់រូបពីសម័យខ្មែរក្រហម មិនមែនត្រឹមតែប្រជាជនកម្ពុជាក្រោមប៉ុណ្ណោះទេ ។ យ៉ាងណាមិញ ប្រសិនបើមតិនេះត្រូវបានទទួលយក ប្រជាជនកម្ពុជាក្រោមដែលរងទុក្ខពីរបបកម្ពុជាប្រជាធិបតេយ្យភាគច្រើន ឬទាំងអស់នឹងស្ថិតក្រោមការការពារ ។

## សង្ខេបវែកញែកពីអំពើប្រល័យពូជសាសន៍

ស្ថានភាពរបស់ក្រុមទទួលបានការការពារក្នុងលក្ខខណ្ឌចេតនាកម្ទេចទាំងស្រុងឬដោយផ្នែក ÷

១) ប្រជាជនកម្ពុជាក្រោម ត្រូវបានខ្មែរក្រហមចាត់ទុកថាជាផ្នែកមួយនៃក្រុមជនជាតិខ្មែរ ហើយទង្វើរបស់ខ្មែរក្រហមចំពោះកម្ពុជាក្រោមគឺដូចគ្នានឹងទង្វើចំពោះក្រុមជនជាតិខ្មែរដែរ ។

«ខ្មែរក្រហមមានចេតនាកម្ទេចក្រុមជនជាតិខ្មែរមួយផ្នែក ហើយប្រជាជនកម្ពុជាក្រោមក៏ស្ថិតនៅក្នុងចំណោមជនរងគ្រោះទាំងនោះដែរ» ។

២) ខ្មែរក្រហមចាត់ទុកប្រជាជនកម្ពុជាក្រោមជាក្រុមជាតិពន្ធដាច់ដោយឡែក ដោយយោងលើប្រវត្តិសាស្ត្រនិងវប្បធម៌ ។

«ខ្មែរក្រហមមានចេតនាកម្ទេចដោយផ្នែកឬទាំងស្រុងនៃប្រជាជនកម្ពុជាក្រោម ដោយចាត់ទុកថាកម្ពុជាក្រោមមានឋានៈជាក្រុមជាតិពន្ធ ។

៣) ប្រជាជនកម្ពុជាក្រោមមួយចំនួនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃក្រុមជនជាតិវៀតណាម ។

«ខ្មែរក្រហមមានចេតនាតិច ឬច្រើនកម្ទេចក្រុមជនជាតិវៀតណាម ។ ជនរងគ្រោះជាប្រជាជនកម្ពុជាក្រោមមួយចំនួនត្រូវបានធ្វើទុក្ខទោសដោយសារខ្មែរក្រហមឈរលើមូលដ្ឋានថាប្រជាជនកម្ពុជាក្រោមជាជនជាតិវៀតណាម ។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ក្នុងសេចក្តីព្រាងច្បាប់កាត់ទោសខ្មែរក្រហម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាមទារ «ការរីករាលដាលនៃការវាយប្រហារផ្តាច់ការប្រឆាំងនឹងជនស៊ីវិលមួយចំនួន ដោយរើសអើងពីមូលដ្ឋាន ជនជាតិ ទំនោរនយោបាយ ជាតិពន្ធ ពូជសាសន៍ពណ៌សម្បុរ និងសាសនា ។ ការរំលោភសិទ្ធិក្រោមរូបភាពផ្សេងៗក៏អាចចាត់ចូលជាសកម្មភាពប្រឆាំងនឹងមនុស្សជាតិដែរ ដូច្នេះខ្ញុំនឹងផ្តោតជាចម្បងលើធាតុសំខាន់ៗនៃចេតនារបស់ជនដៃដល់ ។ ការកត់សម្គាល់ពីចេតនាកម្ទេចប្រជាជនមួយក្រុមដោយផ្នែកឬទាំងស្រុង មិនមែនជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ប៉ុន្តែជាការវាយប្រហារចាំបាច់ត្រូវឈរលើមូលដ្ឋានពូជសាសន៍ សាសនា ជាតិពន្ធ របស់ជនរងគ្រោះ ។ ដូចខ្ញុំបាននិយាយនៅខាងលើរួចមកហើយ ជនឯទៀតអាចវែកញែកកត្តាប្រជាជនកម្ពុជាក្រោមកាន់សញ្ជាតិឬជាតិពន្ធមួយដោយឡែក ។

## ការរីករាលដាលនៃការវាយប្រហារផ្តាច់ការ

ដើម្បីបង្ហាញថា ការរីករាលដាលនៃការវាយប្រហារមកលើប្រជាជនកម្ពុជាក្រោមពិតជាកើតមានមែន យើងទាមទារ

ភ័ស្តុតាងថា ជនរងគ្រោះមួយចំនួនធំដែលរស់នៅតាមតំបន់ភូមិសាស្ត្រជាក់លាក់មួយទទួលរងនូវការវាយប្រហារ ។ ដោយសារប្រជាជនកម្ពុជាក្រោមជាច្រើនដែលរស់នៅពាសពេញផ្ទៃប្រទេសកម្ពុជាក្លាយជាជនរងគ្រោះនៃរបបខ្មែរក្រហម យើងអាចមានភ័ស្តុតាងបង្ហាញពី"ការរីករាលដាល"នៃការវាយប្រហារ ។ យើងកាន់តែជួបប្រទះការលំបាកកាន់តែខ្លាំងក្នុងការបង្ហាញពីការវាយប្រហារ "ផ្តាច់ការ" ដោយផ្តោតលើផែនការមួយចំនួនដែលគ្រោងទុកជាមុន ។ ភ័ស្តុតាងត្រូវបង្ហាញថាខ្មែរក្រហមបានរៀបចំគម្រោង និងវិធីវាយប្រហារប្រជាជនកម្ពុជាក្រោម ។

**ការវាយប្រហារឈរលើមូលដ្ឋានជាតិពន្ធុឬសញ្ជាតិជនរងគ្រោះ**

ទោះបីជាភ័ស្តុតាងបង្ហាញពីការរីករាលដាលនៃការវាយប្រហារផ្តាច់ការប្រឆាំងនឹងប្រជាជនកម្ពុជាក្រោមត្រូវបានរកឃើញក៏ដោយ ជនដៃដល់មិនចាំបាច់ទទួលទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ។ ករណីជាប់ពីបទនេះ ជនដៃដល់ត្រូវវាយប្រហារលើមូលដ្ឋានសញ្ជាតិ ជាតិពន្ធុ គោលជំហរនយោបាយ ជាតិសាសន៍ ពណ៌សម្បុរ ឬសាសនា ។ ចំពោះករណីប្រជាជនកម្ពុជាក្រោម មូលដ្ឋានសាសនានិងពូជសាសន៍ មិនជាប់ទាក់ទងទេ ។ ភ័ស្តុតាងទាមទារការបង្ហាញថា ប្រជាជនកម្ពុជាក្រោមទទួលការវាយប្រហារក្នុងចំណោមហេតុផលមួយនៃហេតុផលបីខាងលើគឺ ជាតិពន្ធុ គោលជំហរនយោបាយឬសញ្ជាតិ ។

យើងអាចស្វែងរកភ័ស្តុតាងថា មានការវាយប្រហារកើតឡើងដោយឈរលើមូលដ្ឋានជាតិពន្ធុ ឬសញ្ជាតិ ប៉ុន្តែភ័ស្តុតាងពីរបបកម្ពុជាប្រជាធិបតេយ្យទំនងបង្ហាញពីទំនាក់ទំនងគោលជំហរនយោបាយច្រើនជាង ។ ការវាយប្រហារភាគច្រើនកើតឡើងដោយមានការសង្ស័យលើនយោបាយ ហើយប្រជាជនកម្ពុជាក្រោមក្នុងចំណោមនោះត្រូវទទួលរងការធ្វើទុក្ខទោសដោយមូលហេតុនេះដែរ ។ ខ្ញុំសូមណែនាំឲ្យមានការស្រាវជ្រាវដើម្បីវែកញែកថាតើខ្មែរក្រហមបានសន្មតពីនយោបាយរបស់ប្រជាជនកម្ពុជាក្រោម ។ ឧទាហរណ៍ ខ្មែរក្រហមប្រហែលគិតថាប្រជាជនកម្ពុជាក្រោមគាំទ្ររបបចាស់ ឬគោលជំហរវៀតណាម ។ ប្រសិនបើដូច្នេះអត្តសញ្ញាណរបស់ប្រជាជនកម្ពុជាក្រោមអាចបង្ហាញពីការវាយប្រហារដោយមូលហេតុនយោបាយ ។ **ចន ឆរឆីអារី**

## ដំណឹងសួររកកូនស្រី


នី ម៉ៃណាស់

នាងខ្ញុំឈ្មោះ នី ម៉ៃណាស់ អាយុ ៦៨ឆ្នាំ និងប្តីឈ្មោះ ស៊ុប លី ។ សព្វថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។

នាងខ្ញុំសូមសួររកកូនស្រីឈ្មោះ លី ម៉ៃណាស់ អាយុ១៨ឆ្នាំដែលត្រូវខ្មែរក្រហមចាត់ឲ្យទៅធ្វើការតាមកងចល័តនារី ខណៈដែលក្រុមគ្រួសាររបស់ខ្ញុំរស់នៅភូមិកំពង់សំបួរ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។ តាំងពីពេលនោះមក ខ្ញុំមិនដែលទទួលដំណឹងពីនាងសោះ ។

ប្រសិនបើកូនស្រីបានឮឬញាតិមិត្តបានស្គាល់ឈ្មោះខាងលើ សូមមេត្តាផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬទូរសារលេខ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។

## ដំណឹងសួររកឪពុកមា


សំ អ៊ូ

នាងខ្ញុំឈ្មោះ សំ ម៉ារីយ៉ាស់ អាយុ៥៨ឆ្នាំ រស់នៅភូមិទួលផ្សេក ឃុំកំពង់ចម្លង ស្រុកពញាឮ ខេត្តកណ្តាល ។

សូមសួររកឪពុកមាឈ្មោះ សំ អ៊ូ ដែលបានបែកគ្នានៅខ្លាគ្រាំ ឆ្នាំ១៩៧៥ ក្នុងដំណើរជម្លៀសមកពីទីក្រុងភ្នំពេញ ។ ខ្ញុំមិនដឹងថាគាត់ត្រូវខ្មែរក្រហមជម្លៀសទៅទីណាបន្តទៀតឡើយ ។ រហូតមកដល់ពេលនេះខ្ញុំមិនដែលបានទទួលដំណឹងអ្វីសោះពីគាត់ ។

ប្រសិនបើឪពុកមាឬបងប្អូនញាតិមិត្តឮដំណឹងនេះសូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ វិថីសីហនុ ខណ្ឌចម្ការមន ក្រុងភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ចំនួនជនជាតិចាមបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម

ខ្ញុំសូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ ប៊ែន គៀរនិន លោកសាស្ត្រាចារ្យ អាឡិច ហ៊ិនតុន និងលោក ទូច បូរ៉ា ដែលលោកបានលាតត្រដាងបញ្ហាសំខាន់ស្តីពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមប្រឆាំងនឹងសាសនានិកជនជាតិភាគតិចឲ្យមានក្នុងការពិភាក្សាជាសាធារណៈ និងការពិភាក្សាលើស្ថិតិចំនួនប្រជាជន ។

នេះគឺជាភាពសំខាន់ចាំបាច់ក្នុងការផ្លាស់ប្តូរយោបល់រវាងអ្នកប្រាជ្ញ ថាតើជនជាតិចាមជាមុខសញ្ញាសម្លាប់របស់ខ្មែរក្រហមដោយសារតែបញ្ហាសាសនានិងអត្តសញ្ញាណជាតិឬយ៉ាងណា? សំបុត្រមួយនេះមិនមែនលើកឡើងត្រង់ៗតែអំពីប្រល័យពូជ-សាសន៍ទេ វាទាក់ទិនទៅនឹងបញ្ហាចំនួនជនជាតិចាមដែលត្រូវសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នេះជាការសំខាន់ដែលយើងត្រូវដឹងពីការប៉ាន់ស្មានដាក់លាក់នូវចំនួនពិតប្រាកដ ព្រោះរឿងរ៉ាវទាក់ទិនជុំវិញបញ្ហានេះគឺជាចំណុចបង្ហាញពីភ័ស្តុតាងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលប្រព្រឹត្តប្រឆាំងនឹងជនជាតិ ។

សៀវភៅខ្ញុំសរសេរចំណងជើងថា “អ៊ូគូបះ : យុត្តិធម៌សម្រាប់ចាមមូស្លីមក្រោមរបបប្រល័យពូជសាសន៍”បោះពុម្ពនៅឆ្នាំ២០០២ ខ្ញុំបានរកឃើញថា មានជនជាតិចាមចំនួនពី៤សែនទៅ៥សែននាក់ដែលបានបាត់បង់ជីវិតនៅអំឡុងខ្មែរក្រហមកាន់អំណាចរវាងឆ្នាំ១៩៧៥-១៩៧៩ ។ តួលេខនេះត្រូវបានបដិសេធពីសំណាក់អ្នកប្រាជ្ញមួយចំនួនដូចជាសាស្ត្រាចារ្យ ប៊ែន គៀរនិន ។ លោកបានបង្ហាញជំហរមិនទទួលស្គាល់ចំនួនតួលេខនេះនៅក្នុង“ការរិះគន់ការសិក្សារបស់ជនជាតិអាស៊ី” *(Critical Asian Studies)* កាលពីឆ្នាំ២០០៣ ដែលការរកឃើញនេះបង្ហាញពីតួលេខសរុបតិចជាងច្រើន ។ សាស្ត្រាចារ្យ ប៊ែន គៀរនិន បានរកឃើញចំនួនជនជាតិចាមជាង៨ម៉ឺន៧ពាន់នាក់បានស្លាប់នៅក្រោមរបបខ្មែរក្រហម ។ លោកអះអាងថា ការប៉ាន់ស្មាននៅក្នុងសៀវភៅរបស់ខ្ញុំគឺមិនស៊ីសង្វាក់គ្នានឹងស្ថាប័នដែលខ្ញុំបម្រើការទេ ។ លោកចាត់ទុកតួលេខនេះថាជា“ការធ្វេសប្រហែស” ។ តាមការប៉ាន់ស្មានរបស់បណ្ឌិត ម៉ៃឃើល វិកឃីរី នៅក្នុង“ព្រឹត្តិបត្រស្តីពីអ្នកប្រាជ្ញអាស៊ី” *(Bulletin of Concerned Asian Scholars)* កាលពីឆ្នាំ១៩៩០ ចំនួនជនជាតិចាមស្លាប់ក្នុងរបបខ្មែរក្រហមមានចំនួន១១០០០នាក់ ។ ចំណែកលោក ទូច បូរ៉ា យល់ឃើញថា តួលេខរបស់ ប៊ែន គៀរនិន មានភាពត្រឹមត្រូវដោយសារតួលេខនេះយោងតាមប្រភពកំណត់ត្រារបស់រដ្ឋាភិបាលនៅឆ្នាំ១៩៦២ ។ ការប្រែប្រួលនៃការប៉ាន់ស្មាននេះបណ្តាលមកពីការ



អ្នកដឹកនាំសាសនាអ៊ីស្លាមនៅវិហារអ៊ីស្លាម

ប្រើប្រាស់ប្រភពឯកសារខុសៗគ្នាយកមកគណនារកចំនួនជនជាតិចាមសរុបដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ ការប៉ាន់ស្មានរបស់ខ្ញុំគឺពឹងផ្អែកលើការចុះស្រាវជ្រាវជាច្រើនកន្លែងដែលខ្ញុំធ្វើជាមួយជនជាតិចាមផ្ទាល់ ។ ចំណែកការប៉ាន់ស្មានរបស់សាស្ត្រាចារ្យ ប៊ែន គៀរនិន និងបណ្ឌិត ម៉ៃឃើល វិកឃីរី យោងទៅតាមការគណនានៅក្នុងឯកសារបារាំងចន្លោះឆ្នាំ១៨៧៤-១៩៣៦ ។ ចំណែកតួលេខផ្តល់ឲ្យតាមរយៈលោក ទូច បូរ៉ា គឺយកតាមឯកសាររដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៦២ ។

ក្រោយមកសំណួរនេះត្រូវបានលើកឡើងម្តងទៀត ។ នា

ពេលថ្មីៗនេះ ខ្ញុំបានបន្តធ្វើការស្រាវជ្រាវជាលម្អិត ។ ខ្ញុំបានសម្ភាសជនជាតិចាមដែលតាំងទីលំនៅចំណាស់ស្រុកយូរយារណាស់មកហើយ និងប្រជាជនចាស់ៗដែលនៅរស់រានមានជីវិតតាំងពីសង្គមរាស្ត្រនិយមឆ្នាំ១៩៥៥-១៩៧០មកម្ល៉េះ ។ ក្នុងចំណោមប្រជាជនដែលខ្ញុំជួបភាគច្រើនជាអតីតប្រធានភូមិ ឬប្រធានឃុំកាលពីសម័យនោះ ។ ពេលដែលខ្ញុំសួរគាត់ ថាតើគាត់មានចាំពីចំនួនជនជាតិចាមរស់នៅសម័យនោះទេ គ្មានអ្នកណាម្នាក់ដឹងឮពីតួលេខនេះសោះ ។ ក្នុងនោះជនជាតិចាមដែលជាអតីតមន្ត្រីរាជការភូមិឃុំមួយចំនួនឆ្លើយថា គាត់មិនបានដឹងពីបញ្ហានេះទេ ព្រោះរបាយការណ៍ត្រួតពិនិត្យតាមភូមិឃុំទាំងអស់ត្រូវបញ្ជូនឡើងទៅថ្នាក់ស្រុក និងខេត្ត ។ របាយការណ៍ទាំងនោះមិនមានបញ្ជាក់ឲ្យបានល្អិតល្អន់អំពីចំនួនជនជាតិភាគតិចរួមទាំងចិន ចាម និងវៀតណាមនៅក្នុងតំបន់ឡើយ ។ និយាយរួម តួលេខនៅក្នុងរបាយការណ៍មិនបានបែងចែកឲ្យច្បាស់ពីក្រុមជនជាតិទេ ។ ជាងនេះទៅទៀត នៅក្នុងសម័យសង្គមរាស្ត្រនិយម សម្តេចព្រះនរោត្តម សីហនុ បានប្តូរឈ្មោះ "ចាម" ហៅថា "ខ្មែរអ៊ីស្លាម" វិញ ។ ទង្វើនេះត្រូវបានទទួលការរិះគន់ពីសំណាក់ជនជាតិចាមមួយចំនួនដែលអះអាងថា សម្តេចព្រះនរោត្តម សីហនុ មានចេតនាចង់លុបបំបាត់ចោលអត្តសញ្ញាណនៃជនជាតិចាម ។



...ស្វាយឃ្លាំង

ទាក់ទិននឹងជំរឿនប្រជាជនចាមនៅក្រោមរបបអាណានិគមបារាំង ពេលខ្ញុំសាកសួរជនជាតិចាមចំណាស់ៗពីការស្ទង់ចំនួនប្រជាជនរបស់បារាំង គ្មានអ្នកណាម្នាក់ដឹងពីរឿងនេះសោះ ។ លោកតា សែន ម៉ាត់ អាយុ៩២ឆ្នាំ ធ្លាប់ធ្វើការជាមួយបារាំងនៅចម្ការកៅស៊ូស្រុកមេម៉ត់ខេត្តកំពង់ចាម លោកតាបានប្រាប់ខ្ញុំថា គាត់ធ្លាប់ឃើញកំណត់ត្រារបស់បារាំងពីឈ្មោះកម្មករជាង ៣០០នាក់ ដែលធ្វើការនៅចម្ការកៅស៊ូ ។ កម្មករភាគច្រើនជាជនជាតិចាម ។ ជនជាតិបារាំងបានកត់ត្រាឈ្មោះទាំងនោះ ថាជា "ខ្មែរប្រមូលជ័រកៅស៊ូ" ។ បញ្ហានេះនាំឲ្យលេចឡើងជាសំណួរសង្កត់ធ្ងន់អំពីភាពត្រឹមត្រូវនៃតួលេខយោងតាមឯកសារពីអាណានិគមបារាំង ជាពិសេសរឿងដែលទាក់ទងនឹងការកត់ត្រាចំនួនជនជាតិចាម ។

តាមការគណនារបស់ ប៉ែន យៀរនិន គាត់លើកហេតុផលថា កាលពីឆ្នាំ១៩៧៥ មានជនជាតិចាមសរុប២សែន៥ម៉ឺននាក់ ។ ចំណែកបណ្ឌិត វិកឃឺរី អះអាងថា មាន១សែន៩ម៉ឺន១ពាន់នាក់ ។ បើទោះបីជាការសន្មតចំនួនជនជាតិចាមបង្ហាញថា ចំនួនជនជាតិចាមបច្ចុប្បន្ននៅប្រទេសកម្ពុជាមានចំនួនច្រើនជាងចំនួនជនជាតិចាមមុនសម័យខ្មែរក្រហមក៏ដោយ ភស្តុតាងជាក់ស្តែងចង្អុលបង្ហាញពីការសន្និដ្ឋានមួយផ្ទុយស្រឡះ ។

នៅក្នុងការចុះស្រាវជ្រាវរបស់ខ្ញុំថ្មីៗនេះ ខ្ញុំបានសាកសួរជនជាតិចាមនៅតាមភូមិនីមួយៗដើម្បីកំណត់ថា តើចំនួនជនជាតិចាមបច្ចុប្បន្នតិចឬច្រើនជាងចំនួនកាលពីឆ្នាំ១៩៧៥ ។ ចម្លើយដែលខ្ញុំទទួលបានភាគច្រើនពីអ្នកភូមិចាមគឺចំនួនជនជាតិចាមបច្ចុប្បន្នតិចជាងកាលពីជំនាន់មុន ។ រីឯអ្នកភូមិចាមមួយចំនួនទៀតថា តួលេខពីមុននិងបច្ចុប្បន្នគឺប្រហាក់ប្រហែលគ្នា ។ ក្នុងនោះមានតែអ្នកភូមិចាមមួយចំនួនតូចប៉ុណ្ណោះដែលផ្តល់ចម្លើយថា ចំនួនជនជាតិចាមបច្ចុប្បន្នកើនឡើងលើសកាលពីសម័យមុន ។ ខ្ញុំបានប្រមូលកត់ត្រាចម្លើយពីជនជាតិចាមនៅខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកំពង់ធំ និងខេត្តក្រចេះ ។ ទោះបីជានេះជាការពិតដែលថា ប្រជាជនចាមបានចាកចេញពីភូមិកំណើតនិងកសាងទីលំនៅថ្មី នេះជាករណីដែលអ្នកភូមិចាមបាត់ខ្លួនបន្ទាប់ពីខ្មែរក្រហមសម្លាប់ជនជាតិនេះទាំងស្រុងឬក៏ស្ទើរតែទាំងស្រុងនៃចំនួនប្រជាជនសរុប ។

យោងតាមតួលេខជាផ្លូវការដែលផ្តល់ជូនដោយ ឧកញ៉ា សុះ កីរី ប្រធានក្រុមប្រឹក្សាជាន់ខ្ពស់នៃកិច្ចការសាសនាអ៊ីស្លាម

នៅកម្ពុជាថា បច្ចុប្បន្ននេះមានជនជាតិចាមចំនួន៥សែន១ម៉ឺននាក់រស់នៅលើទឹកដីកម្ពុជា ។ តួលេខនេះផ្អែកលើការរាយការណ៍ពីវិហារអ៊ីស្លាមនៅទូទាំងប្រទេស ដូច្នេះគ្មានហេតុផលណាគួរឲ្យសង្ស័យពីភាពត្រឹមត្រូវនៃតួលេខនេះឡើយ ។ ដោយចំនួនប្រជាជនចាមនៅតាមតំបន់ភាគច្រើនតិចជាងចំនួនកាលពីមុនរបបខ្មែរក្រហម ជាពិសេសនៅតាមតំបន់ដែលជាទីប្រជុំរបស់ជនជាតិចាមកាលពីសម័យបុរាណ ។ ដូចជានៅខេត្តកំពង់ចាម យើងអាចសន្និដ្ឋានថា មានជនជាតិចាមចំនួន៥សែននាក់មុនសម័យខ្មែរក្រហម ។ តួលេខរបស់ខ្ញុំដែលថាមានជនជាតិចាមមានរហូតដល់៧សែននាក់មុនឆ្នាំ១៩៧៥ ហាក់ដូចជាល្អមអាចទុកចិត្តបាន បើធៀបនឹងពត៌មាននេះ ។

ជាការពិតណាស់ នេះជាផ្នែកមួយស្មុគស្មាញនៅក្នុងកិច្ចការស្រាវជ្រាវដោយសារតែមេដឹកនាំសហគមន៍ចាមស្ទើរតែទាំងអស់បានបាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហម ។ អ្នកទាំងអស់គ្នាច្បាស់ជាយល់ស្របថា ចាំបាច់គួរតែមានទិន្នន័យពីការចុះស្រាវជ្រាវជាក់ស្តែងបន្ថែមពីលើតួលេខពីសម័យអាណានិគមដែលអ្នកប្រាជ្ញនិយមប្រើប្រាស់ ។ ដោយបានចុះធ្វើការស្រាវជ្រាវនិងការចុះសម្ភាសយ៉ាងល្អិតល្អន់អស់រយៈពេលពីរបីឆ្នាំ យើងរីករាយនឹងនិយាយថា ឥឡូវនេះមានទិន្នន័យជាប្រវត្តិសាស្ត្រកាន់តែជាក់លាក់ដែលអាស្រ័យលើរឿងរ៉ាវជាក់ស្តែងរបស់សាក្សី ។ សៀវភៅខ្នាតវែងដែលនឹងបោះពុម្ពផ្សាយនាពេលខាងមុខនេះមានចំណងជើងថា "ការបះបោររបស់ជនជាតិចាម" *(The Cham Rebellion)* នឹងបង្ហាញពីពត៌មានបានពីប្រភពដើមនិយាយពីបទពិសោធន៍របស់ជនជាតិចាមនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យរួមទាំងការសម្លាប់ជនជាតិចាមនៅខេត្តកំពង់ចាមនៅចន្លោះឆ្នាំ១៩៧៣-១៩៧៩ ។ នៅក្នុងកំណត់ត្រាផ្ទាល់ខ្លួន ខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវនិងសៀវភៅនេះនឹងនាំមកនូវការយល់ដឹងកាន់តែជ្រាលជ្រៅពីទុក្ខលំបាករបស់ចាមម៉ូស្លីមនៅសម័យសោកនាដកម្មនៃការបាត់បង់ធនធានមនុស្សដ៏ច្រើនលើសលប់ ។ អ្នកអានអាចទាញការសន្និដ្ឋានដោយផ្អែកលើព្រឹត្តិការណ៍ពិតថាតើកាលដែលខ្មែរក្រហមសម្លាប់ជនជាតិចាមអាចកំណត់ថាជាអំពើប្រល័យពូជសាសន៍ ដែរឬទេ? **អ៊ីសា ឧស្មាន**

# ការតស៊ូនិងការផ្សះផ្សា ពិនិត្យមើលសហគមន៍ម៉ូស្លីមនៅប្រទេសរ៉្វាន់ដា

អំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាដែលបានកើតឡើងរវាងខែមេសានិងខែកក្កដា ឆ្នាំ១៩៩៤ បានធ្វើឲ្យប្រជាជនពី៨សែនទៅ១លាននាក់ស្លាប់បាត់បង់ជីវិត ហើយប្រទេសនៅទ្វីបអាហ្វ្រិកខាងកើតមួយនេះមិនទាន់ទទួលបានការព្យាបាលរបួសផ្លូវចិត្តពីព្រឹត្តិការណ៍ទាំងនោះឲ្យបានពេញលេញនៅឡើយ ។ ជនជាតិរ៉្វាន់ដាច្រើនលើសលប់បានវាយប្រហារទៅលើសមាជិកគ្រួសារនិងអ្នកជិតខាងរបស់ខ្លួន ក្នុងគោលបំណងលុបបំបាត់ចោលទាំងស្រុងនូវក្រុមជាតិពន្ធុមួយ និងអ្នកគាំទ្រទាំងឡាយរបស់ក្រុមនេះពីប្រទេសរ៉្វាន់ដា ។ នៅក្នុងប្រទេសដែលប្រជាជនភាគច្រើនគោរពជំនឿសាសនាគ្រិស្តនិកាយកាតូលិក អាចារ្យនិងដូនជីក៏បានចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ហើយប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់រង្គាលនៅក្នុងព្រះវិហារកាតូលិក ដែលអ្នកទាំងអស់សង្ឃឹមថា ព្រះវិហារនឹងអាចជួយស្រោចស្រង់ជីវិតរបស់ខ្លួនបាន ។

ក្នុងពេលជាមួយគ្នានោះដែរ សហគមន៍អ៊ីស្លាមនៅប្រទេសរ៉្វាន់ដាបានផ្តល់ការការពារនិងសុវត្ថិភាពដល់ជនជាតិទុតស៊ីនិងជនជាតិហ៊ូទូ ។ ទាំងម៉ូស្លីមនិងអ្នកមិនមែនម៉ូស្លីមនៅរ៉្វាន់ដាបានទទួលស្គាល់យ៉ាងទូលំទូលាយថា សហគមន៍អ៊ីស្លាមបានបដិសេធមិនចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ។ ផ្ទុយទៅវិញ សហគមន៍អ៊ីស្លាមទាំងនេះបានបញ្ចេញសកម្មភាពវិជ្ជមានក្នុងគោលបំណងជួយសង្គ្រោះនិងជួយឧបត្ថម្ភដល់ទាំងជនជាតិរ៉្វាន់ដាដែលកាន់សាសនាអ៊ីស្លាមនិងអ្នកមិនកាន់សាសនាអ៊ីស្លាម ។ ស្មារតីនៃ

សាមគ្គីភាពសង្គមនិងការគោរពជំនឿសាសនាយ៉ាងម៉ឺងម៉ាត់របស់សហគមន៍អ៊ីស្លាមបានកាត់បន្ថយសារសំខាន់នៃជាតិពន្ធនិងអនុញ្ញាតឲ្យមូស្លីមអាចទប់ទល់បានទៅនឹងការឃោសនាឲ្យមានការប្រេះឆាស្អប់ខ្ពើម ហើយថែមទាំងអាចធ្វើសកម្មភាពជួយសង្គ្រោះជីវិតមនុស្សទៀតផង ។ ការប្រឆាំងនឹងអំពើប្រល័យពូជសាសន៍និងសកម្មភាពជួយសង្គ្រោះរបស់ក្រុមអ្នកកាន់សាសនាអ៊ីស្លាមគឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់មេដឹកនាំសាសនាអ៊ីស្លាមការប្រៀនប្រដៅពីសំណាក់សាសនានិងគម្ពីរគួរអាននិងការមិនឲ្យតម្លៃទៅលើសហគមន៍មូស្លីមតាំងពីយូរមកហើយពីសំណាក់វប្បធម៌នៅក្នុងប្រទេសរ៉្វាន់ដា ។ ទាំងអស់នេះបានធ្វើឲ្យសាមគ្គីភាពនៅក្នុងសហគមន៍កាន់តែរឹងមាំថែមទៀត ។ នៅក្នុងឆ្នាំបន្តបន្ទាប់ក្រោយពីអំពើប្រល័យពូជសាសន៍ ចំនួនអ្នកកាន់សាសនាអ៊ីស្លាមនៅប្រទេសរ៉្វាន់ដាមានការកើនឡើងយ៉ាងឆាប់រហ័សដោយសារតែចំនួនប្រជាជនកាន់តែច្រើនឡើងៗបានចូលសាសន៍និងគោរពបូជាសាសនាអ៊ីស្លាម ។ សាសនាអ៊ីស្លាមក៏បានដើរតួនាទីយ៉ាងសំខាន់នៃដំណើរការផ្សះផ្សាជាតិនៅក្នុងប្រទេសដែលមិនទាន់បានជាសះស្បើយពីផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ ។

## ប្រវត្តិនៃសាសនាអ៊ីស្លាមនៅក្នុងប្រទេសរ៉្វាន់ដា

សាសនាអ៊ីស្លាមត្រូវបាននាំចូលប្រទេសរ៉្វាន់ដាតាមរយៈអ្នកជំនួញជនជាតិអារ៉ាប់និងឥណ្ឌា ដែលមានដើមកំណើតនៅប្រទេសតង់ហ្សានីនិងតំបន់ឆ្នេរស្វាហីលីនៅអាហ្វ្រិកខាងកើតនាចុងសតវត្សរ៍ទី១៩ ។ នៅក្នុងអំឡុងពេលនៃការចាប់ផ្តើមការដាក់អាណានិគមពីសំណាក់ប្រទេសក្នុងទ្វីបអឺរ៉ុបនៅឆ្នាំ១៩០៨ អ្នកកាន់សាសនាអ៊ីស្លាមជាច្រើនក្រុមបន្ថែមទៀតបានចូលមកប្រទេសនេះ ហើយវិហារអ៊ីស្លាមទីមួយត្រូវបានកសាងឡើងក្នុងឆ្នាំ ១៩១៣ ។ ពីដំបូងឡើយ អ្នកកាន់សាសនាអ៊ីស្លាមនៅរ៉្វាន់ដាភាគច្រើនជាជនបរទេសដែលនិយាយភាសាគីស្វាហីលី (Kiswahili) ដែលប្រឆាំងទៅនឹងភាសាឃីនយ៉ារ៉្វាន់ដា (Kinyarwanda) ដែលជាភាសាកំណើតរបស់ជនជាតិរ៉្វាន់ដា ។ ក្រុមមូស្លីមទាំងនេះបញ្ចេញសកម្មភាព ស្លៀកពាក់ និងហូបចុកខុសគ្នាពីប្រជាជនក្នុងស្រុក ។ នៅពេលសហគមន៍តូចៗជាច្រើនត្រូវបានបង្កើតឡើង មេដឹកនាំសាសនាអ៊ីស្លាមមួយចំនួនត្រូវបានអញ្ជើញឲ្យចូលមកដើម្បីដឹកនាំសាសនិកដែលមានចំនួនកាន់តែកើនឡើង ។ នៅពេលសហគមន៍សាសនានេះមានការវិវឌ្ឍឡើងកាន់តែខ្លាំង ជនជាតិរ៉្វាន់ដាមួយចំនួនទាំងជាតិទុតស៊ីទាំងជាតិហ៊ូទូបាននាំគ្នាផ្លាស់ប្តូរមកចូលសាសនាអ៊ីស្លាមវិញ ។

មេដឹកនាំប្រពៃណីរបស់រ៉្វាន់ដានិងសាសនទូតអឺរ៉ុប បានមើលឃើញសាសនាអ៊ីស្លាមជាការគំរាមកំហែងមួយ និងបានដាក់ចេញនូវគោលនយោបាយរើសអើងមួយចំនួន ដែលនៅមានបន្តរហូតមកដល់សម័យក្រោយឯករាជ្យ ។ ជនជាតិរ៉្វាន់ដាភាគច្រើនទទួលឥទ្ធិពលពីគោលនយោបាយអវិជ្ជមានដែលបានបណ្តាលឲ្យមានការរើសអើងនៅក្នុងសង្គម ។ អ្នកកាន់សាសនាអ៊ីស្លាមទទួលបានឱកាសតិចតួចសម្រាប់ការអប់រំ ។ ទោះបីជាអ្នកកាន់សាសនាអ៊ីស្លាមមួយចំនួនអាចចុះឈ្មោះចូលរៀននៅតាមសាលារ៉្វាន់ដា ដែលគ្រប់គ្រងដោយវិហារសាសនាគ្រិស្តក៏ដោយក៏អ្នកទាំងនេះជួបប្រទះនូវការលំបាកជាច្រើននៅក្នុងការសម្ភាសចុះឈ្មោះចូលរៀនដែរ ។ ការរឹតត្បិតផ្នែកអប់រំមានន័យថាអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់ត្រូវបានដាក់កំហិតមិនឲ្យធ្វើការទៅលើការងារទាំងឡាយណាដែលទាក់ទងនឹងពាណិជ្ជកម្ម ។ ការដាក់កំហិតទៅលើឱកាសការងារបានបង្ខាំងឲ្យអ្នកកាន់សាសនាអ៊ីស្លាមមិនអាចទទួលបានអំណាចនិងឥទ្ធិពលនៅក្នុងប្រទេស ។ ហេតុដូច្នេះហើយ ជនមូស្លីមមានឥទ្ធិពលតិចតួចទៅលើរដ្ឋាភិបាលអាណានិគមបែលហ្ស៊ិកឬរដ្ឋាភិបាលក្នុងស្រុក ។

នៅដើមសតវត្សរ៍ទី២០ ជនមូស្លីមត្រូវបានកំណត់ឲ្យរស់នៅក្នុងតំបន់កំហិតមួយ ដែលអ្នកទាំងនេះមិនអាចចាកចេញពីតំបន់ដែលខ្លួនរស់នៅដោយគ្មានការអនុញ្ញាត ត្រូវបានហាមឃាត់មិនឲ្យមានកម្មសិទ្ធិលើដីធ្លីនិងមិនឲ្យធ្វើស្រែចម្ការ ឬចិញ្ចឹមសត្វនៅក្នុងតំបន់រស់នៅរបស់ខ្លួន ។ ប្រជាជនរ៉្វាន់ដាដែលរស់នៅក្រៅតំបន់កំហិត មិនត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងតំបន់នេះដោយគ្មានការអនុញ្ញាតបានឡើយ ។ តំបន់កំហិតទាំងនេះជាញឹកញាយត្រូវបានហៅថា “ជំរំស្វាហីលី” ឬ “មជ្ឈមណ្ឌលក្រៅប្រពៃណី” ហើយអ្នករស់នៅក្នុងតំបន់ទាំងនេះត្រូវបានចាត់ទុកថាជា“មនុស្សមិនស្ថិតនៅក្នុងកុលសម្ព័ន្ធ” ។ ប្រជាជននៅក្នុងតំបន់កំហិតទាំងនោះមានមេដឹកនាំនិងតុលាការផ្ទាល់ខ្លួន ដែលត្រូវបានចាត់តាំង

ឡើងឲ្យជាស្រេច ។ ប្រការនេះបានធ្វើឲ្យប្រជាជនទាំងនេះមានកម្រិតសេរីភាពខុសពីជនជាតិរ៉ាន់ដាផ្សេងៗទៀត ក្រៅពីការមិនឲ្យតម្លៃទៅលើក្រុមនេះ ។

ទោះបីជាក្រោយមកជនមូស្លីមឈប់តម្រូវឲ្យទៅរស់នៅក្នុងតំបន់កំហិតតទៅទៀតបន្ទាប់ពីប្រទេសរ៉ាន់ដាទទួលបានឯករាជ្យមកក៏ដោយ ក៏ប្រជាជនកាន់សាសនាអ៊ីស្លាមហាក់ដូចជាត្រូវទៅរស់នៅក្នុងសហគមន៍មួយដាច់ដោយឡែក ។ ជនមូស្លីមភាគច្រើនរស់នៅក្នុងតំបន់ ប៊ីយ៉ូហ្គូ (Biryogo) ជាយរដ្ឋធានីគីហ្គាលី (Kigali) ។ ជនមូស្លីមនៅប្រទេសរ៉ាន់ដាបានបន្តរស់នៅដាច់ដោយឡែកពីជនជាតិរ៉ាន់ដាកាន់សាសនាគ្រិស្តភាគច្រើនផ្សេងទៀត ហើយភាគច្រើនត្រូវបានចាត់ទុកថាជាអ្នកប្រឆាំងនឹងក្រុមជាតិពន្ធហ៊ូទូនិងទុតស៊ី ដែលជាក្រុមជនជាតិចម្បងពីរនៅរ៉ាន់ដា ។ ជនមូស្លីមត្រូវបានរើសអើងនៅក្នុងសង្គមក្នុងនាមជាក្រុមមួយដែលប្រការនេះបានជួយពង្រឹងឡើងវិញនូវគោលជំហរនៃអត្តសញ្ញាណរបស់សហគមន៍ដែលរឹងមាំជាងការដាក់អត្ត-សញ្ញាណឲ្យទៅទៀត ។

រ៉ាន់ដា (ក្រុមជនជាតិត្វា Twa មានចំនួនមួយភាគរយនៃចំនួនប្រជាជនសរុប) ។ ពាក្យ“ទុតស៊ី” តាំងពីដើមមកសំដៅទៅលើក្រុមវណ្ណៈម្ចាស់ដីនិងម្ចាស់គោក្របី ហើយពាក្យ“ទុតស៊ី” សំដៅទៅលើវណ្ណៈទាបជាង ដែលជាអ្នកមើលថែដីចម្ការឲ្យជនជាតិហ៊ូទូ ។ ពីដំបូង ពាក្យទាំងនេះគឺប្រើសំដៅទៅលើសេដ្ឋកិច្ចសង្គម មិនមែនក្រុមជាតិពន្ធនោះទេ ដែលហ៊ូទូអាចក្លាយទៅជាទុតស៊ីដោយការខិតខំប្រមូលដីស្រែនិងទ្រព្យសម្បត្តិផ្សេងៗ ។ ពាក្យនេះបានក្លាយទៅជាពាក្យសម្រាប់សម្គាល់ក្រុមជាតិពន្ធកាន់តែធំឡើងៗនៅក្រោមរបបអាណានិគមប៊ែលហ្ស៊ិក ដែលបានធ្វើឲ្យភាពខុសគ្នារវាងក្រុមទាំងពីរដែលបានកើតមានរួចមកហើយ កាន់តែមានសភាពធ្ងន់ធ្ងរឡើង ។ ក្រុមទាំងពីរគោរពជំនឿសាសនាតែមួយ និយាយភាសាតែមួយ អនុវត្តវប្បធម៌ប្រពៃណីតែមួយ ហើយជាញឹកញយរៀបការឆ្លងសាសន៍ទៀតផង ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលអាណានិគមប៊ែលហ្ស៊ិកមើលឃើញក្រុមជាតិពន្ធទុតស៊ីដែលមានកម្ពស់ខ្ពស់ជាងឬមានរូបរាងរបៀបអឺរ៉ុប ឬសម្បុរសថាជាក្រុមជាតិពន្ធដែលមានឋានៈសង្គមខ្ពស់ជាងក្រុមជាតិពន្ធហ៊ូទូ ។ រដ្ឋាភិបាលអាណានិគមប៊ែលហ្ស៊ិកជឿជាក់ថា ក្រុមជាតិពន្ធទុតស៊ីមានដើមកំណើតពី ហាមីទិក (Ham គឺជាតួអង្គនៅក្នុងគម្ពីរគ្រិស្តចាស់និងជាកម្លាំងខាងក្រៅដែលបានចូលមកប្រទេសរ៉ាន់ដាហើយឈ្នះពានក្រុមហ៊ូទូ) ។ ហេតុដូច្នេះ ក្រុមទុតស៊ីត្រូវបានផ្តល់ឋានៈជាវណ្ណៈអភិជន និងមានបុព្វសិទ្ធិច្រើនជាងក្រុមហ៊ូទូ ហើយថែមទាំងត្រូវបានផ្តល់តួនាទីនៅក្នុងការគ្រប់គ្រងប្រទេសទៀតផង ។



## អំពើប្រល័យពូជសាសន៍

ការបែងចែកជាតិសាសន៍រវាងក្រុមភាគច្រើនហ៊ូទូនិងក្រុមភាគតិចទុតស៊ីបានកើតមានឡើងជាយូរមកហើយ នៅក្នុងប្រទេស

កំណត់សម្គាល់នៃការបែងចែកនិងភាពខុសគ្នានៃក្រុមជនជាតិទាំងពីរកាន់តែមានភាពតានតឹងឡើងនៅក្រោមរបបអាណា

និគមប៊ែលហ្ស៊ិក ដែលទាំងក្រុមទុតស៊ីនិងក្រុមហ៊ូទូត្រូវបានផ្តល់ឲ្យនូវអត្តសញ្ញាណប័ណ្ណ ដែលកំណត់អត្តសញ្ញាណជនជាតិរៀងខ្លួនទៀតផង ។ ទោះជាយ៉ាងនេះក្តី នៅពេលប្រទេសរ៉្វាន់ដាទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៩ អាណានិគមប៊ែលហ្ស៊ិកបានជ្រើសរើសការកែប្រែគោលនយោបាយគ្រប់គ្រងអំណាចក្នុងប្រទេស ។ អាណានិគមប៊ែលហ្ស៊ិកបានផ្តល់អំណាចគ្រប់គ្រងប្រទេសទៅឲ្យក្រុមភាគច្រើនហ៊ូទូ ដែលបានចាត់ទុកខ្លួនឯងថាជាវណ្ណៈដែលត្រូវបានជិះជាន់ជាយូរមកហើយ បើប្រៀបធៀបទៅនឹងក្រុមទុតស៊ីដែលត្រូវបានដឹងឮថា ក្រុមដែលបានឈ្លានពានទឹកដីរបស់ហ៊ូទូ ។ ការយល់ឃើញខុសគ្នារវាងក្រុមហ៊ូទូនិងទុតស៊ីកាន់តែមានសភាពតឹងតែងឡើង ហើយត្រូវបានក្រុមទាំងពីរទទួលស្គាល់ថាជាការពិត ។ ក្រុមភាគច្រើនហ៊ូទូមិនជឿថា ក្រុមទុតស៊ីគឺជាជនជាតិរ៉្វាន់ដាពិតប្រាកដនោះទេ ។ នៅក្រោមរបបថ្មីគ្រប់គ្រងដោយហ៊ូទូ ក្រុមទុតស៊ីត្រូវបានធ្វើទុក្ខបុកម្នេញនិងទទួលការរើសអើងដែលការសម្លាប់រង្គាលមិនទៀតទាត់ជាច្រើនបានកើតមានឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់ហ៊ូទូ ។ ប្រតិកម្មទៅនឹងការសម្លាប់រង្គាលនេះក្រុមទុតស៊ីសញ្ជាតិរ៉្វាន់ដាដែលកំពុងរស់នៅប្រទេសអ៊ូហ្កង់ដា **(Uganda)** បានបង្កើតរណសិរ្សស្នេហាជាតិរ៉្វាន់ដា **(RPF)** ដែលដឹកនាំដោយប៉ូល កាហ្កាមី (ប្រធានាធិបតីរ៉្វាន់ដាសព្វថ្ងៃ) ។ នៅឆ្នាំ១៩៩០ រណសិរ្សស្នេហាជាតិរ៉្វាន់ដាបានចូលឈ្លានពានប្រទេសរ៉្វាន់ដាក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទាមទារសិទ្ធិជាជនជាតិរ៉្វាន់ដា ។ ប៉ុន្តែក្រុមហ៊ូទូបានចាត់ទុកការវាយប្រហារនេះថា ជាការព្យាយាមដើម្បីបង្កើតឡើងវិញនូវឋានានុក្រមអំណាចរបស់ក្រុមអាណានិគម ។



អដ្ឋិធាតុជនរងគ្រោះនៅបូជនីដ្ឋានតាវ៉ាម៉ាប្រទេសរ៉្វាន់ដា

នៅឆ្នាំ១៩៩៣ ដោយមានសម្ពាធពីសហគមន៍អន្តរជាតិ រណសិរ្សស្នេហាជាតិរ៉្វាន់ដានិងរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារុហ្សា **(Arusha)** ដែលជាកិច្ចព្រមព្រៀងបែងចែកអំណាច ដើម្បីបញ្ចប់សង្រ្គាមស៊ីវិលនៅក្នុងប្រទេស ។ ទោះជាយ៉ាងនេះក្តី ប្រធានាធិបតីរ៉្វាន់ដា ជូវេណាល់ ហាប៊ីយ៉ារី ម៉ាណា **(Juvenal Habyarimana)** ទទួលការរិះគន់យ៉ាងខ្លាំងពីក្រុមជ្រុលនិយមហ៊ូទូនៅក្នុងជួររដ្ឋាភិបាលរបស់លោក ។ កិច្ចព្រមព្រៀងនេះបានធ្វើឲ្យក្រុមជ្រុលនិយមហ៊ូទូបង្កើនយុទ្ធនាការជាតិនិយម ។ ស្ថានីយវិទ្យុនិងកាសែតបានចាប់ផ្តើមផ្សព្វផ្សាយពីគំនិតជាតិនិយមហួសហេតុនិងការឃោសនាបំបែកបំបាក់ ។ ការឃោសនាទាំងនេះបានលុបបំបាត់ភាពជាមនុស្សរបស់ក្រុមទុតស៊ីដោយធ្វើការពណ៌នាក្រុមនេះថាជា "ពួកកន្លាត" ដែលត្រូវតែលុបបំបាត់ចោល និងផ្សព្វផ្សាយអំពីសង្គមរ៉្វាន់ដាប្រសើរជាងមិនមានជនជាតិទុតស៊ី ។ អាវុធគ្រប់ប្រភេទត្រូវបានរៀបចំទុកហើយកងយោធាហ៊ូទូដែលត្រូវបានស្គាល់ថាជា "ក្រុមប្រហាររួម" ត្រូវបានបង្កើតឡើងនិងហ្វឹកហ្វឺន ។

អំពើប្រល័យពូជសាសន៍បានចាប់ផ្តើមឡើងពិតប្រាកដនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ នៅពេលដែលយន្តហោះដឹកលោកប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា និងលោកប្រធានាធិបតី បូរុនឌី ត្រូវបាញ់ទម្លាក់ ។ ក្រុមហ៊ូទូបានចោទប្រកាន់ឧបទ្ទវហេតុនេះទៅ

លើក្រុមខុទ្ទាមទុតស៊ី ហើយបានបិទរដ្ឋធានីគីហ្គាលី ។ អ្វីដែលបានកើតឡើងជាបន្តទៀតនោះ គឺការប៉ុនប៉ងដែលបានរៀបចំទុកយ៉ាងល្អ ដែលក្រុមជ្រុលនិយមហ៊ូទូអាចប្រមូលកងកម្លាំងយោធានិងហ៊ូទូសាមញ្ញ ដើម្បីសម្លាប់រង្គាលក្រុមទុតស៊ីនិងហ៊ូទូនិយមកណ្តាល ។ របាំងបិទផ្លូវរាប់រយត្រូវបានដាក់ដើម្បីកំហិតការធ្វើដំណើរនិងនាំឲ្យមានការសម្លាប់ ។ ហើយវិទ្យុរបស់ក្រុមជ្រុលនិយមហ៊ូទូបានដាក់ចេញនូវបទបញ្ជារអំពីទីកន្លែងនិងមនុស្សណាដែលត្រូវសម្លាប់ ។ អត្តសញ្ញាណប័ណ្ណដែលធ្វើឡើងនៅក្រោមរបបអាណានិគមបែលហ្សិក ដែលបានបង្ហាញអំពីក្រុមជនជាតិបានជួយសម្រួលដល់ការតាមសម្លាប់នេះ ។ ក្រុមទុតស៊ីនិងហ៊ូទូនិយមកណ្តាល ត្រូវបានបណ្តេញចេញពីផ្ទះសម្បែង វាយធ្វើបាបទទួលទារុណកម្ម និងកាប់សម្លាប់ដោយកាំបិតដែលមានដងខ្លីផ្លែវែង (ជាឧបករណ៍ប្រើបានច្រើនបែបជាពិសេស ប្រើសម្រាប់កាត់ធញ្ញជាតិនៅតាមចម្ការ) ឬដោយអាវុធផ្សេងៗ ទៀត ដោយមិនគិតពីអាយុនិងភេទ ។ ស្ត្រីត្រូវបានចាប់រំលោភក្នុងគោលបំណងដើម្បីលុបបំបាត់ចោលឈាមជ័រជាជាតិទុតស៊ី ព្រោះថាកូនក្មេងដែលកើតចេញពីស្ត្រីដែលទទួលការចាប់រំលោភនឹងមានឈាមពាក់កណ្តាលជាជាតិហ៊ូទូ ។ ដូច្នេះ វាមានលក្ខណៈបរិសុទ្ធជាង ។ ទោះបីជាព្រឹត្តិការណ៍ទាំងនេះត្រូវបានមើលឃើញយ៉ាងច្បាស់ថាជាការផ្ទុះឡើងនូវការស្អប់ខ្ពើមក្រុមកុលសម្ព័ន្ធមួយក៏ដោយ ក៏ប្រការនេះមិនមែនជាចំណុចសំខាន់ ព្រោះអំពើប្រល័យពូជសាសន៍គឺជាការគ្រោងទុកនិងការរៀបចំទុកមុនយ៉ាងល្អ ដែលអ្នកនយោបាយជាន់ខ្ពស់ នាយទាហាន និងអ្នកជំនួញបានផ្សព្វផ្សាយពីការប្រឆាំងនឹងក្រុមទុតស៊ីនិងអំណាចរបស់ហ៊ូទូនៅតាមសាលារៀននិងប្រព័ន្ធផ្សព្វផ្សាយ ។ បញ្ជីសម្លាប់ក្រុមទុតស៊ីត្រូវបានរៀបចំឡើងមុនការចាប់ផ្តើមអំពើប្រល័យពូជសាសន៍ទៅទៀត ។ ក្រុមយោធាជ្រុលនិយមបានលើកទឹកចិត្តនិងជាញឹកញយបានបង្ខំឲ្យជនជាតិហ៊ូទូទាំងអស់ចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ។ ហ៊ូទូទាំងឡាយណាដែលប្រឆាំងនឹងគោលការណ៍នេះអាចមានគ្រោះថ្នាក់ដល់ជីវិត ហើយមានហ៊ូទូជាច្រើនត្រូវបានសម្លាប់ដោយសារតែបដិសេធមិនព្រមចូលរួម ។

នៅក្នុងរយៈកាលនោះ សហគមន៍អន្តរជាតិនិងអង្គការសហប្រជាជាតិបានធ្វើកិច្ចការតិចតួចណាស់ ហើយថែមទាំងបរាជ័យក្នុងការធ្វើឲ្យមានការទទួលស្គាល់ថា ការកាប់សម្លាប់នេះជាអំពើប្រល័យពូជសាសន៍រហូតដល់ពេលក្រោយយូរមកទៀត ។ អង្គការសហប្រជាជាតិថែមទាំងបរាជ័យក្នុងការឆ្លើយតបទៅនឹងរបាយការណ៍អំពីការប្រមូលផ្តុំរបស់កងយោធាហ៊ូទូនិងការបង្កើតបញ្ជីឈ្មោះក្រុមទុតស៊ី (ជាពិសេសបញ្ជីសម្លាប់) នៅមុនពេលអំពើប្រល័យពូជសាសន៍ ។ ក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ អង្គការសហប្រជាជាតិមានតែកងកម្លាំងរក្សាសន្តិសុខដ៏ខ្សោយមួយប៉ុណ្ណោះ ដែលឈរជើងនៅនឹងកន្លែង ហើយកងកម្លាំងនេះត្រូវបានបង្កើតឡើងគ្រាន់តែដើម្បីជួយអនុវត្តកិច្ចព្រមព្រៀងសន្តិភាពក្រុមអារុហ្សា ។ កងកម្លាំងនេះត្រូវបានកាត់បន្ថយអស់ជាច្រើនក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ហើយកងរក្សាសន្តិភាពដែលសេស



មនុស្សប្រហែល២០០០នាក់ប្រមូលផ្តុំគ្នាថ្វាយបង្គំនៅមុខវិហារម៉ាស្ជិទអាល់ហ្វាត់ ក្នុងទីក្រុងគីហ្គាលី

សល់អាចធ្វើកិច្ចការបានតិចតួចណាស់ជាមួយនឹងអំណាចទន់ខ្សោយ ។ កងកម្លាំងនេះត្រូវបានហាមប្រាមមិនឲ្យទាក់ទងចរចាជាមួយកងយោធារដ្ឋាភិបាលឬដកអាវុធពីក្រុមនេះទេ លើកលែងតែក្នុងករណីការពារខ្លួនប៉ុណ្ណោះ ។ ក្នុងរយៈពេលតែ១០០ថ្ងៃជនជាតិទុតស៊ីនិងជនជាតិហ៊ូទូនិយមកណ្តាលជាង៨សែននាក់ត្រូវបានសម្លាប់ ដែលភាគច្រើនស្លាប់ក្រោមដៃអ្នកជិតខាងឬសមាជិកគ្រួសាររបស់ខ្លួន ។ អំពើប្រល័យពូជសាសន៍ត្រូវបានបញ្ចប់នៅពាក់កណ្តាលខែកក្កដា នៅពេលរណសិរ្សស្នេហាជាតិរ៉្វាន់ដាបានផ្តួលរំលំរដ្ឋាភិបាល ដែលដឹកនាំដោយក្រុមហ៊ូទូ ។ ជនជាតិហ៊ូទូរាប់ពាន់នាក់បានរត់ភៀសខ្លួនទៅប្រទេសហ្សាអៀរ (សព្វថ្ងៃជាសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) ដែលបន្តឲ្យមានវិបត្តិជនភៀសខ្លួនយ៉ាងធ្ងន់ធ្ងរ ដែលចុងក្រោយទទួលបានការចាប់អារម្មណ៍ពីអន្តរជាតិ ។

## សកម្មភាពជនមូស្លីមក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍

ទោះបីជាកើតមានអំពើហិង្សាក្នុងទ្រង់ទ្រាយធំយ៉ាងណាក៏ដោយ ក៏សហគមន៍អ៊ីស្លាមក្នុងប្រទេសរ៉្វាន់ដាមិនបានចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ដូចសហគមន៍ផ្សេងៗទៀតនៅក្នុងប្រទេសនោះទេ ។ សហគមន៍អ៊ីស្លាមបានបង្ហាញពីឧទាហរណ៍ទាំងពីរ ទាំងការប្រឆាំងអកម្មដែលប្រជាជនបដិសេធមិនចូលរួមក្នុងការកាប់សម្លាប់ និងការប្រឆាំងសកម្មដែលប្រជាជនបានប្រថុយប្រថាននឹងគ្រោះថ្នាក់ដល់ជីវិតដើម្បីការពារនិងសង្គ្រោះជីវិតអ្នកដទៃ ។ ហ្សង់ ព្យែរ សាហ្កាហ៊ូទូ (Jean Pierre Sagahutu) ដែលបានចូលសាសន៍ជាអ៊ីស្លាម បានរៀបរាប់ពីបទពិសោធន៍របស់គាត់ក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ «សម្រាប់ជនជាតិរ៉្វាន់ដា ក្រុមមូស្លីមគឺជាអ្នកប្រយុទ្ធដើម្បីសេរីភាពរបស់យើងក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ។ ខ្ញុំចង់លាក់ខ្លួននៅក្នុងព្រះវិហារគ្រិស្ត ប៉ុន្តែនោះគឺជាកន្លែងមិនមានសុវត្ថិភាព ។ ផ្ទុយទៅវិញ គ្រួសារមូស្លីមមួយបានជួយលាក់បំពួនខ្ញុំ ។ ពួកគេបានសង្គ្រោះជីវិតខ្ញុំ» ។ ជនជាតិទុតស៊ីរាប់ពាន់នាក់ត្រូវបានសម្លាប់នៅក្នុងព្រះវិហារគ្រិស្ត ដែលអ្នកទាំងនេះបានរត់ទៅជ្រកកោន ដោយចាត់ទុកជាកន្លែងអាចសង្គ្រោះជីវិតបាន ។ អាចារ្យក្នុងព្រះវិហារបានញុះញង់ឲ្យមានការសម្លាប់ ហើយជាញឹកញយបានផ្តល់ព័ត៌មានអំពីកន្លែងជ្រកកោនសុវត្ថិភាពខុសដែលធ្វើឲ្យជនជាតិទុតស៊ីត្រូវបានសម្លាប់យ៉ាងងាយ ។ ថ្នាក់ដឹកនាំជាន់ខ្ពស់ព្រះវិហារគ្រិស្តជាច្រើន ឥឡូវកំពុងតែត្រូវបានកាត់ទោសពីបទចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ។ ផ្ទុយទៅវិញ មិនមានមេដឹកនាំសាសនាអ៊ីស្លាមណាមួយត្រូវបានចោទប្រកាន់ឬចាប់ខ្លួនពីបទចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ហើយជាទូទៅជនមូស្លីមតិចតួចណាស់ត្រូវបានឃុំឃាំងពីបទប្រល័យពូជសាសន៍ ។ អ្នករួចរស់ជីវិតពីអំពើប្រល័យពូជសាសន៍មួយចំនួន ទាំងជនមូស្លីមនិងអ្នកមិនមែនមូស្លីម ក៏ត្រូវបានការពារនិងសង្គ្រោះដោយជនមូស្លីម ។ ជាងនេះទៅទៀត នៅពេលដែលមនុស្សជាច្រើនដែលបានចូលទៅជ្រកកោនក្នុងព្រះវិហារគ្រិស្តឬអគាររដ្ឋ ត្រូវបានសម្លាប់ក្រោមបញ្ជាឬមានការសហការពីមេដឹកនាំសាសនានិងមេដឹកនាំរដ្ឋ ប៉ុន្តែមិនមានអ្នកណាម្នាក់ត្រូវបានសម្លាប់ក្នុងវិហារអ៊ីស្លាម ដោយមានការឃុបឃិតពីមេដឹកនាំសាសនាអ៊ីស្លាមនោះទេ ។

ដោយមើលឃើញការស្អប់ខ្ពើមនិងការឃោសនាមុនអំពើប្រល័យពូជសាសន៍កាន់តែខ្លាំងឡើង មេដឹកនាំសហគមន៍បានធ្វើការប៉ាន់ប្រមាណអំពីសក្តានុពលនៃការកើនឡើងនៃអំពើហិង្សា ហើយបានចាត់វិធានការចាំបាច់ដើម្បីពន្យល់ប្រាប់ប្រជាជនមូស្លីមនិងទប់ទល់ជាមួយការផ្សព្វផ្សាយស្អប់ខ្ពើម ។ ជាច្រើនសប្តាហ៍មុនអំពើប្រល័យពូជសាសន៍ មេដឹកនាំសាសនាអ៊ីស្លាមបានចែកខិត្តប័ណ្ណនិងបិទប្រកាសព័ត៌មាននៅតាមវិហារអ៊ីស្លាម ស្នើសុំឲ្យប្រជាជនរក្សាភាពស្ងប់ស្ងាត់ និងចៀសវាងការចូលរួមក្នុងជម្លោះបែងចែកពូជសាសន៍ ដែលនេះជាការក្រើនរំឭកដល់សហគមន៍ថា «ការសម្លាប់ជាអំពើបាប» ។ មេដឹកនាំសាសនាអ៊ីស្លាមបានបង្ហាញជំហររបស់ខ្លួនជាសាធារណៈដោយបានចេញសេចក្តីប្រកាសតាមរយៈស្ថានីយវិទ្យុរបស់រដ្ឋាភិបាល ។ នៅពេលដែលស្ថានីយ៍វិទ្យុស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងតែង និងកំពុងត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ផ្សព្វផ្សាយឃោសនាអវិជ្ជមាន សាររបស់ជនមូស្លីមមួយចំនួននៅតែត្រូវបានផ្សព្វផ្សាយតាមរលកធាតុអាកាស ។

សហគមន៍អ៊ីស្លាមទាំងមូលក៏បានបញ្ចេញសកម្មភាពជួយ

សង្គ្រោះជីវិតមនុស្សដែរ ។ ជនមូស្លីមបានជួយលាក់បាំង ទាំងមូស្លីម និងអ្នកមិនមែនមូស្លីម ដោយបញ្ជូនមនុស្សពីផ្ទះមួយទៅផ្ទះមួយដើម្បីការពារពួកគេពីកងយោធា ហើយលាក់បាំងអ្នកទាំងនេះឲ្យនៅលើពិតាន ឬឲ្យស្ត្រីពាក់ក្រមារុំមុខដើម្បីក្លែងបន្លំខ្លួន ។ មូស្លីមហ៊ូទូបានបដិសេធមិនព្រមផ្តល់ព័ត៌មានអំពីកន្លែងលាក់ខ្លួនរបស់ទុតស៊ី ។ ជនមូស្លីមក៏បានឆ្លៀតឱកាសនេះទិញគ្រឿងបរិក្ខារ ដូចជាអាហារនិងថ្នាំពេទ្យយកមកផ្គត់ផ្គង់ដល់អ្នកដែលខ្លួនកំពុងការពារ ។ ជាងនេះទៅទៀត នៅពេលរបាំងរាំងផ្លូវត្រូវបានប្រើដោយកម្លាំងរដ្ឋាភិបាលក្នុងការតាមចាប់ជនជាតិទុតស៊ីដែលកំពុងរត់គេច ជនមូស្លីមមួយចំនួនបានប្រើរបាំងនេះដើម្បីការពារមិនឲ្យក្រុមហ៊ូទូចូលមកក្នុងសហគមន៍របស់ខ្លួន ។ ធ្វើដូចនេះអាចការពារជនជាតិទុតស៊ីបានប្រសើរជាង ។ អ្នកខ្លះទៀតធ្វើពុតជាចូលរួមក្នុងអំពើប្រល័យពូជសាសន៍ដើម្បីបន្លាក់ការសង្ស័យនិងធានាសុវត្ថិភាពដល់អ្នកដែលខ្លួនកំពុងការពារ ។ ឧទាហរណ៍អំពីសកម្មភាពនេះរួមមាន ការយកដើមឈើមកធ្វើជាសាកសពហើយរៀបចំពិធីកប់ក្លែងបន្លំមួយ និងការខិតខំប្រឹងប្រែងចូលទៅក្នុងជួរកងទ័ព ហើយស៊ើបយកការណ៍ពីក្រុមយោធាដើម្បីផ្តល់ដំណឹងដល់ជនជាតិទុតស៊ីអំពីពេលវេលានិងទីកន្លែងវាយប្រហារនាពេលអនាគត ។

មានបុគ្គលជាច្រើនបានប្រថុយប្រថាននឹងគ្រោះថ្នាក់ ។ អ្នកខ្លះបានប្រឆាំងនឹងបទបញ្ជារបស់ក្រុមយោធាឲ្យសម្លាប់ឬបោះបង់ចោលកន្លែងលាក់ខ្លួនជនជាតិទុតស៊ី ហើយជាលទ្ធផលអ្នកទាំងអស់នេះខ្លួនឯងត្រូវបានស្លាប់ ។ សមាជិកសហគមន៍មួយចំនួនបានរៀបចំឡើងជាចលនាប្រឆាំង ដើម្បីការពារសហគមន៍របស់ខ្លួន ។ នៅក្នុងតំបន់ម៉ាប៊ែរ (Mabare) ជនជាតិទុតស៊ីជាច្រើនបាននាំគ្នារត់ចូលវិហារអ៊ីស្លាមនៅពេលពួកគេដឹងថា មូស្លីមបានជួយសង្គ្រោះជីវិតទុតស៊ីនៅក្នុងតំបន់នេះ ។ នៅពេលកងយោធារដ្ឋាភិបាលមកដល់ មេដឹកនាំអ៊ីស្លាមមួយរូបត្រូវបានសម្លាប់ ព្រោះគាត់បានបដិសេធមិនព្រមប្រគល់ជនជាតិទុតស៊ីដែលមកជ្រកកោននៅទីនោះ ។ ពេលនោះជនមូស្លីមនិងជនភៀសខ្លួនបានចាប់ផ្តើមការតស៊ូប្រដាប់អាវុធ ដោយប្រើប្រាស់តែអាវុធបុរាណ ។ ការតស៊ូប្រឆាំងនេះបានបញ្ចប់ទៅរយៈពេល បីថ្ងៃ គឺនៅពេលកងកម្លាំងប៉ូលិសជំនួយចុះមកបង្ក្រាប ។ ក្នុងតំបន់បាហ្គាបា (Kbagaba) មូស្លីមហ៊ូទូនិងមូស្លីមទុតស៊ីបានប្រមូលផ្តុំគ្នានៅក្នុងវិហារអ៊ីស្លាមហើយបានប្រាប់ទៅកងកម្លាំងយោធាថា *"មិនមានហ៊ូទូ ឬទុតស៊ីទេ យើងទាំងអស់គ្នាជាមនុស្សលោក"* ។ ក្រុមនេះបានប្រឆាំងតទល់នឹងកងយោធាអស់រយៈពេលបីថ្ងៃ នៅពេលដែលជនជាតិទុតស៊ីកាន់តែច្រើនទៅៗបានមកជ្រកកោនក្នុងវិហារអ៊ីស្លាម ។ កងការពារលោកប្រធានាធិបតីបានមកដល់ ហើយបានទាមទារឲ្យជនជាតិហ៊ូទូបំបែកខ្លួនចេញពីទុតស៊ី ។ ខណៈពេលដែលមូស្លីមហ៊ូទូអាចការពារជីវិតរបស់ខ្លួនបាន អ្នកទាំងនេះបានបដិសេធ ហើយជាលទ្ធផលមនុស្សជាច្រើនត្រូវបានសម្លាប់ ។ សរុបសេចក្តីអំពីសកម្មភាពរបស់មូស្លីម លេខាប្រតិបត្តិនៃអង្គការសមាគមអ៊ីស្លាមរ៉្វាន់ដា លោក វ៉ាម៉ាទីនី រូហ្គេម៉ា បាននិយាយថា *"គ្មានអ្នកណាម្នាក់ស្លាប់នៅក្នុងវិហារអ៊ីស្លាមទេ ។ គ្មានជនមូស្លីមណាមួយចង់ឲ្យជនមូស្លីមដទៃទៀតស្លាប់ទេ ។ យើងបានក្រោកឈរឡើងប្រឆាំងនឹងកងយោធា ។ ហើយយើងបានជួយអ្នកមិនមែនមូស្លីមឲ្យគេចខ្លួនទៅកន្លែងផ្សេង"* ។

## ពិនិត្យមើលការប្រឆាំងតបតរបស់មូស្លីម

វាត្រូវបានដឹងឮយ៉ាងទូលំទូលាយថា ការស្ម័គ្រចិត្តរបស់ជនជាតិរ៉្វាន់ដាក្នុងការធ្វើតាមការបញ្ជាគឺជាកត្តាចម្បង ដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ ។ ការស្ម័គ្រចិត្តក្នុងការស្តាប់បង្គាប់ថ្នាក់ដឹកនាំ ក៏ត្រូវបានមើលឃើញថា បានដើរតួនាទីជាវិជ្ជមាននៅក្នុងសហគមន៍អ៊ីស្លាម ដោយមេដឹកនាំសហគមន៍បានព្យាយាមពន្យល់ប្រាប់ដល់សមាជិកឲ្យប្រឆាំងទៅនឹងការបែងចែកជនជាតិនិងអំពើហិង្សា ហើយបានក្រើនរំឭកអ្នកទាំងនេះអំពីកាតព្វកិច្ចនិងជំនឿរបស់ខ្លួនក្នុងនាមជាអ្នកកាន់សាសនាអ៊ីស្លាម ។ កត្តាទាំងអស់នេះបានធ្វើឲ្យមូស្លីមមិនចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ។ មូស្លីមមានជំនឿទៅលើការប្រៀនប្រដៅនិងមនោគមវិជ្ជារបស់មេដឹកនាំសាសនារបស់ខ្លួនព្រមទាំងគម្ពីរគួរអានជាងមេដឹកនាំនយោបាយក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ។ ដូច្នេះ អ្នកទាំងអស់នេះអាចទប់ទល់ប្រឆាំងនឹងឥទ្ធិពលជាច្រើនដែលបង្ខំឲ្យខ្លួនចូលរួម ។ ទាក់ទងនឹងបញ្ហានេះ មានការប៉ាន់ប្រមាណថា ប្រសិនបើមេដឹកនាំសាសនាអ៊ីស្លាមបណ្តោយឲ្យមានអំពើ

ហិង្សានោះ ប្រាកដជាមានជនមូស្លីមជាច្រើននឹងចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ។ ដូចគ្នាផងដែរ វានឹងមានអំពើហិង្សាតិចតួច ប្រសិនបើមេដឹកនាំសាសនាគ្រិស្តច្រើនជាងនេះឈរលើជំហរប្រឆាំងនឹងការកាប់សម្លាប់ ។

ការជឿជាក់យ៉ាងជ្រាលជ្រៅទៅលើជំនឿសាសនាអ៊ីស្លាម ក៏បានដើរតួនាទីក្នុងការធ្វើឲ្យមានការតបតជាវិជ្ជមានក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាម ។ ទាំងមេដឹកនាំសាសនានិងសមាជិកក្នុងសហគមន៍ទូទៅ ដែលត្រូវបានសម្ភាសនៅក្នុងការសិក្សាលើប្រធានបទនេះបានអះអាងថា គម្ពីរគួរអានគឺជាសេចក្តីពន្យល់ជាបឋមសម្រាប់សកម្មភាពអហិង្សារបស់ពួកគេ ។ អ្នកទាំងនេះបានលើកឡើងអំពីការប្រៀនប្រដៅនៅក្នុងគម្ពីរគួរអាន អំពីការការពារជនទន់ខ្សោយនិងជំនឿដែលថា ការសម្លាប់មនុស្សម្នាក់នឹងអាចនាំដល់ការសម្លាប់មនុស្សជាតិទាំងមូល ។ គម្ពីរគួរអានក៏បានបង្រៀនផងដែរថា មនុស្សមិនត្រូវមើលឃើញឬសម្គាល់ភិនភាគតាមរយៈសញ្ញាឃីហោទេ ប៉ុន្តែផ្ទុយទៅវិញ ត្រូវចាត់ទុកថាមានឋានៈស្មើៗគ្នា ។ ទស្សនៈនេះប្រហែលជាជួយឲ្យមូស្លីមរ៉្វាន់ដាមើលឃើញបានច្រើនជាងការបែងចែករវាងក្រុមជាតិសាសន៍ «ហ៊ូទូ» និង«ទុតស៊ី»ទៅទៀត ។ យ៉ែត សារ៉ាប៊ូយ៉េ គ្រិស្តសាសនិកមួយរូបដែលត្រូវបានលាក់បំពួនដោយក្រុមមូស្លីមនៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ពណ៌នាអំពីសារសំខាន់នៃគម្ពីរគួរអាន ដែលមានឥទ្ធិពលទៅលើអាកប្បកិរិយារបស់ជនមូស្លីម ហើយថា «ប្រសិនបើមូស្លីមហ៊ូទូម្នាក់ព្យាយាមសម្លាប់មនុស្សម្នាក់ដែលកំពុងលាក់ខ្លួននៅក្នុងភូមិរបស់យើងជាដំបូង ជនម្នាក់នេះនឹងត្រូវបានប្រាប់ឲ្យយកគម្ពីរគួរអានដ៏ពិសិដ្ឋមកហែកចោលដើម្បីបង្ហាញពីការចាកចេញពីសាសនារបស់ខ្លួនជាមុនសិន ។មិនមានជនមូស្លីមណាម្នាក់ហ៊ានល្មើសនឹងសៀវភៅដ៏ពិសិដ្ឋនេះទេ ហើយប្រការនេះបានជួយសង្គ្រោះជីវិតយើងជាច្រើន» ។

ចំណុចផ្សេងៗទៀតនៃជំនឿសាសនាអ៊ីស្លាម ប្រហែលជាបានធ្វើឲ្យប្រសើរឡើងថែមទៀតនូវអារម្មណ៍ជឿជាក់លើសាសនានិងការរស់នៅជាសហគមន៍ក្នុងចំណោមជនមូស្លីម ដែលធ្វើឲ្យអ្នកទាំងនេះមានការពិបាកយ៉ាងខ្លាំងក្នុងការបែរមកប្រឈមមុខដាក់គ្នា នៅពេលការសម្លាប់បានចាប់ផ្តើម ។ ការចែករំលែកសុខទុក្ខគ្នាគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងលទ្ធិសាសនាអ៊ីស្លាម ហើយការអនុវត្តក្នុងសាសនាជាច្រើនបានពង្រឹងគោលការណ៍នេះ ។ មូស្លីមដែលប្រកាន់ជំនឿសាសនាយ៉ាងខ្ជាប់ខ្ជួនបានថ្វាយបង្គំជាមួយគ្នារហូតដល់ប្រាំដងក្នុងមួយថ្ងៃ ។ ជាងនេះទៅទៀត អំពើប្រល័យពូជសាសន៍បានចាប់ផ្តើមក្រោយថ្ងៃកាន់បួសរបស់មូស្លីមបន្តិច ដែលនេះគឺជាពេលដែលជនមូស្លីមទាំងអស់ជម្រះឲ្យអស់នូវអំពើបាបទាំងឡាយនិងស្វែងយល់ពីកំហុសរបស់ខ្លួន ហើយគំនិតល្អពិសិដ្ឋនៃសាសនាអ៊ីស្លាមនិងចរិតលក្ខណៈខ្ពស់នៃសាមគ្គីភាពក្នុងសង្គមប្រហែលជាមានឥទ្ធិពលខ្លាំងនៅក្នុងគំនិតរបស់មូស្លីមទាំងនោះនៅពេលអំពើប្រល័យពូជសាសន៍បានកើតឡើង ។ ជាចុងក្រោយ ដោយសារតែការក្លាយខ្លួនជាមូស្លីមមានការលំបាកនៅក្នុងសង្គមជាតិរ៉្វាន់ដា មនុស្សភាគច្រើនដែលគោរពបូជាជំនឿសាសនាអ៊ីស្លាមមានការលះបង់ខ្ពស់និងស្មោះត្រង់ ។ ទោះជាយ៉ាងនេះក្តី ការប្រៀនប្រដៅរបស់សាសនាអ៊ីស្លាមមិនគួរត្រូវបានចាត់ទុកថាជាកត្តាសំខាន់ក្នុងការជំរុញឲ្យមានការតស៊ូប្រឆាំងរបស់មូស្លីមនោះទេ ។ ជំនឿសាសនាគ្រិស្តក៏មានការបង្ហាត់បង្រៀនប្រហាក់ប្រហែលគ្នាដែរ ។

ការបន្ទាបតម្លៃនិងការដាក់សហគមន៍អ៊ីស្លាមឲ្យនៅដាច់ពីសង្គមរ៉្វាន់ដា ក៏ជាកត្តាជំរុញឲ្យមានសកម្មភាពវិជ្ជមានផងដែរ ។ មូស្លីមត្រូវបានដកចេញពីតួនាទីនយោបាយក្នុងរដ្ឋាភិបាលរ៉្វាន់ដា ដែលមានទំនាក់ទំនងច្រើនជាមួយព្រះវិហារគ្រិស្ត ។ ថ្នាក់ដឹកនាំសហគមន៍អ៊ីស្លាមបានឈរនៅខាងគណបក្សទាមទារឯករាជ្យរបស់ទុតស៊ី មុនទទួលបានឯករាជ្យ ហើយជាលទ្ធផលត្រូវគណបក្សរបស់ក្រុមហ៊ូទូដែលចុងក្រោយបានឡើងកាន់អំណាចទុកឲ្យនៅក្រៅឆាកនយោបាយ ។ ហេតុដូច្នេះ រដ្ឋាភិបាលរ៉្វាន់ដាមានឥទ្ធិពលឬការគ្រប់គ្រងតិចតួចទៅលើអាជ្ញាធរមូស្លីមឬមនោគមវិជ្ជារបស់សាសនាអ៊ីស្លាម ។ ការណ៍នេះបានអនុញ្ញាតឲ្យមេដឹកនាំសាសនាអ៊ីស្លាមអាចរស់នៅដាច់ដោយឡែកពីគោលការណ៍រដ្ឋនិងអាចបញ្ជូនសារដោយផ្ទាល់ទៅឲ្យសាសនិករបស់ខ្លួន ។

សហគមន៍អ៊ីស្លាមក៏ត្រូវបានបដិសេធពីសង្គមរ៉្វាន់ដាផងដែរ ។ នេះក៏អាចជាហេតុផលមួយដែលមូស្លីមត្រូវបានបង្ខំឲ្យទៅរស់

នៅក្នុងតំបន់កំហិតទទួលរងនូវការរើសអើងនិងមិនឲ្យទទួលបានការអប់រំ ហើយឱកាសទទួលបានការងារនិងតួនាទីនៅក្នុងរដ្ឋាភិបាលមានកំណត់ ។ ជាងនេះទៅទៀត សាលារៀននៅរ៉ាន់ដាគឺជាកន្លែងដែលបង្រៀនអំពីការបែងចែកពូជសាសន៍និងបណ្ដុះគំនិតជ្រុលនិយមដល់ក្រុមហ៊ូទូ ។ ដោយមិនបានចូលសិក្សានៅតាមសាលាទាំងនេះ ក្មេងៗមូស្លីមបានគេចផុតពីការឃោសនាអវិជ្ជមានដ៏សម្បើមនេះ ។

ការដាក់ឲ្យនៅឆ្ងាយពីសង្គមបានធ្វើឲ្យសាមគ្គីភាពក្នុងសហគមន៍កាន់តែរឹងមាំនិងធ្វើឲ្យជនមូស្លីមមើលឃើញកាន់តែជ្រៅទៅក្នុងសហគមន៍របស់ខ្លួន ដែលអនុញ្ញាតឲ្យពួកគេផ្ដាច់ខ្លួនចេញពីមនោគមវិជ្ជាទាំងឡាយណាដែលនាំដល់អំពើហិង្សា ។ បញ្ហាពូជសាសន៍មិនសូវមានសារសំខាន់ទេសម្រាប់មូស្លីម ហើយអ្នកទាំងនេះមួយចំនួនថែមទាំងមើលឃើញខ្លួនឯងជាសមាជិកនៃក្រុមជាតិសាសន៍ទីបួនជាជាងចាត់ទុកខ្លួនឯងថាជាហ៊ូទូ ទុតស៊ី ឬជាតិសាសន៍ត្វា ។ ដោយសារមូស្លីមរស់នៅជិតគ្នា វាមានការងាយស្រួលក្នុងការផ្លាស់ប្ដូរយោបល់គ្នានិងគាំទ្រដល់អំពើអហិង្សានិងការតស៊ូ ។ កត្តានេះក៏បានជួយដល់មូស្លីមធ្វើការការពារសហគមន៍របស់ខ្លួនក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ និងប្រជាជនអាចរត់ទៅលាក់ខ្លួនពីផ្ទះមួយទៅផ្ទះមួយទៀតក្នុងអំឡុងពេលនៃការតាមសម្លាប់ ។ ជាចុងក្រោយ នៅពេលសង្គមជាតិប្រព្រឹត្តមកលើប្រជាជនមិនស្មើភាពគ្នា មូស្លីមអាចរស់នៅជាមួយទុតស៊ីបាន ។ ដូច្នេះពូជសាសន៍មិនត្រូវបានមើលឃើញថា មានសារសំខាន់ដែលបានធ្វើឲ្យសហគមន៍មិនចូលរួមក្នុងអំពើឧក្រិដ្ឋហើយបែរមកការពារជាជាងប្រព្រឹត្តអំពើហិង្សាទេ ។

ទោះជាការតស៊ូប្រឆាំងមានលក្ខណៈទូទៅក្នុងចំណោមមូស្លីមរ៉ាន់ដាក៏ដោយ ក៏មូស្លីមមួយចំនួនបានចូលរួមយ៉ាងសកម្មក្នុងអំពើប្រល័យពូជសាសន៍ ។ ជនមូស្លីមដែលមានមុខមាត់ក្នុងសង្គមបីនាក់បានចូលរួមយ៉ាងសកម្មក្នុងអំពើប្រល័យពូជសាសន៍ ។ ពីរនាក់គឺជាសមាជិករដ្ឋាភិបាល ហើយម្នាក់ទៀតគឺជាមេដឹកនាំផ្នែកឯកជន (ព្រឹត្តិប័ត្រកាន់ហ្គូរ៉ា ដែលជាកាសែតគាំទ្រយ៉ាងខ្លាំងក្លាដល់មេដឹកនាំកាន់អំណាចហ៊ូទូ) ។ ប៉ុន្តែជនមូស្លីមជាច្រើនបានអះអាងថា ជនដែលទាំងនេះមិនបានធ្វើក្នុងនាមជាសហគមន៍អ៊ីស្លាមទេ ហើយក៏មិនបានចូលរួមអ៊ីនៅក្នុងសហគមន៍អ៊ីស្លាមដែរ ។ ប្រជាជនមូស្លីមមួយចំនួនបានផ្ដល់ព័ត៌មានឬចូលរួមជាមួយកងឃោឃៅ ប៉ុន្តែមានមូស្លីមតិចតួចណាស់ដែលបានសម្លាប់មូស្លីមផ្សេងទៀត ។ របាយការណ៍មួយ បានរៀបរាប់ថា កងឃោឃៅមូស្លីមម្នាក់បានប្រាប់ជនជាតិទុតស៊ី មិនមែនមូស្លីមថា ប្រសិនបើគាត់ចូលសាសន៍នោះ គាត់នឹងមិនត្រូវបានសម្លាប់ទេ ។ ទុតស៊ីរូបនេះបានធ្វើតាមហើយបានរួចរស់ជីវិត ។

## ស្ថានភាពក្រោយរបបប្រល័យពូជសាសន៍ និងប្រទេសរ៉ាន់ដានាពេលបច្ចុប្បន្ន

បន្ទាប់ពីអំពើប្រល័យពូជសាសន៍ ប្រជាជនរ៉ាន់ដាជាច្រើនមិនបានវិលត្រឡប់ទៅព្រះវិហារគ្រិស្ដដែលមិនបានការពារពួកគេ ហើយមេដឹកនាំព្រះវិហារមួយចំនួនបានប្រឆាំងយ៉ាងខ្លាំងក្លាទៅនឹងការប្រៀនប្រដៅរបស់សាសនាគ្រិស្ដ ។ យ៉ាកូបូ ជូមូ ហ្សេយីម៉ាណា (Yakobo Djumu Nzeyimana) បានរៀបរាប់ថា “ប្រជាជនស្លាប់នៅក្នុងព្រះវិហារចាស់របស់ខ្ញុំ ហើយលោកអាចារ្យបានជួយពួកឃាតករ ។ ខ្ញុំមិនអាចត្រឡប់ទៅវិញហើយថ្វាយបង្គំនៅទីនោះទេ ។ ខ្ញុំត្រូវតែរកកន្លែងផ្សេងទៀត” ។ មនុស្សជាច្រើនបានបែរមកគោរពសាសនាអ៊ីស្លាម ដែលបានក្លាយទៅជាសាសនាមួយដែលមានអ្នកគោរពបូជាកើនឡើងលឿនជាងគេក្នុងប្រទេសរ៉ាន់ដា ។ មានការប៉ាន់ស្មានមួយថា មូស្លីមមានចំនួន១៥ភាគរយក្នុងចំណោមប្រជាជនសរុប៨,២លាននាក់ ដែលបង្ហាញពីការកើនឡើងទ្វេដងនៃចំនួនកាលពីដប់ឆ្នាំមុន ។

មេដឹកនាំសាសនាអ៊ីស្លាមជឿជាក់ថា ការកើនឡើងនេះគឺមានជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពការពារនិងជួយសង្គ្រោះជីវិតមនុស្សក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ។ ជនជាតិទុតស៊ីកាន់សាសនាគ្រិស្ដបានរៀនច្រើនអំពីលទ្ធិសាសនាអ៊ីស្លាមក្នុងកំឡុងពេលលាក់ខ្លួននៅតាមផ្ទះរបស់ជនមូស្លីម ហើយភាគច្រើននៃអ្នកទាំងនោះបានចូលសាសន៍ដើម្បីជាការតបស្នងនិងជាការគោរពដល់អ្នកដែលបានជួយសង្គ្រោះជីវិតរបស់ខ្លួន ។ យ៉ាស់យ៉ា កាយីរ៉ាន់ហ្គា ទុតស៊ីមិនមែនមូស្លីមម្នាក់ដែលទទួលបានការជ្រកកោននិងការការពារពីសំណាក់ប្រជាជនមូស្លីមក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍បានរៀបរាប់ពីការសម្រេចចិត្តក្នុងការចូលសាសន៍របស់គាត់ថា “ក្នុងលទ្ធិសាសនាអ៊ីស្លាមហ៊ូទូនិង

ទុតស៊ីគឺតែមួយ ។ សាសនាអ៊ីស្លាមបានបង្រៀនយើងពីភាពជាបងប្អូន» ។ ជនជាតិទុតស៊ីផ្សេងទៀតបានចូលសាសនាអ៊ីស្លាមក្នុងឆ្នាំក្រោយៗបន្តមកទៀត បន្ទាប់ពីអំពើប្រល័យពូជសាសន៍ដើម្បីការពារខ្លួនពីក្រុមជ្រុលនិយមហ៊ូទូ ដែលបានបន្តវាយប្រហារមកលើប្រទេសរ៉្វាន់ដាពីជំរំជនភៀសខ្លួនក្នុងប្រទេសហ្សាអៀរ ។ ហ៊ូទូមួយចំនួនក៏បានចូលសាសនាអ៊ីស្លាមជាមធ្យោបាយដើម្បីលាងបាបនិងព្យាបាលរបួសផ្លូវចិត្ត ។ សម្រាប់អ្នកទាំងអស់នេះ ការចូលសាសន៍គឺជាមធ្យោបាយក្នុងការលុបបំបាត់ស្លាកស្នាមបាតដៃប្រឡាក់ឈាមនិងការការពារពីការសងសឹក ។

ការចូលសាសន៍មិនមែនជាការងាយស្រួលសម្រាប់ប្រជាជនរ៉្វាន់ដាទេ ដោយប្រជាជនទាំងនេះត្រូវតម្រូវឲ្យទទួលយកនូវការហាមប្រាមថ្មី ដូចជារបៀបរស់នៅ ការស្លៀកពាក់ និងទំនៀមទម្លាប់ប្រពៃណី ។ ជាងនេះទៅទៀត ជាប្រវត្តិសាស្ត្រមកហើយ ជនមូស្លីមត្រូវបានដាក់ឲ្យនៅឆ្ងាយពីសង្គម និងមិនត្រូវបានចាត់ទុកថាជាប្រជាជនរ៉្វាន់ដាទេ ។ ទោះជាយ៉ាងនេះក្ដី គោលគំនិតនេះបានផ្លាស់ប្ដូរនៅពេលសាសនាអ៊ីស្លាមមានការរីកចម្រើនច្រើននៅក្នុងប្រទេស ។ ការតស៊ូរបស់មូស្លីមក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ក៏បានរួមចំណែកប្រឆាំងទៅនឹងការដាក់ឲ្យនៅក្រៅសង្គមផងដែរ ។ មូស្លីមត្រូវបានមើលឃើញកាន់តែច្រើនឡើងថាជាប្រជាជនរ៉្វាន់ដា និងបានដើរតួនាទីយ៉ាងសកម្មនៅក្នុងសង្គមជាទូទៅ ។

ការរីករាលដាលនៃក្រុមអ៊ីស្លាមជ្រុលនិយមពីអាហ្វ្រិកខាងជើងទៅតំបន់វាលខ្សាច់សាហារ៉ា ក្នុងទ្វីបអាហ្វ្រិកបានធ្វើឲ្យសហគមន៍អន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះថាអ៊ីស្លាមជាញឹកញយមានជាប់ពាក់ព័ន្ធទៅនឹងជនប្រដាប់អាវុធនិងក្រុមជ្រុលនិយម ។ ទោះជាយ៉ាងនេះក្ដី សហគមន៍អ៊ីស្លាមនៅរ៉្វាន់ដាសម្លឹងមើលទៅក្នុងសហគមន៍របស់ខ្លួន ហើយធ្វើការកសាងសហគមន៍តាមមធ្យោបាយផ្គត់ផ្គង់ខ្លួនឲ្យបានគ្រប់គ្រាន់ ។ ក្នុងពេលមួយបន្ទាប់ពីអំពើប្រល័យពូជសាសន៍ ក្រុមអ៊ីស្លាមជ្រុលនិយមមួយក្រុមដែលទទួលជំនួយហិរញ្ញវត្ថុពីប្រទេសប៉ាគីស្ថាន បានកាន់កាប់ព្រះវិហារអ៊ីស្លាមមួយ ប៉ុន្តែត្រូវបានបណ្ដេញចេញទៅវិញដោយសមាគមអ៊ីស្លាមនៅរ៉្វាន់ដា ក្នុងគោលបំណងដើម្បីបង្ក្រាបការរីករាលដាលក្រុមជ្រុលនិយមអ៊ីស្លាម ។ និច អ៊ី មីយ៉ាណា អ៊ីមាំនៅក្នុងតំបន់រ៉ូហេនហ្គីរី បានថ្លែងថា «*យើងមានបញ្ហាគ្រប់គ្រាន់ហើយ ។ យើងមិនចង់ឲ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកមកលើយើងទេ ។ ផ្ទុយទៅវិញ យើងចង់ឲ្យអង្គការក្រៅរដ្ឋាភិបាលរបស់អាមេរិកជួយកសាងមន្ទីរពេទ្យឲ្យយើង*» ។

ជាងនេះទៅទៀត នៅពេលភាពតានតឹងរវាងក្រុមជាតិសាសន៍ ការខឹងសម្បានិងការភ័យខ្លាច នៅមានកម្រិតខ្ពស់នៅឡើយនៅក្នុងប្រទេសរ៉្វាន់ដា ជនមូស្លីមនៅរ៉្វាន់ដាបានមើលឃើញថាខ្លួនមានកាតព្វកិច្ចដឹកនាំឲ្យមានការផ្សះផ្សាជាតិនៅក្នុងប្រទេស ។ សហគមន៍អ៊ីស្លាមបានផ្សព្វផ្សាយសារអំពីសាមគ្គីភាព និងការអត់ឱនឲ្យគ្នាទៅដល់អ្នកដែលបានចូលសាសន៍ ហើយសង្ឃឹមថាខ្លួននឹងដើរតួនាទីក្នុងការបង្ហាត់បង្រៀនអំពីសារនេះដល់ប្រជាជនផ្សេងៗទៀត ។ សាឡេះ ហាប៊ីម៉ាណា មេដឹកនាំសាសនាអ៊ីស្លាមធំជាងគេនៅរ៉្វាន់ដា បានធ្វើជាសហប្រធានគណៈកម្មការអន្តរសាសនាសម្រាប់ការរួបរួមនៅរ៉្វាន់ដា ។ គណៈកម្មការនេះមាននាទីបញ្ចប់ការស្អប់ខ្ពើមជាតិសាសន៍ និងជំរុញឲ្យមានសេរីភាពក្នុងការពិភាក្សានិងបញ្ចេញយោបល់ ។ វិហារអ៊ីស្លាមនៅរ៉្វាន់ដាគឺជាកន្លែងដ៏កម្រមួយ ដែលធ្វើឲ្យការផ្សះផ្សាទទួលបានជោគជ័យយ៉ាងល្អប្រសើរ ។ វិហារអ៊ីស្លាមនិងសាលាបង្រៀនផ្នែកសាសនាអ៊ីស្លាមម៉ាដ្រាសាស ជាញឹកញយត្រូវបានប្រើជាកន្លែងសម្រាប់ការជួបជុំគ្នារវាងហ៊ូទូនិងទុតស៊ីដើម្បីធ្វើការផ្សះផ្សា ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំសាសនាអ៊ីស្លាមបានបង្ហាញពីឆន្ទៈក្នុងការពិភាក្សានិងសហការជាមួយថ្នាក់ដឹកនាំសាសនាគ្រិស្ត ។

មូស្លីមនៅរ៉្វាន់ដាបានពណ៌នាពីការខិតខំប្រឹងប្រែងនេះថាជា «ជ្ជីហាដ» ឬជាការតស៊ូដ៏ពិសិដ្ឋមួយ ។ ទោះបីជាពាក្យនេះមានអត្ថន័យអវិជ្ជមាននៅក្នុងសង្គមនាពេលបច្ចុប្បន្ន (ដែលបានសំដៅទៅលើក្រុមវាយប្រហារនិងក្រុមដាក់គ្រាប់បែកអត្តឃាតក៏ដោយ) ក៏មូស្លីមនៅរ៉្វាន់ដាប្រើប្រាស់ពាក្យនេះ ដើម្បីពណ៌នាពីវិធីព្យាបាលរបួសនៅក្នុងប្រទេស ។ ហាប៊ីម៉ាណា និយាយថា «*យើងមានជ្ជីហាដ ហើយនេះគឺជាសង្គ្រាមតស៊ូរបស់យើងប្រឆាំងនឹងគ្រោះអវិជ្ជារវាងក្រុមហ៊ូទូនិងក្រុមទុតស៊ី ។ វាជាការតស៊ូដើម្បីព្យាបាល*

របួស ។ ការតស៊ូរបស់យើងគឺចាប់ផ្តើមពីការគោរពគ្នាទៅវិញទៅមក និងរស់នៅក្នុងនាមជាប្រជាជនវៀតណាមនិងជាអ្នកកាន់សាសនាអ៊ីស្លាម» ។ វត្តមានរបស់សាសនាអ៊ីស្លាមបានបង្ហាញឲ្យប្រជាជនក្នុងតំបន់មើលឃើញថា ហ្វ៊ូទូនិងទុតស៊ីអាចរស់នៅជាមួយគ្នានៅក្រោមអត្តសញ្ញាណតែមួយ ។ នៅក្នុងស្ថានការណ៍នេះការចូលសាសន៍បានដើរតួនាទីក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរព្រំដែនសង្គមដែលអាចធ្វើឲ្យភាពខុសគ្នារវាងជាតិសាសន៍មានការធូរស្រាលនិងមិនសូវមានការបែងចែក ។ កត្តាជាតិសាសន៍មានទំនាក់ទំនងតិចតួចទៅនឹងអត្តសញ្ញាណ ដូច្នេះវាអាចកាត់បន្ថយនូវជម្លោះ ។

**សេចក្តីសន្និដ្ឋាន**

ជនជាតិទុតស៊ីនិងជនជាតិហ្វ៊ូទូនិយមកណ្តាលរាប់រយពាន់នាក់ត្រូវបានសម្លាប់នៅក្នុងអំពើប្រល័យពូជសាសន៍មួយដែលចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជននៅក្នុងប្រទេស ។ ទោះជាយ៉ាងនេះក្តី សហគមន៍អ៊ីស្លាមបានផ្តល់នូវគំរូឧទាហរណ៍យ៉ាងសំខាន់អំពីសហគមន៍មួយដែលមានលទ្ធភាពតស៊ូនឹងភាពស្អប់ខ្ពើមនិងអំពើហិង្សា ហើយក្រោយមកបានផ្តល់នូវទម្រង់សម្រាប់សន្តិភាពនិងការផ្សះផ្សាជាតិ ។ ក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៩៤ សហគមន៍អ៊ីស្លាមបានបញ្ចេញសកម្មភាពខុសពីសហគមន៍ផ្សេងៗទៀតនៅក្នុងប្រទេស ដោយបានបដិសេធការចូលរួមក្នុងអំពើហិង្សា និងបានជួយសង្គ្រោះជីវិតជនមូស្លីមនិងអ្នកមិនមែនមូស្លីមដែលគ្មានកំហុស ។ ក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍នេះដែរ សហគមន៍សាសនាគ្រិស្តបានសម្តែងខ្លួនជាឧបករណ៍នៃអំពើហិង្សានិងការសមគំនិតនៅពេលសហគមន៍អ៊ីស្លាមតំណាងឲ្យការការពារនិងសុវត្ថិភាព ។ ការតស៊ូប្រឆាំងនេះក៏អាចបណ្តាលមកពីកត្តាមួយចំនួនដូចជារបៀបរស់នៅដែលសង្កត់ធ្ងន់ទៅលើសាមគ្គីភាពនៅជុំវិញលទ្ធិសាសនាមួយមិនមែនជាតិសាសន៍, គោលការណ៍សាសនាអ៊ីស្លាមដូចជាអហិង្សានិងការមិនរើសអើង និងការដាក់ឲ្យនៅក្រៅតួនាទីសង្គមនិងនយោបាយជាយូរមក ។ អស់ជាច្រើនឆ្នាំមកហើយមូស្លីមមិនត្រឹមតែត្រូវបានដាក់ដោយឡែកក្នុងនាមជាក្រុមសាសនាមួយដែលបានចាត់ទុកអត្តសញ្ញាណរបស់ខ្លួនជាមូស្លីមជាជាងហ៊្វូទូឬទុតស៊ី ។ ក្នុងនាមជាជនជាតិភាគតិចដែលត្រូវបានដាក់ដោយឡែក ទំនាក់ទំនងទៅនឹងសហគមន៍របស់ខ្លួនមានលក្ខណៈរឹងមាំ ហើយអ្នកទាំងនេះមានលទ្ធភាពផ្តាច់ខ្លួនចេញពីគំនិតបែងចែកពូជសាសន៍ និងធ្វើការយ៉ាងសកម្មដើម្បីជួយសង្គ្រោះអ្នកដទៃ ។

ដោយសារការខិតខំប្រឹងប្រែងរបស់មូស្លីមក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ សាសនាអ៊ីស្លាមត្រូវបានមើលឃើញថាជាប្រភពដ៏សំខាន់សម្រាប់ការផ្សះផ្សានៅរ៉្វាន់ដា ដែលបានធ្វើការព្យាបាលរបួសនៅក្នុងប្រទេសនិងប្រជាជន ។ ជាងនេះទៅទៀតដោយសារហ៊្វូទូនិងទុតស៊ីកាន់តែច្រើនឡើងបានចូលសាសន៍អ៊ីស្លាមបានធ្វើឲ្យប្រជាជនមានលទ្ធភាពផ្លាស់ប្តូរព្រំដែន សង្គមនិងជាតិសាសន៍របស់ខ្លួនបាន ។ នៅក្នុងការពិនិត្យមើលទៅលើប្រទេសរ៉្វាន់ដា វាបានបង្ហាញច្បាស់អំពីសារសំខាន់របស់សាសនាដែលអាចត្រូវបានប្រើជាកម្លាំងចលករសម្រាប់បង្កឲ្យមានជម្លោះនិងអំពើហិង្សា ឬសម្រាប់សន្តិភាពនិងការដោះស្រាយជម្លោះ ។ នៅពេលដែលមូស្លីមនៅរ៉្វាន់ដាត្រូវបានចាត់ទុកកាន់តែច្រើនឡើងដោយប្រជាជនផ្សេងៗទៀតថាជាប្រជាជនរ៉្វាន់ដា (ជាជាងសហគមន៍ដាច់ដោយឡែកនិងខុសពីគេ) សហគមន៍អ៊ីស្លាមបានបែរទៅរកកិច្ចខិតខំប្រឹងប្រែងដើម្បីចៀសវាងគំនិតជ្រុលនិយមនិងបុរាណនិយម ហើយជួយប្រទេសរ៉្វាន់ដាដើម្បីព្យាបាលនិងអភិវឌ្ឍ ។

**លីហ្សាប៊ែត ម៉ៃយើរ**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ភាសា និង អក្សរសាស្ត្រចាម

*ចាប់តាំងពីសតវត្សរ៍ទី៤រហូតដល់សតវត្សរ៍ទី១៣ ថ្នាក់ដឹកនាំចាមមានឥទ្ធិពលក្នុងភាសាចាមនិងសំស្ក្រឹត ។ ភាសាចាមមានឫសគល់ចេញមកពីអម្បូរភាសាម៉ាឡាយូប៉ូលីនេស៊ី ។ នៅក្នុងសតវត្សរ៍ទី១៣មានពាក្យជាច្រើនក្នុងភាសាចាមត្រូវបានកម្ចីមកពីភាសាសំស្ក្រឹត ភាសាខ្មែរ ភាសាម៉ាឡេស៊ី និងភាសាអារ៉ាប់ ។*

*កាលពីមុន ការសរសេរជាភាសាចាមមានពីរទម្រង់គឺការសរសេរជាសំស្ក្រឹតនិងការសរសេរជាភាសាចាមបែបបុរាណ ហើយត្រូវបានកំណត់សរសេរនៅក្រោមបន្ទាត់ ។ ការកំណត់សរសេរលើផ្ទាំងថ្មលើកទី១ជាភាសាចាមនៅសតវត្សរ៍ទី៤ និងការរកឃើញសិលាចារឹកចុងក្រោយគឺសរសេរជាសំស្ក្រឹតនៅឆ្នាំ១២៥៣នៃគ្រិស្តសករាជ ។ ក្រោយសតវត្សរ៍ទី១៤ អក្សរចារឹកនោះត្រូវបានផ្លាស់ប្តូរជាសៀវភៅសរសេរដោយដៃវិញ ។*

*រហូតមកដល់សតវត្សរ៍ទី១៥ សំណេរនោះមានបួនទម្រង់ថ្មីៗដែលត្រូវបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ ហើយត្រូវបានប្តូរមកសរសេរជាភាសាចាមវិញ ។ បន្ទាប់ពីសតវត្សរ៍ទី១៦ មានក្រុមមួយដែលហៅថា "ចាមបានី" ធ្លាប់ប្រើអក្សរអារ៉ាប់ដែលចម្លងចេញពីគម្ពីរគួរអាន ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគយ៉ាងដិតដល់ទៅលើការប្រើប្រាស់បានបង្ហាញឲ្យឃើញថាជាការពិត ពួកគេមិនស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាអារ៉ាប់ អក្សរសរសេរ និងអក្ខរក្រមឡើយ ។*

*អក្សរសាស្ត្រចម្ប៉ាត្រូវបានបែងចែកជាពីរ គឺអក្សរសាស្ត្របែបបុរាណនិងអក្សរសាស្ត្របែបទំនើប ។ អក្សរសាស្ត្រចាមបែបបុរាណគឺជាឯកសារអក្សរសាស្ត្រដែលត្រូវបានរកឃើញនៅក្នុងចំណារលើផ្ទាំងថ្មមួយ ជាពិសេសសិលាចារឹកនោះបាននិយាយអំពីសាសនានិងប្រវត្តិសាស្ត្រ ។ ចំណែកអក្សរសាស្ត្រចាមបែបសម័យត្រូវបានរកឃើញនៅលើជព្ចូកស្លឹកឈើ (Luntar leaf) ឬសរសេរ នៅលើក្រដាសដែលធ្វើដោយដៃ ដោយការប្រើប្រាស់ទឹកខ្មៅដែលធ្វើអំពីម្រែងភ្លើង លម្អងផ្សែង ឬផ្ទៃឈើដុតឲ្យខ្មៅ ។*

*អក្សរសាស្ត្រចាមអាចត្រូវបានបែងចែកបន្ថែមទៀតនូវអ្វីដែលទាក់ទិនទៅនឹងសាសនាមន្តអាគម ។ អក្សរសាស្ត្រសាសនាគឺជាទម្រង់ដ៏សំខាន់បកស្រាយអំពីដើមកំណើតនៃជំនឿដែលទាក់ទងទៅនឹងទេវកថាក្នុងស្រុកនិងទស្សនៈរបស់អ៊ិស្លាម (ដូចជាការពន្យល់បកស្រាយអំពីដើមកំណើតរបស់ភពផែនដី) ការបួងសួងនិងជំនឿឆ្វេងដែលលាយឡំទៅនឹងមន្តអាគមដូចជាក្នុងគោលបំណងលែងព្រលឹងជាដើម ។*

*អក្សរសាស្ត្រនោះក៏បានពន្យល់បកស្រាយផងដែរនូវពិធីបុណ្យនៃព្រឹត្តិការណ៍សំខាន់ៗជាច្រើន ។ គម្ពីរគួរអានត្រូវបានសរសេរជាភាសាអារ៉ាប់ ឬកំណត់ជាលាយលក្ខណ៍អក្សរខាងសួរស័ព្ទជាភាសាចាម ។ អក្សរសាស្ត្រដែលមិនទាក់ទងទៅនឹងសាសនានោះ មានការសរសេរនិទានរឿង រឿងព្រេង វេវចនសព្ទ អធិប្បាយជារូបាធិដ្ឋាន កំណាព្យ និងវីរកថា ។ ឧទាហរណ៍ នៃវីរកថារឿង "ប្រាំទឹត ប្រាំឡាក់" ដែលជារឿងសង្ខេបរបស់រាមាយណៈ អាកាយិត អ៊ីនរ៉ា ប៉ាត្រា គឺស្រដៀងទៅនឹងរឿងព្រេងអ៊ីនដារ៉ា ភូតារ៉ារបស់ម៉ាឡេស៊ី ចំណែករឿងអាកាយិត អ៊ុំរ៉ុប គឺមានប្រជាប្រិយភាពណាស់ សម្រាប់ជនជាតិចាមនៅក្នុងប្រទេសវៀតណាម ។ អក្សរសាស្ត្រដែលមិនទាក់ទងទៅនឹងសាសនានេះក៏បានលើកឡើងអំពីប្រវត្តិរាជវង្សានុវង្ស រឿងព្រេងនិងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយចំនួនដែលនិយាយអំពីការបង្កើតបច្ចេកទេសកសិកម្ម វិធីផ្សំឱសថ និងវិទ្យាសាស្ត្រខាងផ្នែកក្រុណាផ្សេងៗ ។* **សារឡេះ អាប់ឌុលរ៉ស់ម៉ាន**

# តួអក្សរក្នុងភាសាចាម
# THE CHAM ALPHABETS

| ល-រ | អក្សរចាម | = | អានថា | អានថា | ល-រ | អក្សរចាម | = | អានថា | អានថា |
|---|---|---|---|---|---|---|---|---|---|
| 1 | | = | អា | A | 22 | | = | ដា | DA |
| 2 | | = | អុី | I | 23 | | = | ដា | DHA |
| 3 | | = | អ៊ុ | U | 24 | | = | នឺ | NÚ |
| 4 | | = | អឺ | E | 25 | | = | ណា | NA |
| 5 | | = | អាយ | AI | 26 | | = | ដា | DA |
| 6 | | = | អូ | O | 27 | | = | ប៉ា | PA |
| 7 | | = | កា | KA | 28 | | = | ប៉ា | PPA |
| 8 | | = | ខា | KHA | 29 | | = | ផា | PHA |
| 9 | | = | ហ្គា | GA | 30 | | = | បា | BA |
| 10 | | = | ហ្គា | GHA | 31 | | = | បា | BHA |
| 11 | | = | ង៊ឺ | NGÚ | 32 | | = | មឺ | MÚ |
| 12 | | = | ង៉ា | NGA | 33 | | = | ម៉ា | MA |
| 13 | | = | ឆា | CHA | 34 | | = | បា | BBA |
| 14 | | = | ឈ៉ា | CHHA | 35 | | = | យ៉ា | YA |
| 15 | | = | ចា | JA | 36 | | = | រ៉ា | RA |
| 16 | | = | ជា | JHA | 37 | | = | ឡា | LA |
| 17 | | = | ញ៊ឺ | NHÚ | 38 | | = | វ៉ា | VA |
| 18 | | = | ញ៉ា | NHA | 39 | | = | ស្យា | SSA |
| 19 | | = | ដ្យ៉ា | NHJA | 40 | | = | សា | SA |
| 20 | | = | តា | TA | 41 | | = | ហា | HA |
| 21 | | = | ថា | THA | | | | | |

# គ្រួសារខ្ញុំ

ខ្ញុំបាទឈ្មោះ កើ ម៉ាត់ អាយុ៣៩ឆ្នាំ ។ នៅឆ្នាំ១៩៨៥ ខ្ញុំឈប់រៀនត្រឹមថ្នាក់ទី៨ ហើយទៅរៀនផ្នែកសាសនាអ៊ីស្លាម រហូតដល់ឆ្នាំ១៩៩០ នៅភូមិពោធិឥន្ទ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃពីស ឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បច្ចុប្បន្នរស់នៅភូមិឃុំដដែល ។ ភូមិព្រៃពីសស្ថិតនៅក្នុងឃុំកំពង់ត្រឡាចលើ មុនរបបខ្មែរក្រហម ។ នៅពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ខ្ញុំទើបតែមានអាយុ៩ឆ្នាំប៉ុណ្ណោះ ដោយសារការចងចាំរបស់ខ្ញុំព្រមទាំងការនិយាយប្រាប់ពីចាស់ៗ ធ្វើឲ្យខ្ញុំអាចសរសេរសាច់រឿងសង្ខេបនេះឡើង ។

ប្រជាជនក្នុងភូមិរបស់ខ្ញុំរស់នៅលំបាកវេទនាណាស់ ដោយសារសង្គ្រាម ។ ខ្ញុំឮចាស់ៗតំណាលអំពីរឿងរ៉ាវនេះថា នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានចេញចូលមកអុកឡុកភូមិដោយបានសុំស្បៀងពីប្រជាជននិងឃោសនាអំពីគោលនយោបាយបដិវត្តន៍ខ្មែរក្រហមដល់ប្រជាជនរហូតដល់មានក្រុមយុវជនស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហម ។ មាខ្ញុំម្នាក់ឈ្មោះ សុះ ត្រូវខ្មែរក្រហមកេណ្ឌធ្វើជាកងទ័ពជាមួយក្មេងដទៃទៀតខណៈពេលដែលគាត់កំពុងឃ្វាលគោ ។ ពេលនោះគោទាំងហ្វូងរបស់គាត់ដើរមកផ្ទះវិញដោយខ្លួនឯង ។

ក្នុងឆ្នាំ១៩៧៤ ភូមិរបស់ខ្ញុំស្ថិតនៅក្នុងតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហមនិងទាហានលន់នល់ ។ ពេលខ្លះក្រុមទាំងពីរនេះពើបប្រទះនិងប្រយុទ្ធគ្នាបណ្តាលឲ្យផ្ទះសម្បែងមួយចំនួនឆេះព្រមទាំងបង្កឲ្យមានមនុស្សស្លាប់និងរបួសជាច្រើននាក់ ។ ជួនកាលទាហានលន់នល់ឡើងមកចាប់មនុស្សពីលើផ្ទះនៅពេលយប់យកទៅសម្លាប់ដោយចោទថា ក្រុមគ្រួសារឬភូមិនោះជាជម្រករបស់ទ័ពខ្មែរក្រហម ។ កងទ័ពខ្មែរក្រហមដែលនៅខាងព្រៃនាមខេត្តកំពង់ឆ្នាំងបានចូលមកចាប់មនុស្សយកទៅសម្លាប់ឬបង្កឲ្យមានរបួសដល់អ្នកភូមិ ។ ឪពុករបស់ខ្ញុំត្រូវចោទថាជាតិញសម្ងាត់របស់ លន់នល់ ហើយត្រូវខ្មែរក្រហមចាប់និងបណ្តើរនាំយកទៅសម្លាប់ ។ ម្តាយរបស់ខ្ញុំបាននាំកូនៗគេចខ្លួនទៅផ្សារខត្តុង ។ ១០ថ្ងៃក្រោយ ឪពុកខ្ញុំក៏ត្រូវដោះលែងដោយសារប្អូនរបស់គាត់ជាកងទ័ពខ្មែរក្រហមបានទៅសុំធានាមកវិញ ។ នៅពេលយប់អ្នកភូមិទាំងអស់បារម្ភពីសុវត្ថិភាពរស់នៅតាមផ្ទះរៀងៗខ្លួន ហើយក៏បានប្រមូលគ្នាសម្រាកនៅលើវិហារអ៊ីស្លាម ឬប្រមូលគ្នាទៅសម្រាកនៅផ្ទះអ្នកភូមិណាម្នាក់ ដើម្បីគេចពីការកៀររបស់ខ្មែរក្រហម ។ ប៉ុន្តែនៅតែមានប្រជាជនមួយចំនួនត្រូវខ្មែរក្រហមកៀរទៅក្នុងព្រៃនាម តាមបណ្តោយមាត់បឹងឬទន្លេ ។ នៅពេលដែលទាហានលន់នល់ដឹងដំណឹងនេះក៏ទៅវាយរំដោះប្រជាជនពីខ្មែរក្រហមមកវិញ ។ ទោះបីយ៉ាងណាក៏ដោយ ការប្រយុទ្ធគ្នានេះបណ្តាលឲ្យប្រជាជនស្លាប់និងរងរបួសមួយចំនួន ។

ថ្ងៃមួយខ្មែរក្រហមបានមកដីកលេណដ្ឋានក្នុងភូមិរបស់ខ្ញុំទុកសម្រាប់ប្រយុទ្ធគ្នាជាមួយទាហានលន់នល់ ។ អ្នកភូមិរបស់ខ្ញុំបានសុំឲ្យខ្មែរក្រហមចេញពីភូមិសិនដើម្បីកុំឲ្យមានការប្រយុទ្ធគ្នា ប៉ុន្តែខ្មែរក្រហមមិនព្រមដកថយឡើយ ។ ក្រោយមកអ្នកភូមិខ្ញុំនាំគ្នាស្រែកព្រមៗគ្នា ហើយលីកាំបិត ពូថៅដាវឡើង ធ្វើឲ្យខ្មែរក្រហមបាត់បង់ម្ចាស់ការរត់ចេញពីភូមិអស់ ។ តាំងពីពេលនោះមកភូមិរបស់ខ្ញុំមិនបានសុខឡើយ ។ ខ្មែរក្រហមបានដើរស្រាវជ្រាវចាប់ខ្លួនមេបះបោរឲ្យអ្នកភូមិកាន់កាំបិតពូថៅដើម្បីបង្អាក់ការជីកលេណដ្ឋាន ។ អ្នកខ្លះក៏ចាប់ផ្តើមរត់គេចខ្លួនទៅនៅខេត្តក្រុងផ្សេងៗ ដូចជា ក្រុងប៉ៃលិន ក្រុងភ្នំពេញ ខេត្តបាត់ដំបង និងខេត្តពោធិសាត់ ។ លោកយាយលោកតារបស់ខ្ញុំបានទៅរស់នៅជាមួយគ្រួសារខ្ញុំនៅខត្តុង គាត់ទាំងពីរមិនព្រមទៅតាមមាមីងរបស់ខ្ញុំទេ ពីព្រោះគាត់ស្រឡាញ់ពួកខ្ញុំ ។ ក្រោយមកក្រុមគ្រួសារខ្ញុំបានធ្វើដំណើរតាមយន្តហោះទៅរស់នៅស្រុកអូរជ្រៅ (បច្ចុប្បន្នស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ) ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ឮដំណឹងតាមវិទ្យុថាប្រទេសកម្ពុជាលែងមានសង្គ្រាម ហើយប្រជាជននឹងរស់នៅសុខសាន្តត្រាណដូចដើមវិញ ។ ក្រុមគ្រួសារខ្ញុំបានឯកភាពថានឹង

ត្រឡប់មកស្រុកកំណើតវិញដោយជួលរថយន្តកុងទ័រមួយតម្លៃ ១ជីដែលអាចផ្ទុកមនុស្សបាន២០គ្រួសារ ។ យើងត្រូវធ្វើដំណើរចេញពីខេត្តសៀមរាបមកស្រុកកំណើតវិញ ព្រោះស្ពានផ្លូវជាតិលេខ៥ត្រូវកាត់ផ្តាច់ ។ យើងនាំគ្នាសម្រាកនៅខេត្តសៀមរាបមួយយប់ ព្រលឹមស្រាងៗឡើង ស្រាប់តែឃើញកងទ័ពខ្មែរក្រហមក្នុងសម្លៀកបំពាក់ខ្មៅប្រដាប់ដោយអាវុធគ្រប់ដៃចេញមកបណ្តេញយើងទាំងអស់គ្នាឲ្យចាកចេញ ។ ក្រុមគ្រួសារខ្ញុំនិងគ្រួសារដទៃទៀតបាននាំគ្នាចេញដំណើរមកជាមួយគេឯង ។ គ្រួសារខ្ញុំត្រូវជម្លៀសទៅតាមផ្លូវជាតិលេខ៦ ហើយនៅពេលមកដល់ចំណុចតាំងគ្រង ខ្មែរក្រហមឲ្យពួកគាត់ចុះពីផ្លូវជាតិធ្វើដំណើរតាមផ្លូវលំប្រហែល២គីឡូម៉ែត្រ ។ នៅទីនោះមានទីស្នាក់ការមួយដែលប្រើសម្រាប់ឆែកយកមាសប្រាក់ពីប្រជាជន និងក៏ជាកន្លែងដែលខ្មែរក្រហមបំបែកប្រជាជនឲ្យទៅតាមផ្លូវផ្សេងៗដែរ ។ ទោះបីជាប្រជាជនយំអង្វរសុំទៅជាមួយក្រុមគ្រួសារបងប្អូន យ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមមិនព្រមឲ្យប្រជាជនទាំងនោះទៅជួបជុំគ្នាឡើយ ។ ក្រោយពីធ្វើដំណើរប្រហែលមួយសប្តាហ៍ ខ្មែរក្រហមចាត់ឲ្យក្រុមគ្រួសារខ្ញុំទៅរស់នៅភូមិស្រែវាល ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្តសៀមរាប ។ ទៅដល់ទីនោះភ្លាម ជនជាតិចារាយដែលបានជម្លៀសមកពីកន្លែងផ្សេងៗ បាននាំគ្នាចោមរោមមើលពួកខ្ញុំ ព្រោះពួកគេមិនដែលឃើញជនជាតិចាមដូចជាយើងខ្ញុំ ។ ជនជាតិចារាយទាំងនោះក៏និយាយភាសាចាមខ្លះដែរ ប៉ុន្តែយើងស្តាប់គ្នាមិនសូវបានទេ ។

យើងអត់មានអាហារហូបទេព្រោះអង្ករដែលម្តាយខ្ញុំយកទៅជាមួយអស់ទៅហើយ ។ ម្តាយខ្ញុំក៏យកសម្លៀកបំពាក់និងរបស់របរទៅដូរយកអង្ករមកដាំបាយហូបបណ្តោះអាសន្ន ។ យាយរបស់ខ្ញុំពូកែធ្វើកន្ត្រកម្ហូណាស់ គាត់បានទៅបោចវល្លិថ្មីងនៅតាមព្រៃជិតៗនោះដើម្បីយកមកធ្វើកន្ត្រកដូរយកមាន់មកចិញ្ចឹម ។ កាលណោះវល្លិថ្មីងសម្បូរណាស់ព្រោះគ្មានអ្នកណាត្រូវការវាឡើយ ។ គាត់ធ្វើកន្ត្រកទាំងយប់ទាំងថ្ងៃ ហើយដូរបានមាន់យ៉ាងច្រើន ។

ខ្មែរក្រហមហៅប្រជាជនមកប្រជុំដើម្បីឲ្យប្រជាជនយករបស់របរដូចជា មាស ប្រាក់ ចានឆ្នាំង ស្បាបព្រា មាន់ ទា គោ ក្របីដាក់សមូហភាពទាំងអស់ ។ ប្រសិនបើអង្គការដឹងថា មានអ្នកលួចលាក់ទុកនឹងត្រូវមានទោសសម្លាប់ចោល ។ ម្នាក់ៗសោកស្តាយទ្រព្យសម្បត្តិរបស់ខ្លួន ប៉ុន្តែមិនមានអ្នកណាហ៊ានប្រកែកឡើយ ។

អង្គការបានប្រជុំដាក់ទិសនិងដាក់ការងារឲ្យប្រជាជនធ្វើ ។ ម្តាយនិងឪពុកខ្ញុំធ្វើការនៅក្នុងកងស្ទូងស្រូវ ។ ក្រៅពីធ្វើស្រែ គាត់ទាំងពីរត្រូវអង្គការចាត់តាំងឲ្យទៅជីកក្លួចដាក់សហករណ៍ទុកលាយបបរឲ្យអ្នកធ្វើការហូប ។ យាយខ្ញុំធ្វើជាមេដោះមើលកុមារតូចៗ ចំណែកតារបស់ខ្ញុំទៅឃ្វាលគោ ។ ពួកគាត់ចេញទៅធ្វើការពីម៉ោង៥ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ ហើយពីម៉ោង១រសៀលរហូតដល់ម៉ោង៥ល្ងាចទើបត្រឡប់មកផ្ទះវិញ ។ ចំណែកខ្ញុំនិងបងស្រីខ្ញុំសែងលាមកគោពីក្រោលយកទៅដាក់ក្នុងរណ្តៅនៅពេលព្រឹក និងកាប់ដើមទន្រ្ទានខែត្រយកមកចិញ្ច្រាំធ្វើជីនៅពេលល្ងាច ។ ខ្ញុំធ្លាប់បានទៅមើលសិល្បៈមួង ហើយថែមទាំងបានច្រៀងលើកសរសើរអង្គការបដិវត្តន៍ទៀតផង ។

ក្រោយមកយាយរបស់ខ្ញុំត្រូវផ្លាស់ទៅនៅក្នុងក្រុមដាំបន្លែវិញ ។ ដោយអាណិតចៅពេក គាត់ក៏លួចបេះសណ្តែកគួរចាស់ៗដុតទុកឲ្យខ្ញុំនិងចៅៗរបស់គាត់ដទៃទៀតហូប ។ ចំណែកតារបស់ខ្ញុំវិញ នៅពេលដើរឃ្វាលគោតាមព្រៃភ្នំ គាត់ក៏ឆ្លៀតបេះផ្លែកកកោះចាស់ៗមកដុតរួចប្រឡេះយកគ្រាប់ដាក់ហោប៉ៅផ្ញើចៅៗជារៀងរាល់ថ្ងៃ ។

នៅចុងឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចោទថាជាគិញ ហើយចាប់យកទៅសម្លាប់ ដោយគ្រាន់តែប្រាប់ថាយកគាត់ទៅរៀនសូត្រ ។ ខ្ញុំបានឃើញឈ្លបបណ្តើរគាត់ចេញទៅកាលណោះខ្ញុំទើបតែមានអាយុប្រហែល១០ឆ្នាំប៉ុណ្ណោះ ។ ម្តាយខ្ញុំលួចយំ ប្រហែលជាគាត់ដឹងរឿងរ៉ាវទាំងនេះ ។ ក្រោយមកម្តាយខ្ញុំត្រូវអង្គការបង្ខំឲ្យរៀបការជាមួយបុរសដទៃទៀត រួចឲ្យគាត់ទៅធ្វើការនៅក្នុងក្រុមបុកនិងកិនអង្ករ ។ ម្តាយរបស់ខ្ញុំលួចកន្ទក់ខ្ចប់ស្លឹកចេកហើយអាំងឡើងក្រៀមយកមកឲ្យពួកខ្ញុំហូប ។

នៅក្នុងឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់ខ្ញុំ និងអ្នកដទៃទៀតនៅក្នុងភូមិត្រូវជម្លៀសទៅនៅកន្លែងថ្មីមួយទៀតដែលជាព្រៃក្រាស់ ។ អង្គការប្រាប់ឲ្យប្រជាជនកាប់ព្រៃដែលមានបណ្តោយប្រវែង៤គីឡូម៉ែត្រនិងទទឹង១គីឡូម៉ែត្រដើម្បីរៀបចំជាភូមិ

មួយសម្រាប់ប្រជាជន៤សហករណ៍ដែលត្រូវបានជម្លៀសមកពីភូមិជាច្រើន។ ភូមិថ្មីនេះមានឈ្មោះថា ភូមិកែវរ៍យ ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្តសៀមរាប។ អង្គការរៀបចំខ្ទមជាជួរសម្រាប់ឲ្យប្រជាជនរស់នៅ ហើយបំបែកក្រុមគ្រួសារខ្ញុំឲ្យនៅសហករណ៍ផ្សេងគ្នា។ យាយរបស់ខ្ញុំត្រូវបានចាត់តាំងទៅក្នុងសហករណ៍ទី១ ម្តាយខ្ញុំនៅភូមិសហករណ៍ទី៣ ចំណែកអ៊ំខ្ញុំនៅសហករណ៍ទី៤។ ជនជាតិចាមត្រូវបានហាមឃាត់មិនឲ្យនិយាយភាសាចាម និងមិនឲ្យមានសាសនា មិនតែប៉ុណ្ណោះថែមទាំងបង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូក។ ក្រៅពីការហាមប្រាមនេះ អង្គការបានចាប់មនុស្សយកទៅសម្លាប់ជាបន្តបន្ទាប់។ ខ្ញុំឃើញអតីតមន្ត្រីរាជការរបបលន់នល់ត្រូវចាប់ខ្លួន។ តាសូត អតីតអភិបាលស្រុកស្ទោងត្រូវយកទៅសម្លាប់ខណៈពេលដែលគាត់កំពុងឃ្វាលគោជាមួយជីតារបស់ខ្ញុំ។ កូនប្រុសរបស់គាត់បីនាក់ ដែលម្នាក់ជាអតីតកងរាជអាវុធហត្ថ និងពីរនាក់ទៀតជាអតីតគ្រូបង្រៀនក៏ត្រូវបានសម្លាប់ចោលទាំងអស់ដែរ។

ប្រជាជនខ្លះស្លាប់ដោយសារការអត់ឃ្លាននិងជំងឺ។ នៅដើមឆ្នាំ១៩៧៦ អ៊ំប្រុសរបស់ខ្ញុំម្នាក់ស្លាប់ដោយសារអត់ឃ្លាន គាត់ហូបតែក្តួចមិនដែលមានបាយម្តងណាឡើយ ជាហេតុបណ្តាលឲ្យគាត់ធ្លាក់ខ្លួនឈឺស្គមរហូតដល់ស្លាប់។ បន្ទាប់មក នៅចុងឆ្នាំ១៩៧៦ ជីតារបស់ខ្ញុំក៏ស្លាប់ដោយជំងឺគ្រុនចាញ់។ ម្តាយខ្ញុំបានសុំប្រធានកងយកសាកសពគាត់ទាំងពីរទៅបញ្ចុះតាមប្រពៃណីសាសនាអ៊ីស្លាមនៅភូមិស្វាយលើ។

ពួកខ្ញុំនៅរស់រហូតដល់កងទ័ពវៀតណាមចូលរំដោះប្រទេសកម្ពុជា។ ពេលនោះខ្ញុំឃើញមេកង មេឃុំ មេស្រុក នាំគ្នាបររទេះដឹកកូនចៅសំដៅទៅភ្នំ។ អ្នកភូមិក៏នាំគ្នាទៅយកឆ្នាំងចានដែលអង្គការប្រមូលដាក់សហករណ៍មកវិញ។ អ្នកខ្លះចាប់គោមកទឹមរទេះ និងខ្លះទៀតទៅកើបស្រូវអង្ករដើម្បីវិលត្រឡប់មកស្រុកកំណើតរៀងៗខ្លួនវិញ។ ក្រុមគ្រួសារខ្ញុំធ្វើដំណើរមកដល់ទីរួមខេត្តសៀមរាប ហើយស្នាក់នៅទីនោះរយៈពេលប្រហែលមួយខែទើបធ្វើដំណើរមកស្រុកកំណើតវិញ។ យាយខ្ញុំត្រេកអរណាស់ គាត់សង្ឃឹមថានឹងបានជួបជុំកូនស្រីទាំងពីររបស់គាត់ដែលបានបែកគ្នានៅភូមិព្រៃពីសមិនខាន ប៉ុន្តែអ្នកជិតខាងប្រាប់គាត់ថា កូនស្រីទាំងពីររបស់គាត់ត្រូវខ្មែរក្រហមដឹកតាមរទេះយកទៅសម្លាប់បាត់ទៅហើយបន្ទាប់ពីប្តីត្រូវបានសម្លាប់ចោលដោយចោទប្រកាន់ថាជាគិញ។ ម៉ាន លីតាំ ដែលរស់នៅជិតសហករណ៍ព្រៃពីសក៏បានឮគាត់ទាំងពីរស្រែកលាថា “បងទាំងពីរអើយខ្ញុំលាហើយ” ប៉ុន្តែគាត់ពុំហ៊ានឆ្លើយតបវិញឡើយ ព្រោះខ្លាចអង្គការនាំយកគាត់ទៅសម្លាប់ដែរ។ យាយរបស់ខ្ញុំស្រឡាំងកាំងរកនិយាយអ្វីមិនរួច។ គាត់ធ្លាក់ខ្លួនវិកលចរិតហើយក្រោយមកក៏ស្លាប់។

ពេលមកដល់ភូមិកំណើតដំបូង ខ្ញុំគ្មានឃើញមនុស្សម្នាក់ឡើយ។ ផ្ទះសម្បែងត្រូវបានរុះរើគ្មានសល់ សូម្បីតែវិហារអ៊ីស្លាមក៏ត្រូវរុះអស់ដែរ។ អ្នកភូមិក៏នាំគ្នាទៅរស់នៅភូមិកញ្ជោងវិញ។

នៅមុនឆ្នាំ១៩៧៥ភូមិរបស់ខ្ញុំមានប្រជាជនជាង៧០០គ្រួសារស្មើនឹង៣៥០០នាក់ ក្រោយឆ្នាំ១៩៧៩ នៅសល់តែ៥៤គ្រួសារប៉ុណ្ណោះ ហើយអ្នកដែលរស់រានទាំងនោះសុទ្ធសឹងតែលាក់ប្រវត្តិថា មិនមែនជាអ្នកភូមិព្រៃពីសទេ។ អ្នកខ្លះបានដូរឈ្មោះខ្មែរដើម្បីកុំឲ្យគេស្គាល់។ ឧទាហរណ៍ ឈ្មោះ អែល ដូរមកឈ្មោះ ណាត់, ខទីជះ ប្តូរឈ្មោះថា សឿន បុ រីម វិញ។ អ្នកខ្លះ



ព្រឹទ្ធាចារ្យនិងអ្នកចេះមន្តអាគមនៅក្នុងភូមិ

ភ័យបាក់ស្បាតមិនហ៊ានវិលត្រឡប់មករស់នៅក្នុងភូមិស្រុកវិញទេ ដោយសុខចិត្តទៅរស់នៅកន្លែងផ្សេងដូចជាខេត្តបាត់ដំបង និងពោធិ៍សាត់ និង៤០គ្រួសារទៀតទៅរស់នៅភូមិនិមិត្ត ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ និងខេត្តស្វាយរៀង ។

នៅឆ្នាំ១៩៨០ ម្តាយរបស់ខ្ញុំស្លាប់ដោយសារជំងឺ និងបន្សល់ទុកបងប្អូនខ្ញុំ៤នាក់ដែលជាក្មេងកំព្រាឲ្យរស់នៅជាមួយគេឯង ។ ពួកខ្ញុំបែកបាក់គ្នាអស់ ។ បងប្អូនខ្ញុំម្នាក់ទៅរស់នៅជាមួយគេផ្សេង ម្នាក់ទៅនៅជាមួយអ្នកនេះ ហើយម្នាក់ទៀតនៅជាមួយអ្នកនោះ ។ ពួកខ្ញុំពុំមានសម្លៀកបំពាក់និងហូបចុកដូចគេដូចឯងឡើយ ។

សព្វថ្ងៃខ្ញុំជាគ្រូបង្រៀនសាសនាអ៊ីស្លាមនៅភូមិព្រៃពីស សិស្សរបស់ខ្ញុំមានចំនួន៤០នាក់ ។ បច្ចុប្បន្នមនុស្សនៅក្នុងភូមិរបស់ខ្ញុំបានកើនឡើងដល់ជាង៣០០គ្រួសារ ។

ឆ្លងកាត់របបខ្មែរក្រហមដ៏ជូរចត់និងរហូតធ្វើឲ្យខ្ញុំបែកបាក់ក្រុមគ្រួសារ ខ្ញុំសំណូមពរឲ្យតុលាការកាត់ទោសខ្មែរក្រហមឲ្យបានឆាប់រហ័ស ព្រោះរបបខ្មែរក្រហមជារបបប្រល័យពូជសាសន៍ ។ ប៉ុន្តែការកាត់ក្តីតែមួយមុខមិនគ្រប់គ្រាន់សម្រាប់ជនរងគ្រោះឡើយ ។ ខ្ញុំសុំឲ្យមានការជួយកសាងវិហារឬសាលារៀន និងអណ្តូងទឹកសម្រាប់ភូមិឋានរបស់ខ្ញុំនិងប្រជាជនទាំងអស់ឡើងវិញដើម្បីឲ្យជីវភាពរបស់អ្នកដែលរស់រានពីរបបខ្មែរក្រហមមានលក្ខណៈប្រសើរឡើង ។

ខ្ញុំសូមគាំទ្រដល់មជ្ឈមណ្ឌលឯកសារដែលខិតខំចងក្រងឯកសារខ្មែរក្រហមទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយដើម្បីឲ្យយល់ដឹងពីរបបនេះ ។ **ភើ ម៉ាត់**

# លិខិតពីមិត្តអ្នកអាន

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៥

ប្រធានគ្រប់គ្រងកម្មវិធីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកប្រធានជាទីគោរពរាប់អាន!

ដើម្បីចូលរួមចំណែកក្នុងការចងក្រងសៀវភៅប្រវត្តិសាស្ត្រជនជាតិចាមក្រោមរបបខ្មែរក្រហមឲ្យមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ ដើម្បីផ្សព្វផ្សាយដល់ក្មេងជំនាន់ក្រោយ ដ៏ដូចជាសាកលលោកដឹងពីសោកនាដកម្មរបស់សហគមន៍ចាមមូស្លីម និងជាសារប្រយោជន៍មួយក្នុងការបង្កើតឲ្យមានប្រវត្តិសាស្ត្រចាមក្រោមរបបខ្មែរក្រហម ខ្ញុំបាទសូមផ្តល់ជាចម្លើយខ្លះដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់សហគមន៍ចាមក្រោមរបបខ្មែរក្រហមនៅភូមិដូង ឃុំព្រែកញ្ញ ស្រុកពញាឮ ខេត្តកណ្តាល ។ ចម្លើយទាំងនោះមានដូចតទៅ ÷

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនភូមិពពាលខែ (ភូមិខ្ពង់) របស់យើងខ្ញុំ ដែលមានចំនួន១២២គ្រួសារ ស្មើនឹង ៥២៧នាក់ (ប្រុស២២៨នាក់, ស្រី២៩៩នាក់) ត្រូវបានខ្មែរក្រហមជម្លៀសចេញទៅរស់នៅតាមទីជនបទនានាតាមទិសដៅបញ្ជារបស់ខ្មែរក្រហម ដែលប្រដាប់ដោយអាវុធ ជាពិសេសទៅកាន់ភូមិភាគពាយ័ព្យនៃប្រទេសដែលទីនោះហើយជាឋាននរកលោកិយរបស់ប្រជាជន ។ ខ្មែរក្រហមប្រើប្រជាជនឲ្យធ្វើការជាទម្ងន់ ហើយបង្អត់អាហារនិងសម្លាប់ដោយទារុណកម្មផ្សេងៗយ៉ាងព្រៃផ្សៃ ។ ប្រជាជនជាច្រើនស្លាប់ដោយសារគ្មានថ្នាំសង្កូវសម្រាប់ព្យាបាល ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ អ្វីដែលមានសម្រាប់យើងទាំងអស់គ្នានាពេលនោះគឺគំនរដេះដង់ដែលជាកាកសំណល់នៃសង្គ្រាម ។ ប្រជាជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហមមានប្រមាណតែ៣៥គ្រួសារប៉ុណ្ណោះ (ក្នុងចំណោម១២២គ្រួសារ) ដែលបានវិលត្រឡប់មកវិញ ក្នុងនោះមានស្រី២៤នាក់ ស្ត្រីមេម៉ាយ១៨នាក់ និងកុមារកំព្រា៥៨នាក់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានគ្រប់គ្រងកម្មវិធីជ្រាបជាពត៌មាន ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានអំពីខ្ញុំបាទ ។

**ឡិប ហូសេន**

# ដំណឹងសួររកបងប្រុសនិងបងស្រី

បន្ទាប់ពីខ្ញុំបានអានព័ត៌មាននិងបានដឹងថាអង្គការរបស់លោកជួយស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន នាងខ្ញុំស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកបងប្រុសនិងបងស្រីរបស់ខ្ញុំដែលបានបែកពីខ្ញុំនៅក្នុងឆ្នាំ១៩៧៥ ។


ណាអូមិ ហាមម័រស្មី

ខ្ញុំនិងបងស្រីភ្លោះរបស់ខ្ញុំ កើតក្នុងខែមករា ឆ្នាំ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ ។ មួយសប្តាហ៍ក្រោយយើងខ្ញុំទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលកុមារកំព្រានៅទីក្រុងភ្នំពេញដែលមានឈ្មោះថាផ្ទះកាណាដា ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៥ យើងទាំងពីរត្រូវបានគ្រួសារជនជាតិកាណាដាមួយ យកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ សព្វថ្ងៃយើងខ្ញុំទាំងពីរនាក់កំពុងតែស្វែងរកព័ត៌មានស្តីពីបងប្រុសនិងបងស្រីដែលត្រូវបានទុកចោលនៅទីក្រុងភ្នំពេញ ។

យើងខ្ញុំទាំងពីរពុំដឹងថាឪពុកម្តាយបងប្អូនរបស់ខ្ញុំមានឈ្មោះអ្វីខ្លះ ហើយក៏ពុំដឹងថាយើងទាំងពីរនាក់កើតនៅទីណានោះទេ ។ យើងខ្ញុំទាំងពីរនាក់គ្រាន់តែដឹងព័ត៌មានបន្តិចបន្តួចពីស្រ្តីជនជាតិកាណាដាដែលបម្រើការនៅមណ្ឌលកុមារកំព្រាប៉ុណ្ណោះ ។

ឪពុករបស់យើងខ្ញុំទាំងពីរនាក់ បានស្លាប់នៅមុនពេលដែលយើងទាំងពីរនាក់កើតមកម្ល៉េះ ហើយគាត់ទំនងជាទាហាន លន់ នល់ ។ បន្ទាប់ពីម្តាយរបស់ខ្ញុំបានផ្តល់កំណើតឲ្យយើងទាំងពីរនាក់នៅក្នុងឆ្នាំ១៩៧៥មក សុខភាពរបស់គាត់បានចុះទន់ខ្សោយដោយសារតែកង្វះអាហារបរិភោគ និងធ្វើឲ្យគាត់មិនអាចចិញ្ចឹមបីបាច់យើងខ្ញុំទាំងពីរបាន ។ បន្ទាប់ពីបុគ្គលិកមណ្ឌលកុមារកំព្រាទទួលបានព័ត៌មានអំពីខ្ញុំទាំងពីរ ពួកគេបានស្វែងរកយើងរហូតបានប្រទះឃើញយើងនៅដេកលើគំនរសំរាមនៅក្នុងខ្ទមមួយ ។ បន្ទាប់មកក៏បាននាំយើងទាំងពីរទៅកាន់ផ្ទះកាណាដា និងយកម្តាយរបស់ខ្ញុំទៅសាលាសំណាក់ ។ បងស្រីខ្ញុំមានអាយុប្រហែល១៨ឆ្នាំ ធ្វើការនៅមណ្ឌលកុមារកំព្រា ហើយបងប្រុសខ្ញុំមានអាយុប្រហែល៧ឆ្នាំស្នាក់នៅជាមួយម្តាយ ។

នៅក្នុងផ្ទះកាណាដា មានកុមារកំព្រាចំនួន៤០នាក់ និងបុគ្គលិកខ្មែរប្រហែល១០នាក់ឬ១៥នាក់មើលថែរក្សាកុមារទាំងនោះ ។ ក្រោយមក កុមារទាំងនោះត្រូវបានយកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ ផ្ទះកាណាដានេះរៀបចំឡើងដោយស្រ្តីជនជាតិកាណាដាជាច្រើននាក់ ។ លោក ស្រី ណាអូមិ ប្រុណស្តេន បានធ្វើដំណើរចុះឡើងពីកម្ពុជាទៅកាណាដាក្នុងការចាត់ចែងការទទួលយកក្មេងទៅចិញ្ចឹម ចំណែកលោកស្រី ដុល្លី ឆារ៉េត និង អាណា ឆារ៉េត ជាអ្នកមើលថែរក្សាកុមារកំព្រាទាំងនោះ ។

ទោះបីជាយើងខ្ញុំទាំងពីរនាក់ពុំមានព័ត៌មានលម្អិតច្រើនស្តីអំពីក្រុមគ្រួសាររបស់ខ្ញុំយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា សារតាររបស់ខ្ញុំ និងផ្ទះកាណាដានេះ អាចផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់បងប្អូន ដែលបានដឹងដំណឹងអំពីបងប្រុស និងបងស្រីរបស់យើងទាំងពីរនាក់ ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការជួយជ្រោមជ្រែងស្វែងរកព័ត៌មានបន្ថែមស្តីអំពីគ្រួសាររបស់យើងខ្ញុំទាំងពីរនាក់ និងអាចជួយធ្វើឲ្យយើងទាំងពីរនាក់ជួបជុំគ្រួសារវិញ ។


បងស្រីរបស់ ណាអូមិ ហាមម័រស្មី

**ណាអូមិ ហាមម័រស្មី**




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Special Number ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.